# របាយការណ៍

# ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា

**កង ច័ន្ទតារារ័ត្ន និង លឹម ជាណែត**

Brett Ballard **និង សូ សុវណ្ណារិទ្ធិ**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**ខែមិថុនា ឆ្នាំ២០០៥**

**Cambodia’s Annual Economic Review**

May 2005

Kang Chandararot and Dannet Liv *and* Brett Ballard and So Sovannarith

**© រក្សាសិទ្ធិ២០០៥ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)**

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃឯកសារនេះ ចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៏អក្សរពី វបសអ ឡើយ ។

## របាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា

កង ច័ន្ទតារ៉ាវត្ថ និង លីវ ដាណែត *និង* Brett Ballard និង សូ សុវណ្ណារិទ្ធិ

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះ៥៦ ផ្លូវ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៩១៦ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: cdri@camnet.com.kh website: http://www.cdri.org.kh

បកប្រែដោយ: អ៊ុំ ចាន់ថា
កែសម្រួល និងរចនាដោយ: យូ សិទ្ធីរិទ្ធ និង យេន សុផានី
បោះពុម្ពនៅកម្ពុជា ដោយរោងពុម្ព ជប៉ុន ភ្នំពេញ

# មាតិកា


បញ្ជីតារាង និងក្រាហ្វិក ..... i

បញ្ជីអក្សរកាត់ ..... iii

បុព្វកថា ..... v

កំណត់សំគាល់ពីដំបូង ..... vii

សេចក្តីថ្លែងអំណរគុណ ..... xiii

**ផ្នែកទី ១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០០៣ ..... ១**

១.១ ស្ថានភាពទូទៅ ..... ១

១.២ ផលិតផលក្នុងស្រុកសរុប-តាមផ្នែក ..... ៣

១.៣ ផលិតផលក្នុងស្រុកសរុប - តាមប្រភេទតំរូវការ ..... ៩

១.៤ ហិរញ្ញវត្ថុសាធារណៈ ..... ១២

១.៥ រូបិយវត្ថុ និងកំរិតថ្លៃ ..... ១៩

១.៦ ជញ្ជីងទូទាត់ ..... ២៣

១.៧ សន្និដ្ឋាន និងការព្យាករណ៍ពីអនាគត ..... ២៥

ឯកសារយោង ..... ២៩

**ផ្នែកទី ២. របាយអត្ថប្រយោជន៍នៃបណ្ណសំគាល់កម្មសិទ្ធិដីធ្លី: វិនិយោគខាងកសិកម្ម និងឥណទានស្ថាប័ន ............................................ ៣១**

២.១. សេចក្តីផ្តើម ........................................................................................ ៣១

២.២ រចនាសម្ព័ន្ធជំពូក ..................................................................................៣៥

២.៣ ការសិក្សាឯកសារ និងវិធីសាស្ត្រ ...........................................................៣៦

២.៤ កម្មសិទ្ធិអចលនវត្ថុ និងសុវត្ថិភាពនៃការកាន់កាប់ដី .................................. ៤៦

២.៥ វិធីសាស្ត្រស្រាវជ្រាវ ..............................................................................៤៩

២.៦ ស្ថានភាពកាន់កាប់ដីបច្ចុប្បន្ន .................................................................៥៣

២.៧ ការវិនិយោគផ្នែកកសិកម្ម ផលិតភាព និងការប្រើប្រាស់ដី ........................ ៦១

២.៨ សកម្មភាពឥណទាននៅកំរិតគ្រួសារ ...................................................... ៧៣

២.៩ សន្និដ្ឋាន ..............................................................................................៨១

ឯកសារយោង.......................................................................................................... ៨៥

ឧបសម្ព័ន្ធ ក................................................................................................................ ៨៩

ស្ថិតិបន្ថែម.................................................................................................................៩៣

# បញ្ជីតារាង និងក្រាហ្វិក

## បញ្ជីតារាង


តារាង ២.១: សង្ខេបអំពីការកាន់កាប់ដីកសិកម្មតាមគ្រួសារ............................................៥៥
តារាង ២.២: បែបបទទទួលបានដី................................................................................ ៥៦
តារាង ២.៣: ទ្រព្យសកម្ម និងពលកម្ម ក្នុងគ្រួសារ........................................................ ៥៨
តារាង ២.៤: សង្ខេបដីកសិកម្មតាមយេនឌ័រ...................................................................៥៩
តារាង ២.៥: ការទទួលបានដីតាមយេនឌ័រ.................................................................... ៦០
តារាង ២.៦: ទ្រព្យធនរបស់គ្រួសារ និងពលកម្ម .......................................................... ៦០
តារាង ២.៧: ធាតុចូលផលិតស្រូវ ................................................................................៦៣
តារាង ២.៨: ប្រភពចំណាយសំរាប់ធាតុចូលកសិកម្មជ្រើសរើស....................................... ៦៤
តារាង ២.៩: ប្រភពហិរញ្ញប្បទានសំរាប់ធាតុចូលជាជីគីមី............................................... ៦៥
តារាង ២.១០: ទិន្នផលស្រូវជាមធ្យមនៃផ្ទៃដីបានប្រមូលផលសរុប................................ ៦៦
តារាង ២.១១: ធាតុចូលសំរាប់ផលិតកម្មស្រូវ ............................................................... ៦៦
តារាង ២.១២: ផលិតភាព និងចំណាយ........................................................................ ៦៨
តារាង ២.១៣: សង្ខេបផលិតកម្មគ្រួសារ....................................................................... ៦៨
តារាង ២.១៤: ការប្រើប្រាស់ដីលំនៅដ្ឋានតាមទំហំដីកាន់កាប់ ....................................... ៧០
តារាង ២.១៥: ប្រភពឥណទាន ................................................................................... ៧៤
តារាង ២.១៦: ការប្រើប្រាស់កំចីតាមទំហំដីកាន់កាប់ ....................................................៧៦
តារាង ២.១៧: ប្រភពឥណទានលំអិតតាមការប្រើប្រាស់កំចី...........................................៧៧
តារាង ២.១៨: ការចែកចាយកំចីតាមឃុំ និងប្រភព....................................................... ៨០
តារាង ក១: ភាពគ្រប់គ្រាន់នៃស្រូវ...............................................................................៩០

## បញ្ជីក្រាហ្វិក

ក្រាហ្វិក ១.១: ការនាំចូលស៊ីម៉ង់ត៍ និងដែកថែបរបស់កម្ពុជា.......................................................៧
ក្រាហ្វិក ១.២: ភាគរយវិនិយោគសាធារណៈ................................................................................១១
ក្រាហ្វិក ១.៣ ភាគរយឱនភាពសរុប........................................................................................ ១៣
ក្រាហ្វិក ១.៤: ពន្ធគយលើប្រេងឥន្ធនៈនាំចូល- ចំណូលពន្ធជាក់ស្តែង និងផែនការ ............ ១៤
ក្រាហ្វិក ១.៥: ការប្រមូលពន្ធគយលើប្រេងឥន្ធនៈនាំចូល.............................................. ១៥
ក្រាហ្វិក ១.៦: ការបែងចែកចំណាយចរន្តក្នុងឆ្នាំ២០០៣...............................................១៧
ក្រាហ្វិក ១.៧: ១០ខេត្តមានឱនភាពធំជាងគេ........................................................................... ១៨
ក្រាហ្វិក ១.៨: អត្រាឱ្យខ្ចីប្រាក់ចារីកនៅកម្ពុជា ថៃ និងវៀតណាម..................................២១

# បញ្ជីអក្សរកាត់

| | |
|---|---|
| BSP | គំរោងអង្កេតជាមូលដ្ឋាន (Baseline Survey Project) |
| CDRI/វបសអ | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| FDI | វិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment) |
| GDP/ផសស | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product) |
| HCAs | តំបន់មានសមត្ថភាពខ្ពស់ (High Capacity Areas) |
| HPI | ផលប៉ះពាល់ជាសក្តានុពលខ្ពស់ (High Potential Impact) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| LCAs | តំបន់មានសមត្ថភាពទាប (Low Capacity Areas) |
| LMAP | គំរោងរដ្ឋបាល និង គ្រប់គ្រងដីធ្លី (Land Management and Administration Project) |
| LPI | ផលប៉ះពាល់ជាសក្តានុពលទាប (Low Potential Impact) |
| MFI | ស្ថាប័នមីក្រូហិរញ្ញវត្ថុ (Micro-finance Institution) |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (Ministry of Land Management, Urban Construction, and Planning) |
| NBC | ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-Government Organisation) |
| Oxfam GB | អង្គការអុកស្វាមអង់គ្លេស (Oxford Famine-Great Britain) |

| | |
|---|---|
| PDK | សាធារណរដ្ឋប្រជាមានិតកម្ពុជា (Peoples Republic of Kampuchea) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| SES | អង្កេតសង្គមកិច្ច-សេដ្ឋកិច្ច (Socio-Economic Survey) |
| SME | សហគ្រាសធុនតូច និងមធ្យម (small and medium enterprises) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation) |

# បុព្វកថា

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា មានសេចក្តីសោមនស្សរីករាយ ដោយបានបោះពុម្ព *របាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំ* លើកទី៤ របស់ខ្លួន ។ *របាយការណ៍* លើកទី១ បានផ្សព្វផ្សាយនៅឆ្នាំ២០០១ ក្នុងគោលបំណងផ្តល់ ការពិនិត្យសព្វគ្រប់លើការអនុវត្តន៍សេដ្ឋកិច្ចថ្មីៗ និងការវិភាគពីបញ្ហាម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ ។ ម្យ៉ាងទៀត *របាយការណ៍* បានសង្កត់ធ្ងន់លើបញ្ហាមួយដែលសេដ្ឋកិច្ចត្រូវប្រឈមមុខនៅតាមវិស័យ និងអនុវិស័យដ៏ជាក់លាក់ ។ ក្នុងពេលកន្លងមក *របាយការណ៍សេដ្ឋកិច្ច* នានា បានលើកជាអាទិ៍ អំពីការអភិវឌ្ឍន៍វិស័យទំនើបៗ (កាត់ដេរ, ទេសចរណ៍) ទីផ្សារដំណាំលក់យកប្រាក់ និងកំណើនវិស័យឯកជន ។ របាយការណ៍លេខនេះ បានផ្តោតទៅលើគំហើញនៃការសិក្សាថ្មីៗរបស់ វិបសអ ស្តីពី ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ។

*របាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំ២០០៤* ចែកចេញជាពីរភាគ ។ ភាគទី១ ផ្តល់ការពិនិត្យជាទូទៅពីស្ថានភាពសេដ្ឋកិច្ចឆ្នាំ២០០៣ ដោយមានការប៉ាន់ស្មានពី ផសស តាមវិស័យ និងតាមតំរូវការ (ការប្រើប្រាស់ វិនិយោគ ពាណិជ្ជកម្ម រដ្ឋាភិបាល) ។ បន្ទាប់មក *របាយការណ៍* ពិនិត្យពីបំរែបំរួលក្នុងសាច់ប្រាក់ ថ្លៃទំនិញ អត្រាការប្រាក់ និងអត្រាប្តូរប្រាក់ រួចហើយបង្ហាញពីជញ្ជីងទូទាត់ និងជញ្ជីងពាណិជ្ជកម្ម ។

រដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តយ៉ាងសកម្មនូវ គោលនយោបាយផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីទាំងក្នុងតំបន់ជនបទ និងទីក្រុង ដើម្បីផ្តល់សុវត្ថិភាពដល់ការកាន់កាប់ដី និងជួយកែលំអទីផ្សារដីធ្លី ។ ភាគទី២ បង្ហាញនូវគំហើញនៃការសិក្សាថ្មីមួយរបស់ វិបសអ លើការផ្តល់ប័ណ្ណកម្មសិទ្ធិ

ដីធ្លី ។ កម្មសិទ្ធិដី មានសារៈសំខាន់ជាគន្លឹះចំពោះការប្រើប្រាស់ដី របៀបរបបគ្រប់គ្រង និង វិនិយោគ ហើយបទពិសោធន៍ក្នុងពេលថ្មីៗនៅកម្ពុជាបានផ្តល់ឱកាសល្អដើម្បីពិនិត្យឱ្យបានជិតដល់ ពីចំណុចស្រាវជ្រាវដ៏សំខាន់នេះ ។ ការសិក្សានេះមិនគ្រាន់តែបង្កើតជារង្វាស់មួយដ៏ច្បាស់លាស់សំរាប់ធ្វើការវាយតំលៃទៅអនាគតប៉ុណ្ណោះទេ ប៉ុន្តែក៏បានផ្តល់នូវសម្មតិកម្ម និងគំហើញដ៏សំខាន់ៗមួយចំនួនដែរ ។

យើងមានជំនឿថា របាយការណ៍នេះ នឹងមានប្រយោជន៍ដល់ទាំងសំរាប់អ្នកកសាងគោលនយោបាយ និងអ្នកវិភាគពីសេដ្ឋកិច្ចកម្ពុជា ។ នាអនាគត យើងសង្ឃឹមថា នឹងអាចធ្វើវិភាគបានកាន់តែល្អិតល្អន់ ព្រមទាំងផ្តល់នូវការព្យាករណ៍ក្នុងរយៈពេលខ្លី និងមធ្យម អំពីកត្តាអថេរសំខាន់ៗក្នុងសេដ្ឋកិច្ច ។ ដូចរាល់លើកដែរ យើងសូមអញ្ជើញមិត្តអ្នកទាំងអស់ ជួយផ្តល់ពតិមានត្រលប់មកយើងខ្ញុំវិញ ដើម្បីយើងខ្ញុំអាចនឹងកែលំអការងារនៅពេលខាងមុខទៀត ។

*ឡារី ស្រ្តេន្ទ*

*នាយកប្រតិបត្តិ*

*វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

# កំណត់សំគាល់ពីដំបូង

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បាន ព្យាយាមចេញផ្សាយជារៀងរាល់ឆ្នាំនូវ របាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំ ស្តីពីឆ្នាំដែលទើបកន្លង ផុត។ ដោយឡែករបាយការណ៍នេះ គឺទាក់ទិននឹងឆ្នាំ២០០៣ ហើយចាប់ផ្តើមឡើងតាមការប៉ាន់ស្មានមួយស្តីពី ផសស ។ ជាទូទៅ ការប៉ាន់ស្មានពី ផសស គឺជាការងាររបស់ វិជ្ជាស្ថានជាតិស្ថិតិ (NIS) ។ ប៉ុន្តែ NIS មិនផ្សព្វផ្សាយនូវការប៉ាន់ស្មានពី ផសស ណាមួយសោះសំរាប់ឆ្នាំ២០០៣ ដូច្នេះហើយ តួលេខរបស់ វបសអ គឺជាតួលេខដ៏ថ្មីបំផុតដែលមានសព្វថ្ងៃសំរាប់ឆ្នាំនេះ ។ តាមពិត ការប៉ាន់ស្មានពីអត្រាកំណើន ផសស ផ្សេងៗទៀតគឺអាចរកបាន (ដូចជា ពី IMF, World Bank និង ADB) ប៉ុន្តែតួលេខទាំងនេះពឹងផ្អែកលើការព្យាករណ៍ ជាជាងលើការគណនាជាក់ស្តែង ចេញពីទិន្នន័យដ៏ជាក់លាក់តាមវិស័យ និងអនុវិស័យ ។

ស្ថានភាពកំណើនឆ្នាំ២០០៣ ឃើញថាអន់ជាងឆ្នាំ២០០២ ដោយសារវិស័យមិនមែនកសិកម្មសំខាន់ៗត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារជំងឺ SARS ដែលធ្វើឱ្យចំណូលខាងទេសចរណ៍ និងវិស័យជាប់ទាក់ទិនផ្សេងៗមានការធ្លាក់ចុះ ។ ប៉ុន្តែឧស្សាហកម្មកាត់ដេរ និងកសិកម្មដាំដុះ មានដំណើរការល្អដោយអត្រាកំណើនបានឡើងដល់ប្រហែល ៤,៦% ។ ពតិមានដែលទទួលបានទាំងអស់ បានបង្ហាញពីការធ្លាក់ចុះស្ថានភាពសេដ្ឋកិច្ចនៅឆ្នាំ២០០៤ ដោយសារការរាំងស្ងួតធ្ងន់ធ្ងរដែលធ្វើឱ្យទិន្នផលកសិកម្មថយចុះដល់កំរិតទាបអាចមានគ្រោះថ្នាក់ ហើយនិងការធ្លាក់ចុះយ៉ាងខ្លាំងក្នុងអនុវិស័យខាងនេសាទ និងព្រៃឈើ ។

ការជជែកវែកញែកពីអនាគតនៃឧស្សាហកម្មកាត់ដេរ នៅតែកើតមានយ៉ាងក្តៅគគុក ដោយមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំងរវាងអ្នកទស្សន៍ទាយពីការដល់ថ្ងៃអវសាន្ត និងអ្នកដែលនៅសុទិដ្ឋិនិយមដ៏ប្រយ័ត្នប្រយែងមួយ ។ ដូច្នេះ នៅពេលដែល IMF ពណ៌នាពីសេនារីយ៉ូដ៏យ៉ាប់យ៉ឺនដែលមានការធ្លាក់ចុះអត្រាកំណើនយ៉ាងខ្លាំងនៅឆ្នាំ២០០៥ (ចុះដល់ ២%) ខាងភាគីរដ្ឋាភិបាល គេនៅមានសុទិដ្ឋិនិយមច្រើនជាង ។

ទេសចរណ៍ ដែលជាប្រភពចំបងមួយទៀតនៃកំណើន បានស្ទុះឡើងវិញក្រោយពីការធ្លាក់ចុះបង្កដោយការឆ្លងជំងឺ SARS នៅឆ្នាំ២០០៣ ហើយសព្វថ្ងៃអ្នកសង្កេតការណ៍ភាគច្រើនមានសុទិដ្ឋិនិយមថានឹងមានកំណើនជាបន្តក្នុងរយៈពេលខ្លី និងមធ្យម ។

បើពិនិត្យជាទូទៅពីលទ្ធផលសេដ្ឋកិច្ចកម្ពុជាក្នុង២-៣ឆ្នាំចុងក្រោយនេះ យើងបានកត់សំគាល់ស្ថានភាពមិនប្រាកដប្រជា និងអស្ថិរភាពយ៉ាងខ្លាំង ដែលគូសបញ្ជាក់ពីភាពទន់ខ្សោយជាមូលដ្ឋាននៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជា ។ កសិកម្មរួមចំណែកប្រហែល ១ភាគ៣ នៃផសស សរុប ហើយវិស័យសេវាកម្មរួមចំណែកបាន ១ភាគ៣ ទៀត ។ ចំពោះ ១ភាគ៣ ដែលនៅសល់ គឺបានមកពីខាងឧស្សាហកម្ម និងសំណង់ ។ ប៉ុន្តែកសិកម្ម បានផ្តល់ការងារភាគច្រើនណាស់ និងបានជួយទ្រទ្រង់ដល់ភាគច្រើនបំផុតនៃអ្នកក្រីក្រ ។

វិស័យទាំង៣ នេះ បានទទួលរងគ្រោះរៀង១ខ្លួនពីភាពមិនប្រាកដប្រជា និងអស្ថិរភាពយ៉ាងខ្លាំង ។ ដូច្នេះ ថ្វីបើកសិកម្មមានដំណើរការល្អក្នុងមួយរយៈពេលវែងកន្លងមកនេះ ប៉ុន្តែវាប្រហែលដោយសារការពង្រីកផ្ទៃដីជាសំខាន់ ជាជាង ការធ្វើប្រពលវប្បកម្ម ការផ្លាស់ប្តូរបច្ចេកវិទ្យា ឬការទទួលបានទិន្នផលកាន់តែខ្ពស់ ។ ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ (ផ្លូវ និងប្រព័ន្ធធារាសាស្ត្រ) ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មខ្សោយ និងសេវាកម្មឥណទានខ្សោយ បានធ្វើឱ្យកសិកម្មកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងទៅលើអាកាសធាតុ និងទឹកភ្លៀង ដែលនាំឱ្យមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំក្នុងទិន្នផល និងចំណូល ហើយធនធាន និងការរៀបចំនានាក៏មានតិចតួចសំរាប់ទប់ទល់លនឹងការប៉ះទង្គិចផ្សេង១ ។

បញ្ហាប្រឈមនឹងឧស្សាហកម្ម ដែលសំដៅភាគច្រើនដល់វិស័យកាត់ដេរ គឺមានគេដឹងជាទូទៅហើយមិនបាច់អធិប្បាយលំអិតទេ ។ ការចំណាយផលិកម្មក្នុងមួយឯកតារបស់កម្ពុជាមានកំរិតពី ២៥-៣០% ខ្ពស់ជាងគូប្រកួតរបស់ខ្លួននៅចិន និងវៀតណាម ហើយអត្រានេះមិនងាយដោះស្រាយចេញទេ បើសិនគ្មានកំណែទំរង់ដ៏ជ្រាលជ្រៅខាងអភិបាលកិច្ច និងសេដ្ឋកិច្ច ។ ទេសចរណ៍ នៅតែសំខាន់ស្លាប់រស់សំរាប់សេដ្ឋកិច្ច ថ្វីបើចរិតងាយប្រែប្រួលចុះឡើងរបស់វាគឺជាប្រភពនៃការព្រួយបារម្ភមួយក្តី ។ ម្យ៉ាងទៀត សមាហរណកម្មអន់ខ្សោយនៃវិស័យទេសចរណ៍ជាមួយនឹងវិស័យផ្សេងទៀតនៃសេដ្ឋកិច្ច បានរួមចំណែកធ្វើឱ្យតំលៃបន្ថែមទទួលបានមានកំរិតទាប ប៉ុន្តែមានផលប៉ះពាល់អវិជ្ជមានជាច្រើនដែលក្លាយជាបន្ទុកចំណាយដ៏ធ្ងន់ចំពោះប្រទេស ដូចជា ទេសចរផ្លូវភេទ ការពង្រីកគ្មានផែនការនូវសណ្ឋាគារ ផ្ទះសំណាក់ និងបនល្បែង និងការជួញដូរស្ត្រី និងកុមារ ។ ដូច្នេះ ចាំបាច់ត្រូវស្រាវជ្រាវរកប្រភពកំណើនមានស្ថិរភាពច្រើន ដូចជា ផ្នែកកសិកម្ម និងការកែច្នៃ, និងការធ្វើអាជីវកម្មលើទីផ្សារ*ក្នុងស្រុក* និងនៅបរទេស ។

ក្នុងពេលជាមួយគ្នា ជាការសំខាន់ដែលស្រាវជ្រាវនូវគ្រប់ឱកាសល្អដែលអាចអនុញ្ញាតឱ្យកម្ពុជាមានស្ថិរភាព និងពង្រីកលទ្ធផលល្អដែលទទួលបានហើយនៅក្នុងឧស្សាហកម្ម និងទេសចរណ៍ ។ ឯផ្លូវខាងមុខគឺត្រូវធ្វើសមាហរណកម្មឱ្យកាន់តែស៊ីជម្រៅ បង្កើនផលិតភាព ផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនទៅលើវិនិយោគក្នុងស្រុក និងស្វែងរកយ៉ាងសកម្មនូវឱកាសល្អថ្មីៗនៃទីផ្សារក្នុងតំបន់ និងជាសាកល ។ ឧទាហរណ៍ មានសញ្ញាជាច្រើនបង្ហាញថា ការគួបផ្សំកត្តាមួយចំនួន អាចជួយការពារឧស្សាហកម្មកាត់ដេរ ពីវិាសនានៃការបិទទ្វាររោងចក្រនៅឆ្នាំ២០០៥ ។ ក្នុងគំនិតនេះ មានការកិច្ចពិភាក្សាមួយចំនួនពីកំណែទំរង់នៃ "ច្បាប់ស្តីពីប្រភពដើម" ដែលអាចជួយសំរួលដល់ការនាំចេញផលិតផលកាត់ដេរកម្ពុជា ទៅសហភាពអឺរ៉ុប និងដែលនៅក្រោមច្បាប់បច្ចុប្បន្នគឺមិនអាចធ្វើកើតទេ ។ ម្យ៉ាងទៀត មានសញ្ញាជាច្រើនបង្ហាញថា ស្តង់ដារពលកម្ម និងការផ្តោតកំលាំងអភិវឌ្ឍទីផ្សារតូចៗដែលឧស្សាហកម្មនេះបានកំណត់យក គឺអាចមានប្រសិទ្ធភាពច្រើនច្រើនក្នុងការរក្សាការពារចំណែកទីផ្សារ ។ អង្កេតក្នុងពេលថ្មីៗមួយធ្វើដោយធនាគារពិភពលោក បានបង្ហាញថា អ្នកទិញចំបងៗនូវ ផលិតផលកាត់

ដេរកម្ពុជា ប្រហែលមិនដកការបញ្ជាទិញចេញពីកម្ពុជាទេ ក្នុងរយៈពេលខ្លី និងមធ្យមនេះ ។ ហើយសមាជិកភាពក្នុង WTO ក៏អាចជួយរៀបចំផ្លូវសំរាប់លំហូរចូលនូវ វិនិយោគផ្ទាល់ពីបរទេស (FDI) ពីប្រទេសនានា ដូចជា ជប៉ុន ទៀតផង។

ដូច្នេះអនាគតដ៏ខ្លីខាងមុខ អាចមិនមែនយ៉ាប់យ៉ឺនដូចមានលើកឡើងជារឿយៗនោះទេ ថ្វីបើគ្រោះថ្នាក់វាអាចកើតឡើងបានពិតមែនក្តី ។ សេនារីយ៉ូដ៏អាក្រក់បំផុត គឺករណីដែលកសិកម្មត្រូវរងគ្រោះដោយការរាំងស្ងួតពីរឆ្នាំជាប់គ្នា (ប៉ុន្តែយើងយល់ថា វាមិនងាយរាំងដូច្នេះទេ) មានកើតជំងឺផ្តាសាយបក្សីមួយថ្មីទៀត ហើយវិធីសាស្ត្រនៃការរកទីផ្សារតូចៗរបស់ឧស្សាហកម្មកាត់ដេរបានទទួលបរាជ័យ ។ ថ្វីបើគេមិនអាចទាត់ចោលទាំងស្រុងនូវលទ្ធភាពកើតមានហេតុការណ៍អវិជ្ជមានទាំងនេះព្រមៗគ្នាក្តី ប៉ុន្តែ រឿងបែបនេះវាកំរខ្លាំងណាស់ ។ ក្នុងករណីវាកើតមានពិតមែន វាអាចអូសទាញឱ្យកំណើន ផសស ធ្លាក់ចុះក្រោម ២% ។

ចំពោះសេណារីយ៉ូល្អបំផុតគឺ យើងប្រមូលផលកសិកម្មបានយ៉ាងច្រើននៅឆ្នាំក្រោយ (មិនមែនជាការកំរទេ) កំណើនដ៏លឿនក្នុងវិស័យទេសចរណ៍ (ស្របតាមទិន្នាការក្នុងតំបន់) និងឧស្សាហកម្មកាត់ដេរមានស្ថិរភាពល្អ និងមានកំណើនវិជ្ជមាន (ដូចជា ដោយសារមានទីផ្សារថ្មីៗនៅអឺរ៉ុប) ។ ក្នុងស្ថានភាពបែបនេះ កំណើន ផសស អាចនៅកៀកនឹងកំរិត ៥-៦% ដូចក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ តើសេនារីយ៉ូបែបនេះ វាកំរខ្លាំងណាស់ ឬយ៉ាងណា?

អ្នកកសាងគោលនយោបាយ និងដៃគូអភិវឌ្ឍន៍នានា នឹងតាមដានដោយបារម្ភនូវការវិវត្តន៍សេដ្ឋកិច្ចក្នុងប៉ុន្មានខែ-ប៉ុន្មានឆ្នាំខាងមុខនេះ នៅពេលវាលាតត្រដាងចេញមក ។ របាយការណ៍សេដ្ឋកិច្ចឆ្នាំ២០០៣ នេះ អាចជួយឱ្យមានការយល់ដឹងកាន់តែពេញលេញថែមទៀត ពីស្ថានភាពថ្មីៗ សំរាប់ប្រៀបធៀបជាមួយនឹងទិន្នន័យឆ្នាំ២០០៤ និង ២០០៥ នៅពេលដែលគេអាចរកវាបាន ។

របាយការណ៍នេះ មានពីរផ្នែក ។ ផ្នែកទី១ មានការពិនិត្យត្រួសៗពីស្ថានភាពសេដ្ឋកិច្ច ព្រមទាំងផ្តល់ការប៉ាន់ស្មាន ផសស តាមវិស័យ និងតាមតំរូវការ (ការប្រើប្រាស់ វិនិយោគ

ពាណិជ្ជកម្ម រដ្ឋាភិបាល) ។ បន្ទាប់មក *របាយការណ៍* ពិនិត្យពីកត្តាអថេរម៉ាក្រូសេដ្ឋកិច្ច សំខាន់ៗ ដូចជា សាច់ប្រាក់ ថ្លៃទំនិញ អត្រាការប្រាក់ និងអត្រាប្តូរប្រាក់ រួចហើយបង្ហាញពី ជញ្ជីងទូទាត់ និងជញ្ជីងពាណិជ្ជកម្ម ។

បច្ចុប្បន្នមានការឯកភាពជាទូទៅថា គោលនយោបាយបែបបុរាណដែលមិនសូវយក ចិត្តទុកដាក់ដល់កសិកម្ម និងការអភិវឌ្ឍន៍ជនបទ គឺត្រូវតែកែប្រែវិញ ដើម្បីឱ្យកម្ពុជាអាចទទួល បានផលប្រយោជន៍ពីឧត្តមភាពប្រៀបធៀបនៃ ការសំបូរដីធ្លី និងពលកម្មមានតំលៃទាប ។ លក្ខខណ្ឌត្រូវមានជាមុននៃការពង្រឹងកសិកម្មឡើងវិញ គឺកំណែទំរង់ដីធ្លី ក្នុងនេះការងារដ៏ សំខាន់បំផុតគឺ ការផ្តល់នូវប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ ដល់អ្នកកាន់កាប់ ឬអ្នកប្រើប្រាស់ដី ។ ផ្នែកទី ២ នៃរបាយការណ៍ បង្ហាញពី គំហើញក្នុងការសិក្សាថ្មីមួយរបស់ វបសអ ស្តីពីការផ្តល់ ប័ណ្ណកម្មសិទ្ធិដីធ្លី និងផលប៉ះពាល់ជាសក្តានុពលទៅលើផលិតភាព និងប្រសិទ្ធភាពនៃកសិកម្ម កម្ពុជា ។

នៅចុងបញ្ចប់នៃរបាយការណ៍ មានឧបសម្ព័ន្ធមួយផ្តល់នូវ ទិន្នន័យស្តីពីអថេរសេដ្ឋកិច្ច សំខាន់ៗក្នុងរយៈ ១០ឆ្នាំមកដល់ឆ្នាំ២០០៣ គឺមាន ទិន្នន័យស្តីពី ការងារ ផសស ការនាំចេញ នាំចូល ចំណូលនិងចំណាយថវិកា ជញ្ជីងទូទាត់និងជញ្ជីងពាណិជ្ជកម្ម ។

ដូចសព្វដងដែរ គួររំលឹកពីការត្រូវប្រុងប្រយ័ត្នចំពោះគុណភាពទិន្នន័យ ។ ថ្វីបើក្រសួង មួយចំនួនបង្កើតទិន្នន័យបានហើយក្តី (ជួនកាលមានការប្រឹងប្រែងជាន់គ្នា) ប៉ុន្តែគេមិនទាន់ បង្កើតបាននៅឡើយទេនូវ ប្រព័ន្ធប្រមូលផ្តុំមួយសំរាប់ ចងក្រង បន្សីុគ្នា ឬផ្គុំទិន្នន័យបានពី ក្រសួងនានា ដែលអាចជួយកាត់បន្ថយកំហុស ឬលេខល្មៀងផ្សេងៗបានមួយកំរិតធំ ។ របាយការណ៍នេះ មិនអាចរកឃើញកំហុសជាក់ស្តែងបែបនេះបានទេ ប៉ុន្តែយ៉ាងដូច្នេះក៏មិនមែន មានន័យថា វាគ្មានសោះនោះដែរ ។

*K.A.S. Murshid*

*នាយកស្រាវជ្រាវ*

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធសូមអរគុណដ៏ជ្រាលជ្រៅដល់អ្នកឆ្លើយសំភាសន៍ទាំងអស់ ដែលបានចំណាយពេលដ៏មានតំលៃដើម្បីផ្តល់ចំលើយចំពោះសំនួរទាំងឡាយ ។ ក្រុមអ្នកនិពន្ធសូមអរគុណជាពិសេសចំពោះមន្ត្រីរដ្ឋាភិបាល និងពាណិជ្ជករ ទាំងនៅកំរិតជាតិ និងមូលដ្ឋាន ដែលបានឆ្លើយសំភាសន៍ និងផ្តល់ពត៌មានសំខាន់ៗដល់ក្រុមស្រាវជ្រាវ ។ ក្រុមអ្នកនិពន្ធ ទទួលបានអត្ថប្រយោជន៍ច្រើនណាស់ពីសហប្រតិបត្តិការរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ធនាគារជាតិនៃកម្ពុជា, វិជ្ជាស្ថានជាតិស្ថិតិ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្រុមអ្នកនិពន្ធសូមអរគុណដល់បណ្ឌិត K.A.S. Murshid នាយកស្រាវជ្រាវ និង បណ្ឌិត Mustafa Mujeri ដែលបានពិនិត្យឯកសារឡើងវិញ ព្រមទាំងផ្តល់យោបល់ជួយកែលំអផ្សេងៗ និង លោក Larry Strange ជានាយកប្រតិបត្តិនៃ វិបសអ ដែលបានគាំទ្រដល់ការសិក្សានេះ ។ ក្រុមអ្នកនិពន្ធក៏សូមអរគុណដល់ សហការីទាំងអស់ ជាពិសេស កញ្ញា អ៊ូច ច័ន្ទតារានី និងលោក តុង គឹមសុន ដែលបានរួមចំណែកដោយផ្ទាល់ដល់ការកសាងរបាយការណ៍ ។ ក្រុមអ្នកនិពន្ធសូមអរគុណជាពិសេសដែរដល់លោក Allen Myers ដែលបានជួយកែសំរួលអត្ថបទរបាយការណ៍ និង លោក Ray Hossinger អ្នកគ្រប់គ្រងប្រតិបត្តិ និងបុគ្គលិករដ្ឋបាលនិងហិរញ្ញវត្ថុរបស់ វិបសអ ដែលបានផ្តល់ការគាំទ្រយ៉ាងមានប្រសិទ្ធភាពខាងផ្នែកសំភារៈ និងភស្តុភារ ។

នៅទីបញ្ចប់ ក្រុមអ្នកនិពន្ធ និង វិបសអ សូមថ្លែងអំណរគុណដល់ Danida, មូលនិធិ Rockefeller និងជំនួយអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុ ។ ក្រុមអ្នក

និពន្ធ សូមអរគុណដល់ គំរោងរដ្ឋបាល និងគ្រប់គ្រងដីធ្លី នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានអនុញ្ញាតឱ្យប្រើផ្នែកខ្លះៗ នៃសេចក្តីព្រាងរបាយការណ៍ស្តីពី អង្កេតជាមូលដ្ឋានលើការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី សំរាប់កសាងឯកសារនេះ ។

*កង ច័ន្ទតារ័ត្ន និង លីវ ដាណែត*

*Brett Ballard និង សូ សុវណ្ណារិទ្ធិ*

*ធ្នូ ២០០៤, ភ្នំពេញ, កម្ពុជា*

# ផ្នែកទី ១

# ស្ថានភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០០៣

*ដោយ កង ច័ន្ទតារារ័ត្ន និង លីវ ដាណែត*

## ១.១ ស្ថានភាពទូទៅ

នៅឆ្នាំ២០០៣ កំណើនផលិតផលក្នុងស្រុកសរុប (ផសស) របស់កម្ពុជា បានធ្លាក់ចុះដល់ ៤,៤% ធៀបនឹង ៥,៣% នៅឆ្នាំ២០០២ ដោយសារការថយចុះផ្នែកសេវាកម្ម និងឧស្សាហកម្ម ដែលបានកាត់កងគ្នានឹងកំណើនក្នុងផ្នែកកសិកម្ម ។

កសិកម្មកើនឡើង ២,២% នៅឆ្នាំ២០០៣ គឺលឿនជាងឆ្នាំ២០០២ ។ ថ្វីបើអនុវិស័យ បសុសត្វ និងបសុបក្សី ការនេសាទ ព្រៃឈើ និងការកាប់ឈើ បានរួមចុះក្តី ប៉ុន្តែអនុវិស័យខាង ដំណាំដំដុះមានដំណើរការល្អ ដែលនាំឱ្យមានការរីកចំរើនជាទូទៅគួរកត់សំគាល់ ។

ម្យ៉ាងទៀត កំណើនផ្នែកឧស្សាហកម្មបានថយចុះដល់ ១១% នៅឆ្នាំ២០០៣ ធៀបនឹង ១៣,៨% នៅឆ្នាំ២០០២ ។ ទោះបីឧស្សាហកម្មកាត់ដេរមានដំណើរការយ៉ាងប្រពៃដោយអត្រា កំណើនស្ទុះដល់ ២២,៥% នៅឆ្នាំ២០០៣ ក្តី ប៉ុន្តែការធ្លាក់ចុះ ៣% ក្នុងផ្នែកសំណង់បានប៉ះ ពាល់ដល់កំណើននៃផ្នែកឧស្សាហកម្ម ។

ដូចគ្នាដែរ ផ្នែកសេវាកម្មបានធ្លាក់កំណើន ពី ៥,៥% នៅឆ្នាំ២០០២ មកត្រឹម ២,៥% នៅឆ្នាំ២០០៣ ។ ការធ្លាក់ចុះនេះបណ្តាលជាសំខាន់ពីការធ្លាក់ចុះក្នុងផ្នែកពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន ដែលសុទ្ធតែជាប់ទាក់ទងនឹងវិស័យទេសចរណ៍ ។ នៅឆ្នាំ២០០៣ ទេសចរ

បរទេសចូលមកកម្ពុជា ធ្លាក់ចុះ ១១% ធៀបនឹងឆ្នាំ២០០២ ដែលប្រហែលមកពីការធ្វើកុប្បកម្ម ប្រឆាំងថៃ ការផ្ទុះជំងឺ SARS និង ការមានសង្គ្រាមដឹកនាំដោយសហរដ្ឋអាមេរិកនៅអ៊ីរ៉ាក់ ។

ស្ថានភាពចំណាយ បានឆ្លុះបញ្ចាំងយ៉ាងល្អនូវរូបភាពក្នុងផ្នែកផលិតកម្ម ។ ចំណាយប្រើប្រាស់កើនបាន ៦% គឺខ្ពស់ជាងកំណើននៅឆ្នាំ២០០២ បន្តិច ។ ដោយចំណាយផ្នែកឯកជននៅថេរ ដូច្នេះយើងអាចសន្និដ្ឋានថា អត្រាកំណើនខ្ពស់នៃការប្រើប្រាស់ វាឆ្លុះបញ្ចាំងពីកំណើនកាន់តែលឿននៃចំណាយសាធារណៈ ។ នៅឆ្នាំ២០០៣ ចំណាយប្រើប្រាស់សាធារណៈ កើន ១១% ធៀបនឹង ៩,៧% នៅឆ្នាំ២០០២ ។

ផ្ទុយទៅវិញ កំណើនវិនិយោគសរុបបានធ្លាក់ចុះខ្លាំងមកត្រឹម ៧,៥% នៅឆ្នាំ២០០៣ ដែលបណ្តាលពីការធ្លាក់ចុះទាំងផ្នែកវិនិយោគសាធារណៈ និងឯកជន ។ ទោះជា គោលនយោបាយរបស់រដ្ឋាភិបាលចំពោះចំណាយមូលធន គ្មានការប្រែប្រួលក្តី ក៏ការធ្លាក់ចុះចំណាយសាធារណៈសំរាប់វិនិយោគ គឺបណ្តាលពីការធ្លាក់ចុះនៃការអនុវត្តន៍ថវិកាជាតិ (ឬចំណាយជាក់ស្តែង) ។ វិនិយោគដោយផ្នែកឯកជន ធ្លាក់ចុះ ៣,៤% នៅឆ្នាំ២០០៣ ដោយសារមានការកាត់បន្ថយវិនិយោគផ្ទាល់ពីបរទេស អស់ ២១% ។ ប៉ុន្តែ វិនិយោគទុនឯកជនក្នុងស្រុកបានកើន ១,៥% ។

ការនាំចេញដែលនាំមុខដោយផលិតផលសំលៀកបំពាក់ កើន ១៦,៨% នៅឆ្នាំ២០០៣ គឺលើសពីឆ្នាំ២០០២ ដែលមានតែ ១១,៥% ។ ក្នុងជាមួយគ្នា ការនាំចូលកើន ១២,២% ជាពិសេស សាច់ក្រណាត់ ផលិតផលប្រេងឥន្ធនៈ យានយន្ត និងសំភារៈសំណង់ ។

វិន័យខាងសារពើពន្ធ បានកែលំអឡើងនៅឆ្នាំ២០០៣ ដោយ ឱនភាពសាធារណៈសរុប ធ្លាក់ចុះដល់ ២៤៨,៧លានដុល្លារនៅឆ្នាំ២០០៣ ដែលកាលពីឆ្នាំ២០០២ មានដល់ ៣០៧,៣ លានដុល្លារ ។ គិតជាភាគរយនៃ ផសស ឱនភាពសាធារណៈសរុប ធ្លាក់ចុះដល់ត្រឹម ៦,៦% នៅឆ្នាំ២០០៣ ធៀបនឹង ៨,៥% នៅឆ្នាំ២០០២ ។

ធនាគារជាតិនៃកម្ពុជា បានរឹតបន្តឹងការផ្គត់ផ្គង់ប្រាក់សាច់ក្នុងឆ្នាំ២០០៣ ដោយបង្កើនវាយឺតៗក្នុងអត្រាត្រឹម ១៥% ធៀបនឹង ៣៣,៥% នៅឆ្នាំ២០០២ ។ ប៉ុន្តែប្រាក់រៀលនៅតែចុះថ្លៃអស់ ២% ធៀបនឹងដុល្លារ ក្នុងចន្លោះឆ្នាំ២០០២ និង ២០០៣ ។

ឱនភាពពាណិជ្ជកម្ម បានថយចុះបន្តិចវិញមកត្រឹម ៥៤៩,៣លានដុល្លារនៅឆ្នាំ២០០៣ ធៀបនឹង ៥៦៣លានដុល្លារ នៅឆ្នាំ២០០២។ ទោះយ៉ាងនេះក្តី ក៏ជញ្ជីងទូទាត់សរុបរបស់កម្ពុជានៅឆ្នាំ២០០៣ នៅមានអតិរេកដោយសារកំណើនកំចី និងការផ្ទេរប្រាក់ជាផ្លូវការ ប៉ុន្តែអតិរេកនេះថយចុះពី ១៧២លានដុល្លារនៅឆ្នាំ២០០២ មកត្រឹម ៣០,៦លានដុល្លារនៅឆ្នាំ ២០០៣ ។ រឿងនេះបណ្ដាលឱ្យមានកំណើនតែបន្តិចបន្តួចនៅក្នុង ធនបំរុងបរទេសរបស់ ធនាគារជាតិនៃកម្ពុជា ដែលមានទំហំ ៤៣,៣លានដុល្លារនៅឆ្នាំ២០០២-០៣ ធៀបនឹង ១៧៧លានដុល្លារនៅឆ្នាំ២០០១-០២ ។

## ១.២ ផលិតផលក្នុងស្រុកសរុប តាមផ្នែក

### *១.២.១ កសិកម្ម*

ផ្ទុយពីឆ្នាំ២០០២ កសិកម្មកម្ពុជាបានស្ទុះឡើងវិញដោយកើន ២,២% នៅឆ្នាំ២០០៣ ក្នុងនេះផលិតកម្មផលដំណាំជាកត្តាជំរុញចំបងគេ ដោយបានប៉ះប៉ូវលើសពីបានគ្រប់គ្រាន់នូវការធ្លាក់ចុះក្នុងអនុវិស័យផ្សេងទៀតដូចជា បសុសត្វ បសុបក្សី និងការនេសាទ ជាដើម ។

យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផលិតកម្មស្រូវ កើនពី ៣,៨លានតោននៅឆ្នាំ២០០២ ដល់ ៤,៧លានតោននៅឆ្នាំ២០០៣ ដែលនេះជាផលិតកម្មខ្ពស់បំផុតក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅនេះ ។ ផលិតកម្មស្រូវវស្សា កើន ៣១,៦% ដែលប៉ះប៉ូវបានលើសពីគ្រប់គ្រាន់នូវលទ្ធផលអន់ខ្សោយនៃស្រូវប្រាំង[១] ។ បាត់ដំបងដែលជាខេត្តផលិតស្រូវដ៏ចំបងជាប់ចំណាត់ថ្នាក់ទី៤ បានផលិតស្រូវកើនពីរដងដល់ ៤៤៦.៣៩៩តោន ធៀបនឹង ២៩៥.៥១១តោននៅឆ្នាំ២០០២ ។ ផលិតផលស្រូវនៅខេត្តតាកែវ កើន ២៦,៤% ដល់ ៦១៦.៧៥៧តោន

---

[១] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០០៤) ។

ដែលធ្វើឱ្យខេត្តនេះ មានចំណាត់ថ្នាក់លេខ ២ នៅក្រោមខេត្តព្រៃវែង ដែលផលិតបាន ៦៣៩.៤៥២តោន ។

ជាមួយនឹងកំនើនផ្នែកផលិតកម្មស្រូវ ក៏មានការធ្លាក់ចុះខាងផ្នែកបសុសត្វ បសុបក្សី និង ការនេសាទ ។ ការចាប់ត្រីទឹកសាបធ្លាក់ចុះយ៉ាងខ្លាំងដល់ ៣០៨.៧៥០តោន រឺ ១៤.៣% តិច ជាងឆ្នាំ២០០២ ទោះបីខេត្តនេសាទសំខាន់ៗ ដូចជា កណ្តាល កំពង់ឆ្នាំង ជាដើមទទួលបាន លទ្ធផលលើសពីផែនការក្តី ។ ដោយសារផែនការចាប់ត្រីទឹកសាបឆ្នាំ២០០៣ វាស្មើគ្នានឹងឆ្នាំ ២០០២ (៣៤៤.៨០០តោន) ដូច្នេះការធ្លាក់ចុះសរុប គឺបណ្តាលពីការថយចុះក្នុងខេត្តឯ ទៀតៗ ។ ដោយឡែកខេត្តសៀមរាបដែលស្ថិតក្នុងក្រុមខេត្តចាប់ត្រីបានច្រើនៗជាងគេ គឺសំរេច បានតែ ៧៦.៤% នៃផែនការប៉ុណ្ណោះ ធៀបនឹង ៨៧.១% ក្នុងឆ្នាំ២០០២ ។ រឿងនេះបង្ហាញពី ការធ្លាក់ចុះបរិមាណត្រីចាប់បានយ៉ាងគំហុកដល់ត្រឹម ២៩.៨០០តោននៅឆ្នាំ២០០៣ ធៀបនឹង ៣៤.០០០តោននៅឆ្នាំ២០០២ ។ តាមយោបល់មន្ត្រីនាយកដ្ឋានជលផល ការធ្លាក់ចុះផលត្រី ទឹកសាបនៅតាមខេត្តភាគច្រើននេះ គឺបណ្តាលពីគោលនយោបាយកាត់បន្ថយឡូត៍នេសាទ (ដោយរដ្ឋបានបើកចំហផ្ទៃទឹកជាច្រើនឱ្យសាធារណជនប្រើប្រាស់) ។ម្យ៉ាងទៀត កំណើនការ នាំចូលកូនត្រីពីប្រទេសជិតខាង ពិសេស ថៃ បានកាត់បន្ថយតំលៃបន្ថែមដែលវិស័យនេសាទ បានរួមចំណែកដល់ ផសស ក្នុងឆ្នាំ២០០៣ ។

### *១.២.២ ឧស្សាហកម្ម និងសំណង់*

នៅឆ្នាំ២០០៣ ផ្នែកឧស្សាហកម្មកើន ១១% គឺយឺតជាងឆ្នាំ២០០២ ដែលមានក៏រិត ១៣.៨% ។ ដោយឡែកកំណើនល្បឿនលូតលាស់នៅក្នុងឧស្សាហកម្មកាត់ដេរ ត្រូវបានកាត់កងមកវិញ ដោយការធ្លាក់ចុះក្នុងសកម្មភាពសំណង់ ។

ផលិតកម្មផ្នែកវាយនភណ្ឌ សំលៀកបំពាក់ និងស្បែកជើង កើនដល់ ១.៨ពាន់លាន ដុល្លារ ធៀបនឹង ១.៤ពាន់លានដុល្លារនៅឆ្នាំ២០០២ ។ បើគិតតាមក៏រិតថ្លៃនៅឆ្នាំ២០០០ អនុវិស័យនេះតំណាងឱ្យ ១៥% នៃ ផសស ឆ្នាំ២០០៣ ធៀបនឹងឆ្នាំ២០០២ ធៀបនឹង ១៣% នៅឆ្នាំ២០០២ ។ កំណើនផលិតកម្មក្នុងឧស្សាហកម្មកាត់ដេរ ប្រហែលជាប់ទាក់ទិននឹងការ

បន្ថែមកូតាអោយដោយសហរដ្ឋអាមេរិកនៅឆ្នាំ២០០៣ ។ម្យ៉ាងទៀត កំណើនលំហូរចូលនូវកិច្ចសន្យាម៉ៅការបន្តពី ចិន ដែលជាអ្នកផ្គត់ផ្គង់សំខាន់សំរាប់ទីផ្សារនៅសហរដ្ឋអាមេរិក បានជួយទ្រទ្រង់ដល់ការផលិតសំលៀកបំពាក់កាលពីឆ្នាំមុន[២] ថ្វីបើមានការធ្លាក់ចុះនូវការបញ្ជាទិញពីក្រៅប្រទេស ដោយសារការបារម្ភផ្សេងៗទាក់ទិននឹងការបោះឆ្នោតជាទូទៅក្តី ។ គេរំពឹងថាអ្នកផ្គត់ផ្គង់អន្តរជាតិមកពីចិន នៅតែម៉ៅការបន្តការកាត់ដេរមកឱ្យកម្ពុជា ដោយសារពួកគេមានផែនការធ្វើជាអ្នកផ្គត់ផ្គង់ដ៏ធំសំរាប់ទីផ្សារពិភពលោក បើយោងតាមអង្កេតរបស់ វិបសអស្តីពីឧស្សាហកម្មកាត់ដេរនៅកម្ពុជា[៣] ។ តាមវិធីនេះ រោងចក្រកាត់ដេរមួយចំនួននៅកម្ពុជាអាចនឹងរស់រានតទៅទៀតបាន បន្ទាប់ប្រព័ន្ធកូតាត្រូវផុតកំណត់នៅចុងឆ្នាំ២០០៤ ។ ប៉ុន្តែឧបសគ្គចំបងៗចំពោះការប្រកួតប្រជែងជាអន្តរជាតិរបស់វិស័យកាត់ដេរកម្ពុជា ហាក់ដូចជានៅតែគ្មានដំណោះស្រាយដដែល[៤] ។ ខណៈដែលបញ្ហាចោទទាក់ទិននឹងការរត់ការឯកសារ បានធូរស្រាលឡើងតាមការតឹរមនីតិវិធីការងារការិយាល័យ និងការកាត់បន្ថយពេលប្រគល់ទំនិញក្តី ក៏កង្វះឧស្សាហកម្មគាំទ្រផ្សេងៗ ដូចជា វាយនភណ្ឌ ជាដើម វានៅតែប៉ះពាល់ដល់ភាពប្រកួតប្រជែងជាអន្តរជាតិនេះនៅឡើយ ។ ដើម្បីបង្កើតឧស្សាហកម្មគាំទ្រប្រភេទខ្លះដូចជាវាយនភណ្ឌជាដើម គេត្រូវបំពេញឱ្យបានជាមុននូវលក្ខខណ្ឌមួយចំនួនដូចជា ការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធដឹកជញ្ជូនមានប្រសិទ្ធភាពល្អជាដើម ។ ដោយហេតុថា ស្ថានភាពដែលកំពុងផុសឡើងវាជាប់ទាក់ទងនឹងការដកចេញនូវកិច្ចព្រមព្រៀងក្រណាត់គ្រប់មុខ (Multi-fiber Agreement: MFA) ដូច្នេះ រោងចក្រកាត់ដេរជាច្រើនទំនងជាមិនអាចរស់រានបានទេនៅក្រោយឆ្នាំ២០០៤ ។

---

[២] យោងតាមបទសំភាសន៍ជាមួយសមាគមកាត់ដេរកម្ពុជា ។

[៣] អង្កេតបានធ្វើកាលពីឆ្នាំ២០០៣ ដោយរួមសហការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច (IDE) ស្តីពីភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរនៅកម្ពុជា ។

[៤] សូមអាន Kang, C. and S. Chan (2003) ។

អនុវិស័យចំបងទី២ ក្នុងឧស្សាហកម្មកម្ពុជា គឺផ្នែកសំណង់ ដែលជាមធ្យមផ្តល់ប្រហែល ៦% នៃ ផសស ហើយចាប់ពីឆ្នាំ១៩៩៩-២០០២ តែងមានកំណើនជាប់ជានិច្ច ។ ជាអកុសលនៅឆ្នាំ២០០៣ សកម្មភាពសំណង់ធ្លាក់ចុះ ៣% ពីកំរិតតំលៃបន្ថែម ២៤៩លានដុល្លារនៅឆ្នាំ២០០២ មកត្រឹម ២៤១លានដុល្លារនៅឆ្នាំ២០០៣ បើគិតតាមកំរិតថ្លៃថេរនៅឆ្នាំ២០០០ ។ រឿងនេះឆ្លុះបញ្ចាំងពីការធ្លាក់ចុះទាំងក្នុងចំណាយសាធារណៈ និងឯកជន ក៏ដូចជាពីកំណើនការប្រើប្រាស់សំភារៈសំណង់នាំចូល ។

ការធ្លាក់ចុះជាទូទៅនៃវិនិយោគឯកជន វាបង្ហាញពីការថយចុះសកម្មភាពសំណង់ ។ ក្នុងនេះនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃសាលាក្រុងភ្នំពេញ បានអនុម័តគំរោងសំណង់ ៧១៧គំរោង(រឺ ១,២២លាន ម.$^{២}$) នៅឆ្នាំ២០០៣ ធៀបនឹង ៧៦៩គំរោង (១,៧៦លាន ម.$^{២}$) នៅឆ្នាំ២០០២ ។ ចំណែកចំនួនសំណង់ភូមិគ្រឹះធ្លាក់ចុះ ១១,៣% មកត្រឹម ១៤១គំរោងនៅឆ្នាំ២០០៣ រីឯសំណង់ផ្ទះល្វែងធ្លាក់ចុះពី ៥៣៥គំរោងនៅឆ្នាំ២០០២ មកនៅត្រឹម ៤៩៣គំរោងនៅឆ្នាំ២០០៣ ហើយនេះជាតួលេខទាបបំផុតចាប់តាំងពីឆ្នាំ១៩៩៥ មក។ ដូចគ្នាដែរ ផ្ទៃក្រឡាសរុបនៃគំរោងសំណង់ដែលបានចុះកិច្ចសន្យា បានរួមចុះ ៣០,៦% នៅឆ្នាំ២០០៣ ដែលបណ្តាលជាសំខាន់ដោយការថយចុះសំណង់ផ្ទះល្វែងពី ១,៥លានម.$^{២}$ មកត្រឹម ០,៦១លានម.$^{២}$ ។ តាមនេះ តំលៃគំរោងសំណង់ដែលបានអនុម័តនៅឆ្នាំ២០០៣ ធ្លាក់ចុះមកត្រឹម ១៩៩លានដុល្លារ ដែលកាលពីឆ្នាំ២០០២ មានដល់ ២២០លានដុល្លារ ។ ការធ្លាក់ចុះយ៉ាងខ្លាំងនេះ វាស្របគ្នានឹងការថយចុះយ៉ាងច្រើន (៤៩%) នៃតំលៃសំណង់ផ្ទះល្វែងនៅឆ្នាំ២០០៣ ។

ទិន្នាការជាទូទៅនៃសំណង់ឯកជននៅកម្ពុជា ក៏អាចមើលឃើញតាមការនាំចូលសំភារៈសំណង់ ស៊ីម៉ងត៍ និងដែកថែប ដែរ ។ នៅឆ្នាំ២០០៣ កម្ពុជាបាននាំចូលសំភារៈសំណង់មានតំលៃត្រឹម ៨០,៨លានដុល្លារ ដែលកាលពីឆ្នាំ២០០២ មានដល់ ៩៧,៤លានដុល្លារ ។ ដោយឡែក ការនាំចូលដែកថែបធ្លាក់ចុះមកត្រឹម ២៥,១លានដុល្លារ រឺ ៣២% តិចជាងកាលពីមួយឆ្នាំមុន (សូមមើលក្រាហ្វិក១.១) ។

ប៉ុន្តែកត្តាចំបងនៃការធ្លាក់ចុះផ្នែកសំណង់ក្នុងឆ្នាំ២០០៣ គឺកាត់បន្ថយចំណាយមូលធនសាធារណៈ ។ ចំណាយសាធារណៈលើការសាងសង់នៅឆ្នាំ២០០៣ មានត្រឹម ២៩៤លានដុល្លារ គឺថយចុះ ១៧% ធៀបនឹងឆ្នាំ២០០២ ។ រឿងនេះបណ្តាលជាសំខាន់ពីការថយចុះក្នុងគំរោង និងដែលតំណាងឱ្យប្រហែល ៧១,៥% នៃចំណាយមូលធន ។ នៅឆ្នាំ២០០៣ ជំនួយពីក្រៅប្រទេសជាគំរោងផ្សេងៗ ធ្លាក់ចុះមកនៅត្រឹម ៨០៦,៣លានរៀល (២០២,១លានដុល្លារ) ដែលកាលពីឆ្នាំ២០០២ មានរហូតដល់ ១.០៧៩លានរៀល (២៧៥លានដុល្លារ) ។

**ក្រាហ្វិក ១.១: ការនាំចូលស៊ីម៉ង់ត៍ និងដែកថែបរបស់កម្ពុជា (ពាន់តោន)**




*ប្រភព: ទិន្នន័យប្រមូលបានពីនាយកដ្ឋានគយ និងរដ្ឋាករ*

ថ្វីបើមានចំណែកក្នុង ផសស តូចជាងឧស្សាហកម្មកាត់ដេរ និងសំណង់ក្តី ក៏អនុវិស័យ "ស្បៀងអាហារ ភេសជ្ជៈ និងថ្នាំជក់" និង "ឧស្សាហកម្មផ្សេងទៀត" នៅតែចូលរួមចំណែកជាតំលៃបន្ថែមបានច្រើនគួរកត់សំគាល់ រហូតដល់ ៨៨,៤លានដុល្លារនៅឆ្នាំ២០០៣ ធៀបនឹង ៨៦,៦លានដុល្លារនៅឆ្នាំ២០០២ ។ តំលៃបន្ថែម បានពី "ឧស្សាហកម្មផ្សេងទៀត" កើនដល់ ៣៧,២លានដុល្លារ ។ យោងតាមរបាយការណ៍ពី CDC គំរោងវិនិយោគខាងកែច្នៃអាហារ និង

កសិឧស្សាហកម្ម (ដែលកត់ត្រាក្នុងឧស្សាហកម្មផ្សេងទៀត) កើនពី ៣៦,៧លានដុល្លារនៅឆ្នាំ២០០២ ដល់ ៤៣,៦លានដុល្លារនៅឆ្នាំ២០០៣ ដែលក្នុងនេះ ៩៣% ជាវិនិយោគក្នុងស្រុក។

### ១.២.៣ សេវាកម្ម

នៅឆ្នាំ២០០៣ វិស័យសេវាកម្មកម្ពុជា កើនបានតែ ២,៥% គឺយឺតជាងឆ្នាំ២០០២ ដែលមានកំរិត ៥,៥% ។ ការធ្លាក់ចុះផ្នែកសណ្ឋាគារនិងភោជនីយដ្ឋាន (ដែលរួមចុះ ១,៣% នៅឆ្នាំ ២០០៣) ក៏ដូចជាខាងផ្នែកពាណិជ្ជកម្មជាទូទៅ បានធ្វើឲយចុះដល់ស្ថានភាពសរុប ។

អនុវិស័យ "សណ្ឋាគារ និងភោជនីយដ្ឋាន" មាននិន្នាការប្រែប្រួលស្របគ្នានឹងវិស័យទេសចរណ៍ ព្រោះថានៅឆ្នាំ២០០៣ ចំនួនទេសចរអន្តរជាតិមកទស្សនាកម្ពុជាបានថយចុះ ។ ការធ្លាក់ចុះវិស័យទេសចរណ៍ ជាប់ទាក់ទិននឹងកុប្បកម្មប្រឆាំងថៃ (ដែលនាំឱ្យមានការបិទព្រំដែនកម្ពុជា-ថៃ អស់ប្រហែលបីខែ) ការផ្ទុះជំងឺ SARS និងសង្គ្រាមដឹកនាំដោយសហរដ្ឋអាមេរិកនៅអ៊ីរ៉ាក់ នៅដើមឆ្នាំ២០០៣ ។ ម្យ៉ាងទៀត ភាពមិនច្បាស់លាស់នៅជុំវិញការបោះឆ្នោតកំរិតជាតិកាលពីខែកក្កដា ក៏ទំនងជាបានរួមចំណែកដល់ការធ្លាក់ចុះនេះដែរ ។ យោងតាមក្រសួងទេសចរណ៍ កម្ពុជាបានទទួលទេសចរបរទេស ៧០១.០១៤នាក់នៅឆ្នាំ២០០៣ រឺ ១១% តិចជាងឆ្នាំ២០០២[៥] ។ ទេសចរបរទេសចូលតាមផ្លូវអាកាស មកដល់ អាកាសយានដ្ឋានអន្តរជាតិក្រុងភ្នំពេញ និងសៀមរាប ក្នុងអំឡុងពេលនេះ បានធ្លាក់ចុះ ១៦% (រឺ ២៦៩.៦៧៤នាក់) និង ៨% (រឺ ១៨៦.២៩៨នាក់) រៀងគ្នា ។ ទេសចរអន្តរជាតិចូលតាមផ្លូវគោក និងផ្លូវទឹក ដែលមាន ៦៥% ក៏ធ្លាក់ចុះអស់ប្រហែល ៧% ដែរនៅឆ្នាំ២០០៣ ។

ចំនាយរបស់ទេសចរបរទេសក៏ធ្លាក់ចុះដែរ។ តាមការប៉ាន់ស្មានរបស់ក្រសួងទេសចរណ៍ ចំណាយសរុបរបស់ទេសចរបរទេសធ្លាក់ចុះដល់ ៣៤៦លានដុល្លារនៅឆ្នាំ២០០៣ រឺ ធ្លាក់ចុះ ៩% ធៀបនឹងកាលពីមួយឆ្នាំមុន ។ ទោះបី ចំណាយមធ្យមរបស់ទេសចរម្នាក់ក្នុងមួយថ្ងៃ កើនពី ៨ដុល្លារនៅឆ្នាំ២០០២ ដល់ ៩ដុល្លារនៅឆ្នាំ២០០៣ ក្តី ក៏កំណើននេះត្រូវបានកាត់កងចុះវិញ

---

[៥] ក្រសួងទេសចរណ៍ (២០០២) ។

ដោយសាររយៈពេលស្នាក់នៅកម្ពុជា គឺខ្លីជាងមុន ត្រឹមតែ ៥,៥ថ្ងៃនៅឆ្នាំ២០០៣ ធៀបនឹង ៥,៨ថ្ងៃនៅឆ្នាំ២០០២ ។ អត្រាបំពេញបន្ទប់សណ្ឋាគារក៏ធ្លាក់ចុះដែរ គឺ ៤៥% នៅឆ្នាំ២០០៣ ធៀបនឹង ៥០% កាលពីមួយឆ្នាំមុន ។

ទោះបីមានភាពរីករវទាំងនៅក្នុងប្រទេស និងក្រៅប្រទេសក្តី ក៏ទេសចរក្នុងស្រុកបាន កើនឡើង ក្នុងនេះមកទស្សនាខេត្តសៀមរាបកើន ៤១% ដល់ ១៣២.៦៤៣នាក់ ។ ការធ្វើ ដំណើរតាមផ្លូវគោក កើនពី ៦៥.១១៩នាក់នៅឆ្នាំ២០០២ ដល់ ១០៤.៩៦០នាក់នៅឆ្នាំ២០០៣ រឺកើនឡើង ៦១% ។

ការស្ពឹកទ្រឹងផ្នែកពាណិជ្ជកម្ម ដែលមានទាំងសកម្មភាពលក់ដុំ និងលក់រាយ បានរួម ចំណែកធ្វើឱ្យធ្លាក់ចុះផ្នែកសេវាកម្ម ។ តំលៃបន្ថែមខាងផ្នែកសេវាកម្មធ្លាក់ចុះពី ៣៧១,៤លាន ដុល្លារនៅឆ្នាំ២០០២ មកត្រឹម ៣៦៧,៥លានដុល្លារនៅឆ្នាំ២០០៣ ។ ដោយសារកម្ពុជាបាន ពន្លឿនសេរីភាវូបនីយកម្មផ្នែកពាណិជ្ជកម្មអន្តរជាតិ, ថ្លៃទំនិញ និងសេវាក្នុងស្រុក ត្រូវតែបញ្ចុះ ដើម្បីប្រកួតប្រជែងនឹងទំនិញនាំចូល ដូច្នេះប្រាក់ចំនេញត្រូវតែថយចុះ[៦] ។ ម្យ៉ាងទៀត លក្ខខណ្ឌ ផលិតកម្មកម្ពុជា មិនអំណោយផលទេ ដោយសារកំរៃផ្សេងៗមានកំរិតខ្ពស់ (ជាពិសេសទាក់ទិន នឹងការដឹកជញ្ជូន) បច្ចេកវិទ្យាចាស់គំរិល និងជំនាញគ្រប់គ្រងទន់ខ្សោយ ។

## ១.៣ ផលិតផលក្នុងស្រុកសរុប ~ តាមប្រភេទតំរូវការ

### *១.៣.១ ការប្រើប្រាស់*

អត្រាកំណើនចំណាយប្រើប្រាស់ ដែលតំណាងឱ្យ ៨៧% នៃចំណាយជាតិសរុប បានកើនបន្តិច បន្តួចពី ៥,៦% នៅឆ្នាំ២០០២ ដល់ ៦% នៅឆ្នាំ២០០៣ ដោយសារកំណើនចំណាយប្រើប្រាស់ សាធារណៈជាសំខាន់ ។

---

៦ Kang, C (2002) ។

នៅឆ្នាំ២០០៣ ចំណាយប្រើប្រាស់សាធារណៈ សំរេចបាន ១០០% នៃផែនការចំណាយក្នុងច្បាប់ថវិកាឆ្នាំ២០០៣ ដោយឡើងដល់ ១.៧៥៨ពាន់លានរៀល (៤៤០,៣លានដុល្លារ) ។ ធៀបនឹងឆ្នាំ២០០២ ចំណាយប្រើប្រាស់សាធារណៈពិត កើន ១១% គឺខ្ពស់ជាងឆ្នាំមុនដែលមានត្រឹម ៩,៧% ។ ក្នុងចំនាយប្រើប្រាស់សាធារណៈសរុប មាន ៦១៤,៧ពាន់លានរៀល (១៥៤,២ លានដុល្លារ) ជាចំណាយលើបៀវត្សរ៍រដ្ឋបាលស៊ីវិលនិងការពារជាតិ និង ១.១៤៣,៤ពាន់លានរៀល (២៨៦,២លានដុល្លារ) ជាចំនាយមិនមែនបៀវត្សរ៍ដូចជា ប្រាក់ផ្ទេរផ្សេងៗខាងសង្គមកិច្ច និងសេដ្ឋកិច្ច ។ យោងតាមច្បាប់ថវិកាឆ្នាំ២០០៣ បៀវត្សរ៍សំរាប់រដ្ឋបាលស៊ីវិលនិងការពារជាតិ កើន ៣០% និង ៦,៧% រៀងគ្នា ។ កំណើនបៀវត្សរ៍ជាក់ស្តែងខាងរដ្ឋបាលស៊ីវិលមានត្រឹមតែ ២៦,៦% ចំណែកឯខាងការពារជាតិកើនលើសគំរិតគ្រោងទុកដល់ ៨,៣% ប៉ុន្តែគិតជាសរុប ចំនាយលើបៀវត្សរ៍បានធ្វើតាមផែនការកំណត់ ។

### *១.៣.២ វិនិយោគ*

ក្រោយពីបានកើនឡើងនៅឆ្នាំ២០០២ ចំណាយវិនិយោគរួមចុះវិញនៅឆ្នាំ២០០៣ អស់ ៧,៥% ដែលបណ្តាលពីការថយចុះទាំងវិនិយោគសាធារណៈ និងវិនិយោគឯកជន ។

គិតជាភាគរយនៃ ផសស វិនិយោគសាធារណៈធ្លាក់ចុះពី ៩,៨% នៅឆ្នាំ២០០២ ដល់ត្រឹម ៧,៨% នៅឆ្នាំ២០០៣ (សូមមើលក្រាហ្វិក១.២) ។ ការធ្លាក់ចុះយ៉ាងធំនៃចំណាយវិនិយោគសាធារណៈ មិនមែនមកពីគោលនយោបាយធ្វើផែនការនោះទេ ប៉ុន្តែមកពីការអនុវត្តន៍ថវិកា ។ មូលហេតុសំខាន់នៃការធ្លាក់ចុះនេះគឺ ការកាត់បន្ថយគំរោងនានាដែលផ្តល់ថវិកាដោយអន្តរជាតិ ហើយរឿងនេះជាប់ទាក់ទិននឹងការយឺតយ៉ាវក្នុងការបង្កើតរដ្ឋាភិបាលថ្មី ។

ដូចគ្នាដែរ នៅឆ្នាំ២០០៣ វិនិយោគឯកជនសរុបថយចុះអស់ ៣% ដល់ ៧៨៣លានដុល្លារ ។ ថ្វីបើវិនិយោគឯកជនក្នុងស្រុក កើនបាន ១,៥% ដល់ ៤១៤លានដុល្លារក្តី ក៏វិនិយោគផ្ទាល់ពីបរទេស (FDI) ធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរអស់ ២១% (៧៧លានដុល្លារ) ។ ជាទូទៅ FDI ប្រែប្រួលចុះឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ នៅឆ្នាំ២០០៣ វិស័យសេវាកម្ម និងកសិកម្ម បានជួប

និងការដកចេញយ៉ាងច្រើន។នូវ FDI ថ្មីៗ រីឯលំហូរ FDI មកក្នុងផ្នែកវាយនភណ្ឌ សំលៀកបំពាក់ និងស្បែកជើង ក៏ធ្លាក់ចុះអស់ ៣,៧% ដែរ ។

**ក្រាហ្វិក ១.២: ភាគរយវិនិយោគសាធារណៈក្នុង ផសស ( ថ្លៃថេរ ឆ្នាំ២០០០)**




*ប្រភព: ទិន្នន័យប្រមូលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង វិបសអ*

សមាជិកភាពរបស់កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) អាចជួយទាក់ទាញ FDI ប៉ុន្តែកម្ពុជាចាំបាច់ត្រូវធ្វើកំណែទំរង់ចំបង។ខាងច្បាប់ និងសេដ្ឋកិច្ច ដូច្នេះរឿងនេះប្រហែលមិនអាចទាក់ទាញបានក្នុងពេលឆាប់ៗទេ ។

### *១.៣.៣ ការនាំចេញ និងនាំចូល*

នៅឆ្នាំ២០០៣ តំរូវការផលិតផលកម្ពុជាកាន់តែច្រើនពីខាងក្រៅ បានជួយជំរុញដល់សេដ្ឋកិច្ច។ នៅឆ្នាំ២០០៣ តំលៃនៃការនាំចេញ កើន ១៦,៨% ដល់ ២.០៤៦លានដុល្លារ ធៀបនឹងកំណើនត្រឹម ១១,៥% នៅឆ្នាំ២០០២ ។ ក្នុងរយៈពេលដដែល ការនាំចេញផលិតផលកាត់ដេរ (មានទាំង វាយនភណ្ឌ និងស្បែកជើង) មាន ១.៣៩៥លានដុល្លារ រឺ ២០% ខ្ពស់ជាងឆ្នាំ២០០២ ។ រឿងនេះជាប់ទាក់ទិននឹងការបន្ថែមកូតាឱ្យកម្ពុជា ពីសំណាក់សហរដ្ឋអាមេរិកនៅឆ្នាំ២០០៣

ហើយសហរដ្ឋអាមេរិកនៅតែជាទីផ្សារនាំចេញដ៏ចំបងសំរាប់ផលិតផលកាត់ដេរកម្ពុជា ហើយបន្ទាប់មកគឺ សហភាពអ៊ឺរ៉ុប ។

ការនាំចូលសរុបរបស់កម្ពុជា កើន ១២,២% ដល់ ២.៩៩៦លានដុល្លារនៅឆ្នាំ២០០៣ គឺលឿនជាងឆ្នាំ២០០២ ដែលមានអត្រាកំណើនតែ ១១,៥% ។ ចំណាត់ថ្នាក់ទំនិញនាំចូល តាមលំដាប់សារៈសំខាន់ គឺ សំលៀកបំពាក់ ផលិតផលប្រេងឥន្ធនៈ ម្ហូបអាហារ/ភេសជ្ជៈ/ថ្នាំជក់ និង យានយន្ត។

យោងតាមនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលក្រណាត់នៅឆ្នាំ២០០៣ មាន ៥៩១,៤លានដុល្លារ រឺ ១៩% ច្រើនជាងឆ្នាំ២០០២ ។ ក្នុងពេលដដែល ការនាំចូលផលិតផលប្រេងឥន្ធនៈកើនដល់ ១៩១,៦លានដុល្លារ រឺ ២១,៦% ច្រើនជាងឆ្នាំ២០០២ ។ ម្យ៉ាងទៀត ការនាំចូល ម្ហូបអាហារ/ភេសជ្ជៈ/ថ្នាំជក់ ធ្លាក់ចុះ ១៤% ក្នុងឆ្នាំ២០០៣ ដល់ ១៤៤លានដុល្លារ ដែលនាំមុខដោយស្ករសនាំចូល ។

## ១.៤ ហិរញ្ញវត្ថុសាធារណៈ

នៅឆ្នាំ២០០៣ ហិរញ្ញវត្ថុសាធារណៈមានឱនភាពសរុប ១.១៦៤ពាន់លានរៀល គឺលើសច្រើនគួរកត់សំគាល់ពី ផែនការកំណត់ក្នុងច្បាប់ថវិកា[៧] ត្រឹម ៨០០ពាន់លានរៀល ។ គិតជាភាគរយនៃ ផសស ឱនភាពហិរញ្ញវត្ថុសាធារណៈសរុប ថយចុះពី ៨,៥% នៅឆ្នាំ២០០២ មកត្រឹម ៦,៦% នៅឆ្នាំ២០០៣ (សូមមើលក្រាហ្វិក១.៣) ។ បើគិតបញ្ចូលទាំងការកែតំរូវផ្សេងៗក្នុងចំនាយសាធារណៈផង ឱនភាពសរុបថយចុះមកត្រឹម ៩៩២ពាន់លានរៀល (២៤៩លានដុល្លារ) ប៉ុន្តែនៅតែធំលើសផែនការដល់ទៅ ២៤% ។

[៧] ផ្អែកតាមទិន្នន័យបានពីរបាយការណ៍ប្រចាំខែស្តីពី "ការអនុវត្តន៍ថវិកាជាតិ" ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នៅឆ្នាំ២០០៣ ការប្រមូលចំណូលសំរេចបាន ១.៧៦៥លានរៀល (៤៤៣លានដុល្លារ) ក្នុងនេះ ១.៧៣៣ពាន់លានរៀល (៤៣៥លានដុល្លារ)ជាចំណូលចរន្ត និងនៅសល់ប៉ុន្មានជាចំណូលជាមូលធន ។ ប្រាក់ចំណូលចរន្តពិត ប្រមូលបានតែ ៨៨% នៃផែនការក្នុងច្បាប់ថវិកាប៉ុណ្ណោះ ។ ចំនូលពន្ធប្រមូលបាន ៨៧% នៃផែនការ រីឯចំនូលមិនមែនពន្ធប្រមូលបាន ៩០% ។

**ក្រាហ្វិក ១.៣ ភាគរយឱនភាពសរុបក្នុង ផសស ពិត**




*ប្រភព: ទិន្នន័យទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង វិបសអ*

ទាក់ទិននឹងចំណូលពន្ធ ការប្រមូលពន្ធគយសំរេចបានតិចបំផុតត្រឹម ៧៧% នៃផែនការ រីឯអាករលើផលរបរបានច្រើនបំផុតដល់ ១៤២% នៃផែនការ ។ ពន្ធលើតំលៃបន្ថែម ដែលមានចំណែកធំបំផុត (៣៧%) ក្នុងចំណូលពន្ធ គឺប្រមូលបាន ៨៧% នៃផែនការ ។ យោងតាមតួលេខក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (សូមមើលក្រាហ្វិក ១.៤) ចំណូលពន្ធគយប្រេងឥន្ធនៈនាំចូលមានសរុប ៩៨ពាន់លានរៀល (៦៤% នៃផែនការ) នៅឆ្នាំ២០០៣ គឺតិចជាងឆ្នាំ២០០២ ដែលមានដល់ ១១៨ពាន់លានរៀល (៦៧% នៃផែនការ) ។ តាំងពីឆ្នាំ២០០០ មក ចំណូលពន្ធគយលើប្រេងឥន្ធនៈនាំចូល បានធ្លាក់ចុះជាបន្តបន្ទាប់ ធ្វើឱ្យគំលាតរវាង ពន្ធប្រមូលបានជាក់ស្តែង និងផែនការកំណត់ក្នុងច្បាប់ថវិកា កាន់តែរីកធំឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។

**ក្រាហ្វិក ១.៤: ពន្ធគយលើប្រេងឥន្ធនៈនាំចូល- ចំណូលពន្ធជាក់ស្តែង និងផែនការ (ពាន់លានរៀល)**




*ប្រភព: ទិន្នន័យទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ម្យ៉ាងទៀត ចំពោះទឹកប្រាក់ពន្ធគយប្រមូលបាន គឺហាក់ដូចមានការខុសគ្នាខ្លះរវាងតួលេខរាយការណ៍ឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និង តួលេខរបស់ទីចាត់ការគយ និងរដ្ឋាករ (សូមមើលក្រាហ្វិក ១.៥) សំរាប់ឆ្នាំភាគច្រើន ។ ការខុសគ្នានេះមានលក្ខណៈគួរចាប់អារម្មណ៍បំផុតសំរាប់ឆ្នាំ២០០៣ ពីព្រោះទីចាត់ការគយ និងរដ្ឋាករ បានកត់ត្រាថា ប្រមូលបាន ១៨៣ពាន់លានរៀលលើប្រេងឥន្ធនៈនាំចូល គឺ ៨៤ពាន់លានរៀល ច្រើនជាងតួលេខរាយការណ៍ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ក្រាហ្វិក ១.៥: ការប្រមូលពន្ធគយលើប្រេងឥន្ធនៈនាំចូល




*ប្រភព: ទិន្នន័យទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទីចាត់ការគយ និងរដ្ឋាករ*

ចំពោះប្រភពចំណូលមិនមែនពន្ធ ចំណូលប្រមូលបានពីការធ្វើអាជីវកម្មព្រៃឈើ គឺបានតិចតួចណាស់ត្រឹម ២១% នៃផែនការ ។ ចំណូលបានពី "ទេសចរណ៍ និងអាកាសចរស៊ីវិល" ស្ថិតក្នុងលំដាប់ទី២ ដោយប្រមូលបាន ៤៦% នៃផែនការ ។ ប៉ុន្តែ ចំណូលបានពីការលក់កូតាសំរេចបានរហូតដល់ ១៤៥ពាន់លានរៀល (៣៧លានដុល្លារ) រឺស្មើនឹង ១៦២% នៃផែនការ ។

នៅខាងផ្នែកចំណាយថវិកាវិញ រដ្ឋាភិបាលចំណាយអស់សរុប ២.៧៥៧ពាន់លានរៀល (៦៩២លានដុល្លារ) ក្នុងនេះមានទាំងការកែតំរូវផ្សេងៗលើខ្ទង់ចំណាយផង ។ ចំណាយចរន្តក្នុងឆ្នាំ២០០៣ សំរេចបាន ១.៧៥៨ពាន់លានរៀល (៤៤០លានដុល្លារ) រឺ ១០០% នៃផែនការ ។ ចំណាយសរុប (សូមមើលក្រាហ្វិក ១.៦) នេះបែងចែកជាចំណាយរដ្ឋបាលទូទៅ ៣៣៦ពាន់លានរៀល, ការពារជាតិ និងសន្តិសុខ ៤១១ពាន់លានរៀល, រដ្ឋបាលសង្គមកិច្ច ៦១៦ពាន់លានរៀល, និង រដ្ឋបាលសេដ្ឋកិច្ច ១៧១ពាន់លានរៀល ។

ខាងក្រោមនេះ គឺជាបញ្ជីចំណាយតាមក្រសួង និងចំណាយផ្សេងទៀត ដែលលើសផែនការ និងដែលបានរួមចំណែកដល់ឱនភាពថវិកាសរុបៈ

- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំណាយដល់ ៨២៧,៩% នៃផែនការ
- ក្រសួងមហាផ្ទៃ (រដ្ឋបាល) ១៧៧,១% នៃផែនការ
- ទីស្តីការគណៈរដ្ឋមន្ត្រី ១៤៩,២% នៃផែនការ
- ក្រសួងទេសចរណ៍ ១២៧,៤% នៃផែនការ
- ក្រសួងយុត្តិធម៌ ១១៥% នៃផែនការ
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ១០៨,៧% នៃផែនការ
- ឧបត្ថម្ភធនដល់ខេត្ត-ក្រុង ១០៤,៧% នៃផែនការ
- ក្រុមប្រឹក្សាធម្មនុញ្ញ ១០៤,៦% នៃផែនការ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១០៤,១% នៃផែនការ
- ក្រសួងធម្មការ និងសាសនា ១០២,៥% នៃផែនការ
- ក្រសួងព្រះបរមរាជវាំង ១០១,៤% នៃផែនការ

## ក្រាហ្វិក ១.៦: ការបែងចែកចំណាយចរន្តក្នុងឆ្នាំ២០០៣




*ប្រភព: ទិន្នន័យទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ម្យ៉ាងទៀត ចំណាយសំរាប់ក្រសួងអាទិភាពទាំង ៤ (អប់រំ យុវជន និងកីឡា, សុខាភិបាល, អភិវឌ្ឍន៍ជនបទ, និងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) សុទ្ធតែក្រោមផែនការទាំងអស់ :

- ក្រសួងអប់រំ យុវជន និងកីឡា ៩៣% នៃផែនការ
- ក្រសួងសុខាភិបាល ៨៥,៦% នៃផែនការ
- ក្រសួងអភិវឌ្ឍន៍ជនបទ ៨០,៥% នៃផែនការ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៩០% នៃផែនការ

ក្នុងពេលជាមួយគ្នា ចំណាយជាមូលធន ធំលើសផែនការក្នុងច្បាប់ថវិកា ដោយឡើងដល់ ១.១៧១លានរៀល (២៩៤លានដុល្លារ) ឬ ១១៣% នៃផែនការ ។ ចំណាយលើស

ផែនការនេះ គឺដោយសារមានគំរោងនានាដែលទទួលជំនួយហិរញ្ញវត្ថុពីក្រៅប្រទេស និងដែលមានចំនួនទឹកប្រាក់ដល់ ៨៣៧ពាន់លានរៀល (២១០លានដុល្លារ) ។

**ក្រាហ្វិក ១.៧: ១០ខេត្តមានឱនភាពធំជាងគេ (ពាន់លានដុល្លារ)**




*ប្រភព: ទិន្នន័យទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ក្នុងចំណោមខេត្តទាំងអស់ កំពង់ចាម មានឱនភាពខ្ពស់ជាងគេដល់ ៣៩,៩ពាន់លានរៀល (១០លានដុល្លារ) នៅឆ្នាំ២០០៣ (សូមមើលក្រាហ្វិក១.៧) ។ ចំណូលប្រមូលបានក្នុងខេត្តនេះ មានសរុប ០,២៤ពាន់លានរៀល ឯចំណាយរបស់ខេត្តមានដល់ ៤០,១ពាន់លានរៀល រឺ ១០,២% ច្រើនជាងឆ្នាំ២០០២ ។ ក្នុងខេត្តនេះ ក្រសួងអាទិភាពទាំង ៤ ចាយលុយអស់ច្រើនបំផុត ។ ក្រសួងអប់រំ យុវជន និងកីឡា ចាយលុយអស់ច្រើនជាងគេដល់ ២២,៤ពាន់លានរៀល (រឺ ៥៦% នៃចំនាយទាំងអស់ក្នុងខេត្ត) បន្ទាប់មកគឺក្រសួងសុខាភិបាលអស់ ៧,៤ពាន់លានរៀល (១៩% នៃចំនាយក្នុងខេត្ត) ។ ឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(០,៨១៣ពាន់លានរៀល) និងក្រសួងអភិវឌ្ឍន៍ជនបទ (០,៥៥៥ពាន់លានរៀល) ស្ថិតក្នុងចំណាត់ថ្នាក់ទី៥ និងទី៦ ។

## ១.៥ រូបិយវត្ថុ និងអត្រាថ្លៃ

### *១.៥.១ ការផ្គត់ផ្គង់រូបិយវត្ថុ*

បន្ទាប់ពីភាពធូរទូលាយក្នុងការផ្គត់ផ្គង់រូបិយវត្ថុនៅឆ្នាំ២០០២ ធនាគារជាតិនៃកម្ពុជា (NBC) បានអនុវត្តគោលនយោបាយតឹងរ៉ឹងជាងមុននៅឆ្នាំ២០០៣ ។ ការផ្គត់ផ្គង់ប្រាក់រៀល ដែលមានប្រាក់រៀលនៅក្រៅធនាគារ និងប្រាក់រៀលផ្ញើនៅធនាគារ កើន ១៥% ដល់ ១.០១៩ពាន់លានរៀលនៅខែធ្នូ ២០០៣ ធៀបនឹងកំណើន ៣៣.៥% នៅឆ្នាំ២០០២ ។ ទន្ទឹមនេះ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសដែលមានចំណែកធំជាងគេ នៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុនៅកម្ពុជា កើនឡើង ១៤% ដល់ ៥៨០លានដុល្លារ នៅដំណាច់ឆ្នាំ២០០៣ គឺតិចជាងឆ្នាំ២០០២ ដែលមានកំណើន ២៩.៦% ។ រូបិយវត្ថុទូទៅ (M2) ដែលមានទាំង ប្រាក់រៀល និង ប្រាក់បញ្ញើជារូបិយវត្ថុបរទេស (គិតចេញជារៀលវិញ) កើន ១៥% ដល់ ៣.៣២៩ពាន់លានរៀល (៨៣៦លានដុល្លារ) នៅដំណាច់ឆ្នាំ២០០៣ គឺតិចជាងកាលពីមួយឆ្នាំមុនដែលមានកំណើនដល់ ៣១% ។

ការថយចុះការផ្គត់ផ្គង់ប្រាក់រៀល បណ្តាលពីការកាត់បន្ថយការចេញផ្សាយរូបិយវត្ថុ គឺពីខែធ្នូ ២០០២ ដល់ ធ្នូ ២០០៣ ធនាគារជាតិនៃកម្ពុជា បានចេញផ្សាយតែ ១៣២ពាន់លានរៀល ដោយបង្កើតបាននូវ ស្តុកប្រាក់រៀលសរុបចំនួន ៩៧៧ពាន់លានរៀល ។ បើធៀបនឹងឆ្នាំ២០០២ NBCបានបង្រួមចុះអស់ ២៩% នូវលំហូររូបិយវត្ថុ ។ ដូច្នេះប្រាក់រៀលធ្វើចរាចរ (នៅខាងក្រៅធនាគារ) កើន ១៨,៥% ដល់ ៩០៨ពាន់លានរៀលនៅដំណាច់ឆ្នាំ២០០៣ គឺតិចជាងឆ្នាំ២០០២ ដែលមានកំណើន ៣៣% ។

ការរឹតបន្តឹងការផ្គត់ផ្គង់រូបិយវត្ថុ ប្រហែលធ្វើតាមរយៈការកាត់បន្ថយ ទ្រព្យសកម្មបរទេស និង/ឬ ទ្រព្យសកម្មជាប់លាប់របស់ NBC[៨] ។ យោងតាមគណនីផ្សេងៗរបស់ NBC

[៨] ទិន្នន័យបានពីធនាគារជាតិនៃកម្ពុជា: របាយការណ៍ប្រចាំខែ ។

ទ្រព្យសកម្មបរទេស នៅខែធ្នូ ២០០៣ កើន ៧% បើធៀបនឹងឆ្នាំ២០០២ ដែលកាលណោះមានកំណើនដល់ ៣១% ។ ក្នុងពេលជាមួយគ្នា ទ្រព្យសកម្មបរទេសរបស់ NBC ថយចុះអស់ ១១% ពី ១៤១ពាន់លានរៀល មកនៅត្រឹម ១២៦ពាន់លានរៀល ។

ការថយចុះរូបិយវត្ថុទូទៅ ក៏បណ្តាលផងដែរពីការថយកំណើនប្រាក់បញ្ញើជារូបិយវត្ថុបរទេស ដែលតំណាងឱ្យ ៦៩% នៃរូបិយវត្ថុទូទៅរបស់កម្ពុជា ។ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើនយឺតៗត្រឹម ១៤% ដល់ ៥៨០លានដុល្លារនៅខែធ្នូ ២០០៣ ធៀបនឹងកំណើន ៣០% នៅឆ្នាំមុន ។ ការថយកំណើនប្រាក់បញ្ញើជារូបិយវត្ថុបរទេសនេះ បណ្តាលមកពីការថយចុះចំនួនទេសចរបរទេស និង ការធ្លាក់ចុះនៃវិនិយោគផ្ទាល់ពីបរទេស (FDI) ។

### *១.៥.២ អត្រាការប្រាក់*

បន្ទាប់ពីការកាត់បន្ថយជាបណ្តើរៗចាប់តាំងពីឆ្នាំ១៩៩៧ មក នូវអត្រាការប្រាក់ចំពោះការឱ្យខ្ចីប្រាក់ជារូបិយវត្ថុបរទេស, ធនាគារនានានៅកម្ពុជា បានតម្លើងអត្រាការប្រាក់ដល់ ១៨.៥% នៅឆ្នាំ២០០៣ ធៀបនឹងអត្រា ១៨.៤% នៅឆ្នាំ១៩៩៧ ។ កម្ពុជានៅតែបន្តរក្សាអត្រាការប្រាក់ ឱ្យនៅខ្ពស់ជាងថៃ និងវៀតណាមដដែល ។ ធនាគារនានានៅថៃ យកការប្រាក់ទាបបំផុតត្រឹម ៥.៩៤% នៅឆ្នាំ២០០៣ (សូមមើលក្រាហ្វិក១.៨) ។

## ក្រាហ្វិក ១.៨: អត្រាឱ្យខ្ចីប្រាក់ចារីកនៅកម្ពុជា ថៃ និងវៀតណាម




*ប្រភព: ធនាគារជាតិនៃកម្ពុជា, មូលនិធិរូបិយវត្ថុអន្តរជាតិ*

ក្នុងបរិបទសេដ្ឋកិច្ចមានដុល្លារូបនីយកម្ម អត្រាការប្រាក់ខ្ពស់ ឆ្លុះបញ្ចាំងជាសំខាន់ពីកំណើនយឺតនៃប្រាក់បញ្ញើជារូបិយវត្ថុបរទេស (ភាគច្រើនដុល្លារសហរដ្ឋអាមេរិក) ។ នៅចុងឆ្នាំ២០០៣ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសថយកំណើនមកត្រឹម ១៤% ធៀបនឹងកំណើន ២៩% នៅចុងឆ្នាំ២០០២។ ទោះបីគ្មានទិន្នន័យច្បាស់លាស់ ស្តីពីបរិមាណរូបិយវត្ថុបរទេសធ្វើចរាចរនៅក្នុងសេដ្ឋកិច្ចកម្ពុជាក្តី ក៏ការធ្លាក់ចុះបរិមាណនេះ គឺអាចជាអាំងឌីកាទ័រដ៏ល្អមួយនៃការថយចុះទ្រព្យសកម្មបរទេស ដែលប្រហែលជាប់ទាក់ទិននឹងកត្តាដូចតទៅ:

- *វិនិយោគផ្ទាល់ពីបរទេស (FDI) :* តាំងពីឆ្នាំ២០០១ មក FDI ធ្លាក់ចុះកាន់តែលឿនឡើងៗខ្លាំង ជាពិសេសនៅឆ្នាំ២០០២-២០០៣ វាធ្លាក់ចុះ ២១% គឺលឿនជាងនៅឆ្នាំ២០០១-២០០២ ដែលកាលនោះធ្លាក់ចុះតែ ១៣% ។
- *គណនេយ្យចរន្ត:* ឱនភាពគណនេយ្យចរន្តកម្ពុជាកើនយ៉ាងខ្លាំងនៅឆ្នាំ២០០៣ ដល់ ១៣១លានដុល្លារ ធៀបនឹងឆ្នាំ២០០២ ដែលមានតែ ២៤លានដុល្លារ ថ្វីបើការផ្ទេរ

ប្រាក់ជាផ្លូវការផ្សេងៗបានកើនតែ ៣២,៩% ក្តី ។ លទ្ធផលដ៏ប្រសើរនៃវិស័យនាំចេញ បានអនុញ្ញាតឱ្យការនាំចូលទំនិញកើនឡើងបាន ។

- *ជំនួយពីក្រៅប្រទេស:* កំចីផ្លូវការសំរាប់ផ្តល់ហិរញ្ញប្បទានដល់ឱនភាពពាណិជ្ជកម្មឡើងចុះមិនទៀងទាត់ទេក្នុងឆ្នាំកន្លងទៅ ។ ធៀបនឹងឆ្នាំ២០០២ ដែលកាលណោះកំចីផ្លូវការកើនខ្លាំងបំផុតដល់ ៥៧,៨% រឺ ១៥០លានដុល្លារ, កំចីផ្លូវការនៅឆ្នាំ ២០០៣ កើនបានតែ ៤,៣% ប៉ុណ្ណោះ។ ម្យ៉ាងទៀត ជំនួយពីក្រៅប្រទេសសំរាប់ទាំងការទ្រទ្រង់ថវិកា និងចំណាយជាមូលធន ធ្លាក់ចុះខ្លាំងនៅឆ្នាំ២០០៣ ដល់ ២១,៩% និង ២៥,៣% រៀងគ្នា ។ ការថយចុះជំនួយបរទេស អាចបណ្តាលមកពីការយឺតយ៉ាវក្នុងការបង្កើតរដ្ឋាភិបាលថ្មី បន្ទាប់ពីការបោះឆ្នោតកំរិតជាតិនៅខែកក្កដា ២០០៣ ។

ដោយសារសាច់ប្រាក់ទំនេរ (liquidity) របស់កម្ពុជា មានប្រភពសំខាន់មកពីបរទេស ដូច្នេះវាច្បាស់ណាស់ដែលអាជ្ញាធរខាងរូបិយវត្ថុ មានឥទ្ធិពលតែតិចតួចទៅលើអត្រាការប្រាក់ ដែលមានសារៈសំខាន់បំផុតដើម្បីជំរុញវិនិយោគ ជាពិសេសវិនិយោគក្នុងស្រុក ។

### *១.៥.៣ អតិផរណា*

ថ្លៃទំនិញប្រើប្រាស់នៅកម្ពុជាកើន ១,១% នៅឆ្នាំ២០០៣ គឺតិចជាងឆ្នាំ២០០២ ដែលមានកំណើន ៣,៣% ។ ការថយចុះនេះ បណ្តាលពីមកពីការថយកំនើនថ្លៃឈ្នួលផ្ទះ និងថ្លៃផ្គត់ផ្គង់សាធារណៈ (utility costs) ដែលកើនបាន ០,៨% នៅឆ្នាំ២០០៣ ធៀបនឹង ៧,២% នៅឆ្នាំ២០០២ ។ ចំណាយលើការថែទាំសុខភាព ក៏ថយចុះដែរ ។ ពីខែមករា ២០០៣ ដល់ មករា ២០០៤ ថ្លៃថែទាំសុខភាពថយចុះ ១,៩% ។ ថ្លៃម្ហូបអាហារ ដែលតំណាងឱ្យមួយភាគធំនៃកន្ត្រកទំនិញប្រើប្រាស់ (consumption basket) ក៏កើនយឺតជាងមុនដែរនៅឆ្នាំ២០០៣ ។

ផ្ទុយទៅវិញ ចំណាយដឹកជញ្ជូន និងទូរគមនាគមន៍ កើនយ៉ាងខ្លាំងដល់ ៤,៩% នៅឆ្នាំ ២០០៣ ( ធៀបនឹង ០,៣% នៅឆ្នាំ២០០២) ដែលនាំមុខដោយកំណើនថ្លៃប្រេងសាំង ម៉ាស៊ូត ថ្លៃសំបុត្ររថយន្តក្រុង ។ ដោយសារផលិតផលប្រេងឥន្ធនៈ ជាផលិតផលស្នូលសំរាប់ពាណិជ្ជកម្ម

និងការប្រើប្រាស់តាមគ្រួសារឯកជន ដូច្នេះការប្រែប្រួលថ្លៃប្រេងសាំង និងម៉ាស៊ូត ពិតជាប៉ះពាល់ដល់កំរិតថ្លៃទូទៅ ។ កំណើនអតិផរណាថ្មីៗនៅឆ្នាំ២០០៤ គឺបណ្តាលពីការបន្តឡើងថ្លៃប្រេងឥន្ធនៈ ។

### *១.៥.៤ អត្រាប្តូរប្រាក់*

នៅឆ្នាំ២០០៣ ប្រាក់រៀលចុះថ្លៃ ២% ទល់នឹងដុល្លារUS ដោយប្តូរបាន ៣.៩៩៨រៀល/ដុល្លារ ធៀបនឹង ៣.៩១៨រៀល/ដុល្លារនៅឆ្នាំ២០០២ ។ ប្រាក់រៀលក៏ចុះថ្លៃ ៥.៤% ទល់នឹងប្រាក់បាតថៃ ពីកំរិត ៩១,២រៀល/បាតនៅឆ្នាំ២០០២ ចុះមកដល់ ៩៦,២រៀល/បាតនៅឆ្នាំ២០០៣ ។

ការធ្លាក់ថ្លៃប្រាក់រៀលទាក់ទិននឹងកត្តាបី គឺ ១) ការថយចុះលំហូរចូលដុល្លារ ដោយសារការធ្លាក់ចុះខាងផ្នែកឧស្សាហកម្មទេសចរណ៍ និងវិនិយោគផ្ទាល់ពីបរទេស, ២) កំណើនតំរូវការរូបិយវត្ថុបរទេស ជាពិសេសសំរាប់ការនាំចូលទំនិញ និង ៣) ស្ថានការណ៍នយោបាយមិនច្បាស់លាស់ នៅជុំវិញការបោះឆ្នោតកំរិតជាតិនៅខែកក្កដា ២០០៣ ជាពិសេសការទាល់ច្រកយ៉ាងយូរនៅក្រោយពេលបោះឆ្នោត ។

## ១.៦ ជញ្ជីងទូទាត់

### *១.៦.១ គណនេយ្យចរន្ត*

គណនេយ្យចរន្តរបស់កម្ពុជា (រួមទាំងការផ្ទេរជាផ្លូវការ) កាន់តែយ៉ាប់យ៉ឺនឡើង ដោយមានឱនភាពកើនដល់ ១៣១លានដុល្លារនៅឆ្នាំ២០០៣ ធៀបនឹងឱនភាពត្រឹម ២៤លានដុល្លារនៅឆ្នាំ២០០២ ។ តុល្យភាពជញ្ជីងពាណិជ្ជកម្ម បានកែលំអឡើង ដោយឱនភាពថយចុះពី ៥៦៣លានដុល្លារឆ្នាំ២០០២ មកត្រឹម ៥៤៩,៣លានដុល្លារនៅឆ្នាំ២០០៣ ហើយការនាំចេញមានលទ្ធផលល្អ ។ ទន្ទឹមនេះ គណនីសេវាកម្មមានអតិរេកថយចុះបន្តិចដល់ ១៣២លានដុល្លារ ធៀបនឹងអតិរេក ២២៥លានដុល្លារនៅឆ្នាំ២០០២ ដោយសារការធ្លាក់ចុះឧស្សាហកម្ម ទេសចរណ៍ដូចបានលើករួចហើយ ។ ប្រាក់ចំណូលរបស់អ្នកផ្តល់សេវាកម្មក្នុងស្រុក ថយចុះដល់ ៥២៦លានដុល្លារឆ្នាំ២០០៣ រឺថយចុះ ១២% ធៀបនឹងកាលពីមួយឆ្នាំមុន ។ ផ្ទុយទៅវិញ ការប្រើប្រាស់

របស់កម្ពុជានូវសេវាកម្មបរទេស នៅឆ្នាំ២០០៣ មានរហូតដល់ ៣៩៤លានដុល្លារ គឺច្រើនជាងឆ្នាំ២០០២ ដែលមានត្រឹមតែ ៣៧៤លានដុល្លារ ។

គណនីប្រាក់ចំណូល (ដែលកត់ត្រានូវប្រាក់ទទួលបានពីជនកម្ពុជាដែលធ្វើការនៅក្រៅប្រទេស និងការបើកប្រាក់ឱ្យជនបរទេសដែលធ្វើការនៅកម្ពុជា រួមទាំងការទូទាត់ការប្រាក់ផង) មានឱនភាពកើនដល់ ១៨៣លានដុល្លារនៅឆ្នាំ២០០៣ ធៀបនឹងឱនភាពត្រឹម ៣៩លានដុល្លារនៅឆ្នាំ២០០២។ យោងតាម NBCកំនើនឱនភាពយ៉ាងខ្លាំងនេះគឺជំរុញឡើងដោយ ការស្ទុះកើនការទូទាត់ប្រាក់ចំណូលពីត្រឹម ៦៥លានដុល្លារឆ្នាំ២០០២ ដល់ ២២៧លានដុល្លារនៅឆ្នាំ២០០៣ ដែលក្នុងនេះមាន ១៩៦លានដុល្លារជាប្រាក់ទូទាត់ឱ្យជនបរទេសដែលធ្វើការនៅកម្ពុជា ។

សមតុល្យនៃការផ្ទេរប្រាក់ចរន្ត (ដែលមានទាំង ប្រាក់ផ្ញើចេញ និងជំនួយជាឯកជន និងផ្លូវការ) មាននិន្នាការដូចធ្លាប់បានពិនិត្យឃើញចាប់តាំងពីឆ្នាំ១៩៩៣ មក។ ការផ្ទេរសរុបកើន ៣៣% ដល់ ៤៦៩លានដុល្លារនៅឆ្នាំ២០០៣ គឺលឿនជាងឆ្នាំ២០០២ (កើន២.៦%) ក្នុងនេះ ៣០៦.៥លានដុល្លារជាការផ្ទេរផ្លូវការសុទ្ធ និង ១៦២.៨លានដុល្លារជាការផ្ទេរឯកជនសុទ្ធ ។

អតិរេកយ៉ាងធំក្នុងគណនីផ្ទេរប្រាក់ចរន្ត គឺមិនទាន់គ្រប់គ្រាន់ទេដើម្បីបំពេញឱនភាពក្នុងជញ្ជីងពាណិជ្ជកម្ម និងគណនីចំណូល និងដើម្បីប៉ះប៉ូវការធ្លាក់ចុះក្នុងគណនីសេវាកម្ម ។ រឿងនេះបណ្តាលឱ្យគណនីចរន្តមានឱនភាពឡើងដល់ ១៣១លានដុល្លារ ។

### *១.៦.២ គណនីហិរញ្ញវត្ថុ*

ដោយសារ FDI មាននិន្នាការធ្លាក់ចុះយ៉ាងយូរតាំងពីឆ្នាំ២០០១ មក គណនីហិរញ្ញវត្ថុរបស់កម្ពុជានៅតែឃើញមានកំចីផ្លូវការយ៉ាងច្រើន។ (ក្រៅពីកំចីពី IMF) ។ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ឱនភាពគណនេយ្យចរន្ត នៅឆ្នាំ២០០៣ កម្ពុជាទទួលប្រាក់កំចីផ្លូវការ ១៥៦លានដុល្លារ រឺ ៤% ច្រើនជាងឆ្នាំ២០០២ ។ ទន្ទឹមគ្នានេះ កម្ពុជាត្រូវសងគេវិញ ៨លានដុល្លារ ។ លំហូរចូលមូលធនសុទ្ធ ក្នុងទំរង់ជាកំចីផ្លូវការ មាន ១៤៩លានដុល្លារ រឺ ៦% ច្រើនជាងឆ្នាំ២០០២ ។

វិនិយោគមិនផ្លូវការសុទ្ធ (លំហូរចូល និងលំហូរចេញនូវមូលធន) តំណាងឱ្យតែ ១៣% គណនីហិរញ្ញវត្ថុនៅឆ្នាំ២០០៣ ។ រីឯ FDI ធ្លាក់ចុះពី ៩៨លានដុល្លារនៅឆ្នាំ២០០២ មកត្រឹម ប្រហែល ៧៧លានដុល្លារ ហើយវិនិយោគឯកជនផ្សេងទៀត មានលំហូរចេញសុទ្ធប៉ាន់ស្មាន ប្រហែល ៥៤លានដុល្លារ។ សរុបមក គណនីហិរញ្ញវត្ថុរបស់កម្ពុជា រួមទាំងលំហូរមូលធនផ្លូវការ និងមិនផ្លូវការ កើនដល់ ១៧២លានដុល្លារនៅឆ្នាំ២០០៣ រឺ ៤១% ខ្ពស់ជាងឆ្នាំ២០០២ ។

អតិរេកជញ្ជីងទូទាត់សរុបរបស់កម្ពុជានៅឆ្នាំ២០០៣ ថយចុះមកត្រឹម ៣១លានដុល្លារ ដែលកាលពីឆ្នាំ២០០២ មាន ១៧២លានដុល្លារ ។ បើគិតទាំងការធ្វើហិរញ្ញប្បទានពិសេស និង ការប្រើឥណទាន IMFផង ធនបំរុងរបស់ NBC ធ្លាក់ចុះពី ១៨៧លានដុល្លារនៅឆ្នាំ២០០២ មកត្រឹម ៤១លានដុល្លារនៅឆ្នាំ២០០៣ ។

## ១.៧ សន្និដ្ឋាន និងការព្យាករណ៍ពីអនាគត

នៅឆ្នាំ២០០៣ សេដ្ឋកិច្ចកម្ពុជា ថយកំណើនអស់បីឆ្នាំជាប់គ្នា។ ការស្ទុះកំណើនគួរឱ្យកត់សំគាល់ ក្នុងឧស្សាហកម្មកាត់ដេរ រួមផ្សំនឹងការរីបឡើងវិញយ៉ាងច្រើននៅក្នុងផលិតកម្មផលដំណាំ (ដោយសាររដូវកាលល្អ និងមានភ្លៀងធ្លាក់ទាន់ពេល) ត្រូវបានកាត់កងអស់វិញដោយសារ លទ្ធផលមិនល្អក្នុងវិស័យផ្សេងទៀត ។

កំណើនកូតាដែលផ្តល់ឱ្យភាគច្រើនដោយសហរដ្ឋអាមេរិក បានជំរុញលទ្ធផលល្អក្នុង ឧស្សាហកម្មកាត់ដេរ ។ ប៉ុន្តែរឿងនេះមិនបានបង្ហាញនូវកំណើនភាពប្រកួតប្រជែងរបស់ ឧស្សាហកម្មកាត់ដេរកម្ពុជា នៅក្នុងទីផ្សារពិភពលោកនោះទេ ។ កង្វះខាតឧស្សាហកម្មគាំទ្រ និងទំនាក់ទំនងទៅដើមខ្សែ និងតាមខ្សែផ្តេក នៅតែជាឧបសគ្គចំបងមួយ ។ ការលំបាកខ្លះបាន ធូរស្រាលហើយ ដូចជា ការកាត់បន្ថយសំណុំឯកសារ និងរយៈពេលចាត់ចែងឯកសារ ក្រោយពី មានសំណើនៅក្នុងវេទិកាជំនួបរវាងវិស័យឯកជន-សាធារណៈ និងការផ្លាស់ប្តូរនៅក្នុងគោល នយោបាយរបស់រដ្ឋាភិបាល ។ ការផុតកំណត់នៃប្រព័ន្ធកូតា ត្រូវបានគេចាត់ទុកជាទូទៅថា ជាការប្រែប្រួលមិនល្អមួយសំរាប់ឧស្សាហកម្មកាត់ដេរកម្ពុជា ។ តំរូវការជាបន្ទាន់នេះគឺ គោល នយោបាយនានាសំរាប់កែលំអបរិស្ថានសេដ្ឋកិច្ច សមត្ថភាពប្រកួតប្រជែងរបស់ឧស្សាហកម្មក្នុង

ស្រុក ដើម្បីកាត់បន្ថយចំណាយផលិតកម្ម និងប្រតិបត្តិការ, តឹរឹមរដ្ឋបាលសាធារណៈឱ្យល្អ និងកសាងឧស្សាហកម្មគាំទ្រផ្សេងៗ ។ ថ្វីបើ ការប្រមើលមើលបានបង្ហាញពីស្ថានភាពមិនសូវល្អក្នុងរយៈពេលខ្លីក្តី ក៏អាចមានឱកាសដ៏ល្អៗជាច្រើនដែលអាចផុសឡើង ដូចជា លទ្ធភាពកាន់តែធំ ដើម្បីចូលទីផ្សារអឺរ៉ុប នៅពេលដែលច្បាប់បញ្ញត្តិអំពីប្រភពដើមនៃទំនិញត្រូវបានបន្ធូរបន្ថយ, ការប្រើប្រាស់ស្តង់ដារពលកម្មកាន់តែខ្ពស់ និងការទទួលខុសត្រូវខាងសង្គមកិច្ចរបស់ក្រុមហ៊ុន ដើម្បីប្រមូលយកទីផ្សារពិសេសៗ (niche markets) សំរាប់កម្ពុជា ។ គេគួរបង្កើតក្រុមការងារមួយសំរាប់ពិនិត្យដោយប្រុងប្រយ័ត្ន និងជាលក្ខណៈយុទ្ធសាស្ត្រលើបញ្ហាទាំងអស់នេះ និងឱកាសល្អៗឯទៀត ដើម្បីដោះស្រាយនូវរយៈពេលដ៏ពិបាក និងចៀសមិនផុតមួយនាអនាគត ។

គ្រប់វិស័យសំខាន់ៗទាំងអស់ដូចជា ទេសចរណ៍ នេសាទ និងការចិញ្ចឹមមាន់-ទា បានធ្លាក់ចុះក្នុងឆ្នាំ២០០៣ ដោយបង្ហាញពីភាពផុយស្រួយនៃសេដ្ឋកិច្ច ។ ឧទាហរណ៍ ក្នុងពេលថ្មីៗនេះផ្នែកទេសចរណ៍ទទួលផលប៉ះពាល់មិនល្អអំពីកុប្បកម្មប្រឆាំងថៃ ខែមករា ២០០៣ និងការផ្ទុះជំងឺ SARS ។ ដូច្នេះ ការពឹងផ្អែកហួសហេតុលើវិស័យទេសចរណ៍ ពិតជាមានគ្រោះថ្នាក់ ។

ផលិតកម្មត្រី ដែលមានចំណែក ៧,៨% ក្នុង ផសស នៅឆ្នាំ២០០៣ បានធ្លាក់ចុះ ដែលប្រហែលមកពី កំពស់ទឹកចុះទាបដោយសារទំនប់ទឹកនៅចិន និងវៀតណាម ការកាប់បំផ្លាញព្រៃឈើនៅកម្ពុជា និងការលុបច្បាប់គ្រប់គ្រងឡូត៍នេសាទ ។ មធ្យោបាយមួយដើម្បីទប់ស្កាត់ឥទ្ធិពលអវិជ្ជមានទាំងនេះ គឺលើកទឹកចិត្តការចិញ្ចឹមត្រីដែលសព្វថ្ងៃមិនទាន់បានធ្វើអាជីវកម្មយ៉ាងពេញលេញទេ ។ ផលិតកម្មត្រីមានតួនាទីសំខាន់ណាស់ ព្រោះវាជាប្រភពប្រូតេអ៊ីនក្នុងរបបអាហារប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា និងវាជួយធ្វើឱ្យថ្លៃម្ហូបអាហារមានស្ថិរភាព ។

រឿងសំខាន់មួយទៀត គឺត្រូវធ្វើចំរុះកម្មប្រភពកំណើន ដោយម្យ៉ាងធ្វើការអភិវឌ្ឍន៍កសិកម្ម និងជនបទ និងម្យ៉ាងទៀត លើកទឹកចិត្តដល់វិនិយោគក្នុងស្រុកទាំងឯកជន និងសាធារណៈ ។ ដើម្បីទាញផលចំណេញពីសក្តានុពលទាំងនេះ កម្ពុជាត្រូវមានរចនាសម្ព័ន្ធលើកទឹកចិត្តយ៉ាងត្រឹមត្រូវ និងស្ថាប័នដ៏សមស្របនានា ។ គេអាចជជែកវែកញែកថា កម្ពុជាបានឆ្លងកាត់រួចហើយនូវរយៈពេលប្រមូលទុនពីដំបូង ហើយបញ្ហាប្រឈមនៅពេលនេះគឺត្រូវជំរុញ

និងលើកទឹកចិត្តដល់ការប្រើប្រាស់ទុនទាំងនេះ សំរាប់ធ្វើវិនិយោគមានផលិតភាព។ ដើម្បីសំរេចរឿងនេះបាន ត្រូវមានការផុសឡើងនូវស្រទាប់អ្នកមូលធននិយមក្នុងស្រុកពិតៗ ដែលខុសគ្នាស្រឡះពីពួកអ្នកដែលស្វែងរកតែថ្លៃឈ្នួល ។

សំរាប់បញ្ហាខាងលើនេះ អាចមានលក្ខខណ្ឌត្រូវបំពេញជាមុនមួយ គឺប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ មួយដែលដំណើរការល្អ និងមានប្រសិទ្ធភាព ។ អត្រាការប្រាក់ខ្ពស់ ក្របខ័ណ្ឌច្បាប់ទន់ខ្សោយដុល្លារូបនីយកម្មកំរិតខ្ពស់ក្នុងសេដ្ឋកិច្ច អាចបន្ថយបង្អាក់ទឹកចិត្តវិនិយោគិន និង បង្កឧបសគ្គដល់គោលនយោបាយសាធារណៈ ជាពិសេសគោលនយោបាយខាងរូបិយវត្ថុ និង ខាងអត្រាការប្រាក់ ។

# ឯកសារយោង


Cambodia Development Resource Institute (2003), *Monthly Flash Report* (May 2003)

International Monetary Fund (2003), *International Financial Statistics 2003*

Kang, C. (2002): “The Development of Micro Finance in Cambodia,” *Cambodia Development Review*, Vol. 6, No. 3, (Phnom Penh: CDRI) pp. 1-3

Kang, C. (2001): *Prerequisites for Successful De-Dollarisation in Cambodia: A Monetary-Keynesian Solution* (in German), (Germany: Lang, Peter, GmbH, Europaischer Verlag de Wissenschaft)

Kang, C. & S. Chan (2003), *Cambodia's Annual Economic Review* (Phnom Penh: CDRI)

Ministry of Agriculture, Forestry and Fisheries (2003a), *Agricultural Statistics 2001–2002*

Ministry of Agriculture, Forestry and Fisheries (2003b), *Official Report on Agriculture, Forestry and Fisheries 2002–2003*

Ministry of Agriculture, Forestry and Fisheries (2004): *Agricultural Statistics 2003-2004*

Ministry of Commerce (2002), *Cambodia—Integration and Competitiveness Study*

Ministry of Economy and Finance, monthly reports on “State Budget Implementation”

Ministry of Tourism (2003), *Tourism Statistical Report—Year Book 2003*

National Bank of Cambodia, Monthly Report

Sok, H. & S. Acharya (2002), Cambodia's Annual Economic Review—2002 (Phnom Penh: CDRI)

# ផ្នែកទី ២
# របាយអត្ថប្រយោជន៍នៃប័ណ្ណសំគាល់ កម្មសិទ្ធិដីធ្លីៈ វិនិយោគខាងកសិកម្ម និងឥណទានស្ថាប័ន[៩]

*ដោយ* Brett Barllard *និង សូ សុវណ្ណារិទ្ធិ*

## ២.១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានចាប់ផ្តើមអនុវត្តរបៀបវារៈកំណែទំរង់មួយដែលសំដៅធ្វើឱ្យបានសំរេចនូវ ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចមានចីរភាព ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អ ។ RGCក៏ដូចជាអ្នកផ្តល់ជំនួយអន្តរជាតិ បានទទួលស្គាល់ថា សុវត្ថិភាពនៃការកាន់កាប់ដីធ្លី ទាំងនៅតំបន់ជនបទ និងទីក្រុង គឺជាគន្លឹះដ៏សំខាន់មួយដើម្បីសំរេចទិសដៅនេះ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) កំពុងអនុវត្តគំរោងរដ្ឋបាល និងគ្រប់គ្រងដីធ្លី (LMAP) ដើម្បីពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី និងប្រព័ន្ធគ្រប់គ្រងដីធ្លី ។ ជាមួយគ្នា

---

[៩] ផ្នែកនេះ ផ្អែកលើរបាយការណ៍ពង្រាងរបស់ វបសអ ទៅឱ្យ MLMUPC ក្រោមចំណងជើងថា "កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជាៈ របាយការណ៍ចុងក្រោយនៃគំរោងអង្កេតជាមូលដ្ឋានៈ ជនបទៈ ដំណាក់កាលទី ១ ( Brett Barllard and So. forthcoming) ។

និងសកម្មភាពជាច្រើនទៀត LMAP កំពុងអនុវត្តកម្មវិធីផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លីជាប្រព័ន្ធមួយ ដែលក្នុងនេះមានការចេញនូវ ១លានប័ណ្ណប្លង់ដីក្នុងរយៈពេល ៥ឆ្នាំដំបូង (២០០៣-២០០៧) ។ នៅខាងជនបទ ផលចំណេញរំពឹងទុក មានជាអាទិ៍ ក) កំណើនសមត្ថភាព និងការលើកទឹកចិត្តដល់កសិករ ក្នុងការធ្វើវិនិយោគលើផលិតភាពផ្នែកកសិកម្ម, ខ) កំណើនវិនិយោគលើផ្នែកសហគ្រាសធុនតូច និងមធ្យម (SMEs) និង គ) កំណើនលទ្ធភាពទទួលបានឥណទានស្ថាប័ន តាមរយៈការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីជារបស់ធានាកំចី ។

ហេតុផលបញ្ជាក់គាំទ្រដល់ការរំពឹងទុកទាំងនោះ គឺឃើញមានទាំងក្នុងឯកសារផ្នែកទ្រឹស្តី និងឯកសារស្រាវជ្រាវជាក់ស្តែងស្តីពីកម្មសិទ្ធិអចលនទ្រព្យ និងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ។ ឧទាហរណ៍ Brandao and Feder, 1996 បានជជែកវែកញែកថា "កម្មសិទ្ធិអចលនទ្រព្យរបស់បុគ្គល (ឬរបស់ក្រុមហ៊ុន) មានសុវត្ថិភាពល្អ គឺជាការសំខាន់បំផុត ក្នុងការបង្កើតរចនាសម្ព័ន្ធមួយនៃគ្រឿងលើកចិត្តខាងសេដ្ឋកិច្ច សំរាប់ជំរុញវិនិយោគនៅក្នុងសកម្មភាពនានាដែលផ្អែកលើដីធ្លី ។ អ្នកស្រាវជ្រាវម្នាក់ក្នុងចំណោមអ្នកស្រាវជ្រាវជាច្រើនទៀតបានសង្កេតឃើញថាកង្វះសមធម៌ក្នុងការទទួលបានដី និងការមានសុវត្ថិភាពកាន់កាប់ដី វារួមចំណែកបង្កនូវភាពក្រីក្រតោកយ៉ាក ការពឹងផ្អែក និងលំនាំគ្មានចីរភាពនៃចំណាកស្រុកនៅជនបទ ។ ក្នុងន័យនេះប្រទេសនានាដែលបានវិនិយោគលើការគ្រប់គ្រងការកាន់កាប់ដីធ្លីឱ្យមានសមភាព និងប្រសិទ្ធភាពខ្ពស់ ច្រើនតែលូតលាស់បានលឿនជាង ប្រទេសដែលមិនបានធ្វើវិនិយោគបែបនេះ (Munro-Faure, 2003) ។ ការសិក្សានានាលើការចេញប័ណ្ណសំគាល់កម្មសិទ្ធិនៅថៃ និងប្រទេសផ្សេងទៀត ក៏បង្ហាញដែរថា ផលប៉ះពាល់លើការលូតលាស់ខាងសេដ្ឋកិច្ច និងសង្គមកិច្ច អាចមានទំហំធំគួរកត់សំគាល់ (Onchan and Aungsumalin, 2002) ។

អ្នកស្រាវជ្រាវផ្សេងទៀត បានចោទសួរទៅលើការអះអាងនេះ ដោយពន្យល់ថា ផលចំណេញបានពីគំរោងផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លី គឺបែងចែកពុំមានសមធម៌ល្អទេ ហើយថាគំរោងបែបនេះ ច្រើនតែជួយខ្លាំងជាង ដល់អ្នកមានដីច្រើននិងធំៗ ។ ឧទាហរណ៍ ដោយប្រើប័ណ្ណកម្មសិទ្ធិដីធ្លីជារបស់បញ្ចាំ គេរំពឹងថាប្រជាជន អាចមានលទ្ធភាពកាន់តែច្រើននឹងទទួល

បានឥណទានពីស្ថាប័នផ្លូវការ ។ គំរោងនេះមានសារៈសំខាន់ជាពិសេសក្នុងការកាត់បន្ថយភាពក្រីក្រ ដោយសារប័ណ្ណកម្មសិទ្ធិដីធ្លីអាចធ្វើឱ្យសមាជិកក្រៗក្នុងសហគមន៍ រកបានឥណទានមានតំលៃទាបសំរាប់បំរើគោលដៅផលិតកម្ម ។ ប៉ុន្តែ (Payne 2000) បានរិះគន់ព្រមានថា រឿងពិតដែលទាក់ទិននឹងឥណទានសំរាប់អ្នកក្រ គឺមិនមែនបញ្ហារបស់របបញ្ចាំទេ ប៉ុន្តែគឺការរារែករបស់ផ្នែកធនាគារ ក្នុងការផ្តល់សេវាឥណទានទៅឱ្យអ្នកខ្ចីជាអ្នកក្រ ដែលសុំប្រាក់ក្នុងចំនួនតូចៗ និងដែលធនាគារត្រូវចំណាយសោហ៊ុយច្រើនដើម្បីធ្វើការគ្រប់គ្រង ។

ផលប៉ះពាល់នៃប័ណ្ណកម្មសិទ្ធិដីធ្លីទៅលើទំហំនៃដីកាន់កាប់តាមគ្រួសារ ក៏រឿងសំខាន់គួរពិចារណាដែរ ។ ភស្តុតាងនៅថៃ (Onchan and Aungsumalin, 2002) បង្ហាញថា ចំនួន និងទំហំ ដីឡូតិ៍ក្នុងមួយគ្រួសារ មាននិន្នាការថយចុះនៅពេលមានការផ្តល់កម្មសិទ្ធិ ។ ដូចមានពិភាក្សានៅខាងក្រោម (ផ្នែក២.២) ទំហំមធ្យមនៃដីកាន់កាប់នាបច្ចុប្បន្ន អាចមិនគ្រប់គ្រាន់ទេសំរាប់សន្តិសុខស្បៀងនៅកម្ពុជា ។ ថ្វីបើកសិករអាចចំណាយទុនជាបន្តទៀតទៅលើសំភារៈផ្គត់ផ្គង់ផ្សេងៗសំរាប់ដីឡូតិ៍តូចៗ ប៉ុន្តែដីឡូតិ៍ទំហំតូចៗវាអាចច្រានចោលនូវវិនិយោគខ្នាតធំដូចជា គ្រឿងម៉ាស៊ីន និងការកែលំអហេដ្ឋារចនាសម្ព័ន្ធ ជាដើម។

ការអះអាងបែបនេះ បានបំផុសផងដែរនូវបញ្ហាសំខាន់ៗខាងវិធីសាស្ត្រ ដែលទាក់ទិននឹងការប៉ាន់ស្មានជាក់ស្តែងពីផលប៉ះពាល់នៃប័ណ្ណកម្មសិទ្ធិដីធ្លី ។ ឧទាហរណ៍ ប័ណ្ណកម្មសិទ្ធិដីធ្លីក៏រំពឹងថា នឹងជួយជំរុញកំណើនវិនិយោគក្នុងផ្នែកផលិតភាពកសិកម្មដែរ ។ ការរំពឹងបែបនេះឈរលើការសន្មតថា ក្របខ័ណ្ឌស្ថាប័នគាំទ្រមួយត្រូវបានបង្កើតឡើង និងមានដំណើរការល្អគួរសម។ ប៉ុន្តែ ក្នុងប្រទេសមួយដូចជាកម្ពុជា ដែលមានគ្រោះរាំងស្ងួត និងជំនន់ កើតឡើងជារឿយៗ នឹងមានឧបសគ្គជាច្រើនទៀត កសិកររារែកនឹងធ្វើវិនិយោគលើធាតុចូលខាងកសិកម្ម ឬធ្វើការកែលំអដី ក្នុងរយៈពេលខ្លី ។ នៅក្នុងន័យនេះ រយៈពេលបីឆ្នាំនៃការសិក្សាសព្វថ្ងៃនៅកម្ពុជា អាចមិនគ្រប់គ្រាន់ទេ ដើម្បីធ្វើការសង្កេតឱ្យបានជាក់លាក់ពីផលប៉ះពាល់នៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ។

រឿងថា សិទ្ធិកាន់កាប់ដីធ្លីមានសុវត្ថិភាព និងលទ្ធភាពទទួលបានដី អាចរួមចំណែកបាន ក៏រិតណាដល់កំណើន និងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច វាជាប់ទាក់ទិនភាគច្រើនទៅលើ សមត្ថភាពស្ថាប័នសាធារណៈ ដើម្បីគ្រប់គ្រងកម្មសិទ្ធិអចលនទ្រព្យឱ្យបានសក្តិសិទ្ធិ និងមាន ប្រសិទ្ធភាព។ ពិតហើយការពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដី មានលទ្ធផលគួរមិនច្បាស់លាស់ ទេនៅតាមកន្លែងជាច្រើនក្នុងប្រទេសកម្ពុជា ប៉ុន្តែយើងនឹងចាត់ទុកថា អថេរខាងអភិបាលកិច្ច នេះ វាជាកត្តាមួយថេរ ដើម្បីយើងអាចផ្តោតការយកចិត្តទុកដាក់ទៅលើ វិនិយោគខាងកសិកម្ម និងលទ្ធភាពទទួលបានឥណទាន។ នេះគឺជាគំនិតមួយដ៏សមរម្យ ពីព្រោះកន្លែងសិក្សាភាគច្រើន ស្ថិតក្នុងតំបន់ដែលមានស្ថិរភាពល្អក្នុងផលិតកម្មស្រូវ និងមានការគ្រប់គ្រងកម្មសិទ្ធិដីធ្លីទៅតាម របៀបរបបជាប្រពៃណីនៅក្នុងមូលដ្ឋាន ដោយគ្មានឃើញទំនាស់ដីធ្លីអ្វីច្រើនទេ ក្រៅតែពី ជំលោះព្រំដីរវាងអ្នកជិតខាងគ្នា និងជំលោះកម្មសិទ្ធិដីក្នុងក្រុមគ្រួសារ ។

ក្នុងជំពូកនេះ យើងពិភាក្សាពីផលប៉ះពាល់ជាសក្តានុពលនៃប័ណ្ណកម្មសិទ្ធិដីធ្លី ទៅលើ ផលិតភាព និងវិនិយោគខាងកសិកម្ម ព្រមទាំងលទ្ធភាពទទួលបានឥណទាន ដោយប្រើទិន្នន័យ ទទួលបានពី ៩១៦គ្រួសារជនបទ ដែលកាន់កាប់ដីកសិកម្មនៅក្នុង ៤ ខេត្ត ដែល LMAP កំពុង ធ្វើការចេញប័ណ្ណកម្មសិទ្ធិដីធ្លី[១០] ។ យើងទស្សន៍ទាយថា របាយអត្ថប្រយោជន៍នៃការផ្តល់ប័ណ្ណ កម្មសិទ្ធិដីធ្លីនេះ នឹងមានបែបផែនស្របទៅតាមរបាយនៃទំហំដីកាន់កាប់ និងទ្រព្យសម្បត្តិរបស់ គ្រួសារ ។ យើងនឹងហៅគ្រួសារណាដែលមានទ្រព្យនិងដីកាន់កាប់ច្រើនគ្រាន់បើ ថាជាគ្រួសារ មានផលប៉ះពាល់ជាសក្តានុពលខ្ពស់ (HPI) ហើយគ្រួសារមានទ្រព្យនិងដីកាន់កាប់តិច ថាជា គ្រួសារមានផលប៉ះពាល់ជាសក្តានុពលទាប (LPI) ។ ម្យ៉ាងទៀត គ្រួសារស្ថិតក្នុងតំបន់មាន សមត្ថភាពខ្ពស់ (HCAs) ដែលនៅទីនោះហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានមានការរីកចំរើនច្រើន គឺមានលទ្ធភាពច្រើនជាងក្នុងការទទួលបានផលចំណេញពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ជាជាង

[១០] កំពង់ចាម កំពង់ធំ ក្រុងព្រះសីហនុ និងតាកែវ ។

គ្រួសារដែលស្ថិតនៅក្នុងតំបន់មានសមត្ថភាពទាប (LCAs) ដែលមានធនធានតិចជាង និងមានស្ថាប័នផ្សេងៗមានការអភិវឌ្ឍន៍មិនសូវល្អ ។

ការទស្សន៍ទាយទាំងនេះ បាននាំទៅដល់អនុសាសន៍មួយចំនួនស្តីពីការកសាងកម្មវិធី និងគោលនយោបាយផ្សេងៗ ។ ទី១ ផលប៉ះពាល់នៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីលើការអភិវឌ្ឍន៍សង្គមកិច្ច កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ អាចបានប្រសើរបំផុត តាមការផ្តោតកិច្ចប្រឹងប្រែងផ្តល់កម្មសិទ្ធិដីធ្លី នៅតាមតំបន់ដែលស្ថាប័នរដ្ឋាភិបាល NGOs និងវិនិយោគិនឯកជន បានចូលធ្វើការយ៉ាងសកម្មហើយ ។ ក្នុងពេលជាមួយគ្នា ផលចំណេញនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី សំរាប់គ្រួសារងាយរងគ្រោះ និងទន់ខ្សោយជាងគេ គឺអាចកែលំអឡើងបាន ដោយកំណត់យកតំបន់នានាដែលមានសេវាសង្គម និងធនធានអភិវឌ្ឍន៍ ផ្តោតចំទៅលើអ្នកក្រ ។ ទី២ ផលចំណេញនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី សំរាប់គ្រួសារទន់ខ្សោយជាងគេ អាចបង្កើនឡើងបាន តាមរយៈគោលនយោបាយដែលផ្សារភ្ជាប់គំរោងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ទៅនឹង គោលដៅអភិវឌ្ឍន៍ដែលអំណោយផលដល់អ្នកក្រ ។ ឧទាហរណ៍ គោលនយោបាយដែលសំដៅកាត់បន្ថយអត្រាការប្រាក់ក្នុងវិស័យផ្លូវការ អាចជួយបង្កើនលទ្ធភាពទទួលបានឥណទានរបស់គ្រួសារមានដីតូចៗ ។ ម្យ៉ាងទៀត ពន្ធលើដីមិនបានប្រើប្រាស់ ចាប់ពីទំហំណាមួយឡើងទៅ អាចជួយកាត់បន្ថយបញ្ហាជាច្រើនដែលទាក់ទិននឹងការជួញដូរដី និងទំនាស់ដីធ្លី ព្រមទាំងជួយបង្កើនចំរុះកម្មនៃការប្រើប្រាស់ដី និងបង្កើនអត្រាប្រើប្រាស់ដី ។

## ២.២ រចនាសម្ព័ន្ធជំពូក

ផ្នែកទី២ ពិនិត្យពីឯកសារនានាដែលទាក់ទងនឹង (ក) រដ្ឋបាលដីធ្លី និងចំណុចលេចធ្លោមួយចំនួននៃស្ថានភាពដីធ្លីបច្ចុប្បន្ននៅជនបទកម្ពុជា និង (ខ) កម្មសិទ្ធិអចលនទ្រព្យ និងសុវត្ថិភាពនៃការកាន់កាប់ដីជាទូទៅ។ ផ្នែកនេះក៏មានពិនិត្យផងដែរ ពីវិធីសាស្ត្រស្រាវជ្រាវ។ ផ្នែកទី៣ ពិភាក្សាពី ប្រជាជននៅក្នុងអង្កេត LMAP នៅជនបទ ដោយពិនិត្យពី ទំហំដីកាន់កាប់តាម គ្រួសារ ទំហំទ្រព្យសម្បត្តិ ព្រមទាំងយេនឌ័រនៃមេគ្រួសារ ។ ផ្នែកទី៤ និងទី៥ ពិនិត្យលំអិតថែមទៀត លើគំហើញសំខាន់ៗទាក់ទិននឹងផលិតភាព និងវិនិយោគខាងកសិកម្ម ព្រមទាំងសកម្មភាព

ឥណទាន ។ ផ្នែកទី៦ ផ្តល់ការសន្និដ្ឋានលើជំពូកនេះ បូកសរុបពីចំណុចសំខាន់ៗ និងផ្តល់អនុសាសន៍មួយចំនួនខាងគោលនយោបាយ និងការកសាងកម្មវិធី ។

## ២.៣ ការសិក្សាឯកសារ និងវិធីសាស្ត្រ

នៅក្នុងផ្នែកនេះ យើងសិក្សាពីឯកសារថ្មីៗដែលទាក់ទិននឹងរដ្ឋបាលដីធ្លី និងសភាពការណ៍ខាងដីធ្លីសព្វថ្ងៃនៅកម្ពុជា ។ បន្ទាប់មកយើងពិនិត្យឯកសារជាប់ទាក់ទិននឹងកម្មសិទ្ធិអចលនទ្រព្យ និងសុវត្ថិភាពនៃការកាន់កាប់ដី ដែលជាគ្រឹះខាងទ្រឹស្តីសំរាប់កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ។ ការពិភាក្សានេះ នឹងជួយកំណត់ក្របខ័ណ្ឌនៃវិធីសាស្ត្រស្រាវជ្រាវដែលបានយកមកប្រើក្នុងការវាយតំលៃពីផលប៉ះពាល់នៃកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ។

### *២.៣.១ រដ្ឋបាលដីធ្លី*

របាយការណ៍ភាគច្រើនស្តីពីរដ្ឋបាលដីធ្លីនៅកម្ពុជា តែងលើកពីអតីតកាល ដែលកាលណោះដីធ្លីជាកម្មសិទ្ធិរបស់ព្រះរាជា ហើយព្រះអង្គប្រទានទៅឱ្យប្រជារាស្ត្រនូវសិទ្ធិប្រើប្រាស់ដីដើម្បីបង្កបង្កើនផល ។ ដោយសារប្រជាជនមានតិច បើធៀបនឹងដីដែលមាន ដូច្នេះបរិមាណដីដែលប្រជាជនអាចបង្កបង្កើនផល គឺជាប់ទាក់ទងមួយភាគធំទៅនឹងធនធានពលកម្ម និងទ្រព្យសម្បត្តិក្នុងគ្រួសារ ដូចជា សត្វអូសទាញ ជាដើម។ គោលការណ៍ដែលគ្រប់គ្រងសិទ្ធិប្រើប្រាស់ដី គឺប្រព័ន្ធដាំដុះយថាផល ដែលអាចសំគាល់បានតាមរយៈ ដង់ស៊ីតេប្រជាជនទាប និងការដាំដុះតិចដង ។ ជាទូទៅ សិទ្ធិទាំងនេះស្ថិតក្រោមការគ្រប់គ្រងក្រៅផ្លូវការនៅកំរិតមូលដ្ឋាន ទៅតាមទំនៀមទំលាប់ និងប្រពៃណី ។

ប្រព័ន្ធគ្រប់គ្រងដីធ្លីផ្លូវការដែលទទួលស្គាល់កម្មសិទ្ធិឯកជន បានដាក់ប្រើប្រាស់ដំបូងដោយច្បាប់ ស្តីពីដីធ្លីនៅឆ្នាំ១៨៨៤ ក្នុងរបបអាណានិគមបារាំង តែអនុវត្តមិនទាន់បានពេញលេញទេរហូតដល់ឆ្នាំ១៩៣០ ។ ប្រព័ន្ធនេះនៅជាធរមានរហូតដល់ឆ្នាំ១៩៧៥ ដូច្នេះ កម្ពុជាមានច្បាប់ដីធ្លីផ្លូវការ បទប្បញ្ញត្តិរួមផ្សំសំរាប់រដ្ឋបាលដីធ្លី ដែលមានដំណើរការជាក់ស្តែង ក្នុងរយៈពេលប្រហែល ៤ជំនាន់មនុស្ស ។ គេគិតថា រយៈពេលនេះវែងគ្រប់គ្រាន់ហើយ ដើម្បីឱ្យប្រព័ន្ធនេះក្លាយជាស្ថាប័នមួយដ៏រឹងមាំ និងមានការទទួលស្គាល់នៅក្នុង "ចិត្តគំនិតរបស់សង្គម"

(Asia Development Bank, 2003) ។ ប៉ុន្តែប្រភពផ្សេងៗទៀត បានលើកឡើងថា ប្រព័ន្ធនេះ អនុវត្តភាគច្រើនតែក្នុងតំបន់ធ្វើស្រែដែលមានដង់ស៊ីតេប្រជាជនខ្ពស់ប៉ុណ្ណោះ ។ ហើយនៅក្រោយពេលបានឯករាជ្យនៅឆ្នាំ១៩៥៤ រដ្ឋាភិបាលកម្ពុជា ក៏មានការជឿនលឿនតែមួយក៏រិតតូចប៉ុណ្ណោះ ក្នុងការចុះបញ្ជីអចលនទ្រព្យជាផ្លូវការ (World Bank, 2003)[១១] ។

បញ្ហាបច្ចុប្បន្នជាច្រើនដែលជាប់ទាក់ទិននឹងសិទ្ធិកាន់កាប់ដី និងរដ្ឋបាលដីធ្លីនៅកម្ពុជា វាអាចមានឫសគល់ជាប់នឹងសង្គ្រាមស៊ីវិល សង្គ្រាម និងគោលនយោបាយធ្វើសមូហភាវូបនីយកម្មយ៉ាងជ្រាលជ្រៅ ដែលអនុវត្តដោយខ្មែរក្រហម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (DK) ពីឆ្នាំ១៩៧៥-១៩៧៩។ ក្នុងបញ្ហាទាំងនេះគឺមានទាំង ៤ដំណាក់កាលនៃការជំលៀស និងចលនាប្រជាជនអ្នកជនបទនិងទីក្រុងផង ។ ដំណាក់កាលទី១ កើតឡើងក្នុងតំបន់ដែលមានប្រជាជនជាច្រើនត្រូវបង្ខំចិត្តចាកចោលដីធ្លី ដើម្បីទៅជ្រកកោននៅភ្នំពេញ និងតំបន់ទីក្រុងផ្សេងទៀត ដោយសារមានការវាយប្រយុទ្ធកាន់តែខ្លាំងនៅមុនឆ្នាំ១៩៧៥ ។ ដំណាក់កាលទី២ កើតឡើងដោយសារគោលនយោបាយដ៏សាហាវបង្ខំឱ្យប្រជាជនធ្វើចំណាកស្រុក ក្នុងរបប ប៉ុល ពត ពីឆ្នាំ១៩៧៥-១៩៧៩ ។ ដំណាក់កាលទី៣ កើតឡើងនៅពេលប្រជាជនរត់ទៅជ្រកកោននៅថៃ និងប្រទេសផ្សេងៗទៀត ក្រោយពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យនៅដើមឆ្នាំ១៩៧៩ ។ ដំណាក់កាលទី ៤ កើតឡើង នៅពេលដែលជនភៀសខ្លួនកម្ពុជាត្រូវបានធ្វើមាតុភូមិនិវត្តន៍ចេញពីជំរំជនភៀសខ្លួននៅថៃ និងពីកន្លែងផ្សេងទៀតនៅឆ្នាំ១៩៩២-១៩៩៣ ក្នុងសម័យអ៊ុនតាក់ ។

ចំពោះការគ្រប់គ្រង និងរដ្ឋបាលដីធ្លីវិញ ផែនទីនិងកំណត់ត្រាសុរិយោដីត្រូវបានបំផ្លិចបំផ្លាញ ហើយអ្នកមានជំនាញវិជ្ជាជីវៈភាគច្រើន បានស្លាប់ ឬក៏រត់ចេញពីប្រទេសក្នុងរបបខ្មែរក្រហម ។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំរាប់ទ្រទ្រង់កម្មសិទ្ធិដីឯកជន ក៏ត្រូវខូចខាតនិងបំផ្លាញដែរ ដើម្បីធ្វើកសិកម្មតាមរបបសហករណ៍ ។ ឧទាហរណ៍ ក្នុងតំបន់ធ្វើស្រូវវស្សានៅខេត្តកំពង់ធំ

[១១] ឯកសារវាយតំលៃគំរោងរបស់ធនាគារពិភពលោក បានប្រើក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដើម្បីកំណត់កាលបរិច្ឆេទនៃការទទួលស្គាល់អចលនទ្រព្យឯកជន ព្រមទាំងរដ្ឋបាល និងការគ្រប់គ្រងដីធ្លី ។

កំពង់ចាម ភ្លឺស្រែខ្លះដែលបំរើការជាព្រំប្រទល់រវាងដីឡូត៍ឯកជន និងជារចនាសម្ព័ន្ធសំរាប់គ្រប់គ្រងទឹក ត្រូវបានបំផ្លាញចោលដើម្បីបង្កើតជាផ្ទៃដីធំៗសំរាប់ធ្វើការដាំដុះជាសមូហភាព ។ ថ្វីបើ ដីក៏នៅតែដាំដុះជាសមូហភាពដដែលតាមក្រុមតូចៗ (ក្រុមសាមគ្គី) ក្ដី ប៉ុន្តែក្រោយពីបរាជ័យនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ ប្រព័ន្ធភ្លឺស្រែត្រូវបានកសាង ឬជួសជុលឡើងវិញជាបណ្ដើរៗដើម្បីគ្រប់គ្រងទឹកជាសំខាន់ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (PDK) ។

ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានាទសវត្សរ៍១៩៨០ សិទ្ធិប្រើប្រាស់ដីលំនៅដ្ឋានត្រូវបានបែងចែកដោយផ្អែកលើមូលដ្ឋានការកាន់កាប់ ហើយរដ្ឋនៅតែជាម្ចាស់កម្មសិទ្ធិដីដដែល ។ នៅឆ្នាំ១៩៨៩ រដ្ឋាភិបាលបានដាក់អនុវត្តឡើងវិញនូវកម្មសិទ្ធិអចលនទ្រព្យឯកជនតាមរយៈសេចក្ដីប្រកាសលេខ៣ និងអនុក្រឹត្យលេខ២៥ ហើយក្នុងពេលជាមួយគ្នា បានបដិសេធចោលរាល់កម្មសិទ្ធិនិងការទាមទារនៅមុនឆ្នាំ១៩៧៩ ។ ក្រឹត្យបានបង្កើតសិទ្ធិមានកម្មសិទ្ធិលើដីលំនៅដ្ឋានរហូតដល់ ២.០០០ម$^{២}$ សិទ្ធិកាន់កាប់សំរាប់ដីដាំដុះតិចជាង ៥ ហ.ត និងសិទ្ធិសម្បទានសំរាប់ដីដាំដុះធំជាង ៥ ហ.ត ។

ដីកសិកម្ម ក៏ត្រូវបានបែងចែកទៅឱ្យគ្រួសារនានា ផ្អែកតាមចំនួនមនុស្សពេញវ័យ និងសមាជិកគ្រួសារឯទៀតដែលអាចធ្វើពលកម្មបាន ។ មានកិច្ចប្រឹងប្រែងជាក់លាក់ជាច្រើនដើម្បីផ្ដល់ឱ្យប្រជាជននូវចំណែកដីមានគុណភាពល្អស្មើៗគ្នា ដូចជា ដីមានជីជាតិ ជិតប្រភពទឹកជាដើម ។ គ្រួសារមានសមាជិកច្រើន ក៏បានទទួលដីបន្ថែម ពីចំណែកដីនៅសេសសល់ដែលអាចជាដីមិនសូវមានជីជាតិ ឬនៅឆ្ងាយពីកន្លែងមានកត្តាអំណោយផល ។ ចំពោះផ្ទៃដី គ្រួសារមានសមាជិកច្រើន តែងទទួលបានដីច្រើនឡូត៍ និងមានផ្ទៃដីធំជាង គ្រួសារមានសមាជិកតិចនាក់ ។ ទន្ទឹមនេះ នៅតំបន់ធ្វើស្រែ ប្រព័ន្ធភ្លឺដែលសំគាល់ដីរបស់បុគ្គលម្នាក់ៗ និងសំរួលការគ្រប់គ្រងទឹក ក៏ត្រូវបានពង្រឹង និងពង្រីកដែរ ។

ក្រោយពីអនុម័តច្បាប់ភូមិបាលឆ្នាំ១៩៩២ ប្រជាជនអាចដាក់ពាក្យសុំប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដី ដែលបញ្ជាក់ពីការកាន់កាប់ និងសិទ្ធិប្រើប្រាស់ ដោយច្បាប់បានអនុញ្ញាតតែសិទ្ធិកាន់កាប់ (មិនមែនកម្មសិទ្ធិទេ) នៅក្នុងតំបន់ជនបទ ។ តាំងពីពេលនោះមក មានការដាក់សំណើ

ដល់ ៤លានពាក្យសុំហើយ ប៉ុន្តែកន្លងមក ប្រព័ន្ធសុរិយោដីខ្វះខាតសំភារៈ និងធនធាន ហើយមិនអាចទាំងដោះស្រាយទំហំការងារយ៉ាងសាមញ្ញឱ្យបានល្អផង ។ ក្នុងស្ថានភាពគ្មានប័ណ្ណសំគាល់សិទ្ធិជាផ្លូវការនេះ ទីផ្សារដីធ្លីដែលទើបផុសឡើង នៅតែត្រូវការឱ្យមានយន្តការផ្សេងៗដើម្បីសំរបសំរួលការផ្លាស់ប្តូរតាមកិច្ចសន្យានូវសិទ្ធិលើដីធ្លី ។ ការដោះដូរនេះ មានផ្សំបញ្ចូលគ្នានូវបែបបទផ្សេងៗនៃការផ្លាស់ប្តូរជាផ្លូវការនិងក្រៅផ្លូវការនូវសិទ្ធិលើដីធ្លី ដោយប្រជាជនបានចាប់ផ្តើមផ្លាស់ប្តូរបង្កាន់ដៃទទួលពាក្យសុំកាន់កាប់ដី និងឯកសារផ្សេងៗទៀត (ឧទាហរណ៍ កំណត់ហេតុអង្កេតដី) ដើម្បីធ្វើជាឯកសារសំរាប់បញ្ជាក់ការលក់ដូរ ដែលមានការទទួលស្គាល់នៅកំរិតមូលដ្ឋានដោយអ្នកដឹកនាំភូមិ ឬមេឃុំ (So *et al.* 2001) ។

ច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ត្រូវបានអនុម័តដោយមានការទទួលស្គាល់ជាសំខាន់ថាការរីកលូតលាស់ខាងសង្គមកិច្ចនិងសេដ្ឋកិច្ច តំរូវឱ្យមានប្រព័ន្ធសិទ្ធិកាន់កាប់ដីធ្លីមួយដ៏រឹងប៉ឹង និងការគ្រប់គ្រង និងរដ្ឋបាលដីធ្លីដែលត្រូវបានកែលំអ ។ ច្បាប់បានទទួលស្គាល់កម្មសិទ្ធិដីបីប្រភេទនៅប្រទេសកម្ពុជា គឺមាន កម្មសិទ្ធិដីសាធារណៈរបស់រដ្ឋ កម្មសិទ្ធិដីឯកជនរបស់រដ្ឋ និងកម្មសិទ្ធិដីរបស់ឯកជន ។ ក្នុងប្រភេទកម្មសិទ្ធិដីរបស់ឯកជន កម្មសិទ្ធិអាចជារបស់បុគ្គល របស់សហគមន៍ មិនទាន់បែងចែក និងសហកម្មសិទ្ធិ ។ សិទ្ធិផ្សេងទៀតលើដី រួមមាន សិទ្ធិប្រើប្រាស់និងអាស្រ័យនៅ ផលុបភោគ សិទ្ធិសេវភាព ហ៊ីប៉ូតែក (mortgages) ការបញ្ចាំ (pledges and charges) ព្រមទាំងសិទ្ធិកំណត់ច្បាស់តាមកិច្ចសន្យា ដែលភាគីជាប់ពាក់ព័ន្ធបានឯកភាពគ្នា (Asia Development Bank, 2003) ។

## ២.៣.២ ស្ថានភាពដីបច្ចុប្បន្ន

ចំពោះស្ថានភាពដីបច្ចុប្បន្ននៅកម្ពុជា គឺគេឃើញមានកំណើនសំពាធប្រជាសាស្ត្រ សិទ្ធិកាន់កាប់ដីគ្មានសុវត្ថិភាព វិសមភាពក្នុងការកាន់កាប់ដី កំណើនភាពគ្មានដីនិងស្ទើរគ្មានដី និងផលិតភាព

និងវិនិយោគក៏រិតទាប[១២] ។ ស្ថានភាពនេះគួរឱ្យបារម្ភជាពិសេសនៅតំបន់ជនបទ ដែលនៅទីនោះ ប្រជាជនកម្ពុជា ៨០-៨៥% ធ្វើកសិកម្មជីវព្រឹត្តិ ។ ម្យ៉ាងទៀត ក្នុងប្រជាជនកម្ពុជាប្រមាណ ៣៦% ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ភាគច្រើនគឺស្ថិតនៅក្នុងតំបន់ជនបទ ។ ប្រជាជនកម្ពុជាភាគច្រើន នៅតែបន្តពឹងផ្អែកលើកសិកម្ម ដោយយកវាធ្វើជាមធ្យោបាយចំបងសំរាប់ដោះស្រាយជីវភាព ពីព្រោះវិស័យសេវាកម្ម និងឧស្សាហកម្ម មិនរំពឹងថាកើនលឿនទាន់កំណើនកំលាំងពលកម្មទេ នៅក្នុងអនាគតដ៏ខ្លីនេះ[១៣] ។

បញ្ហានានាទាក់ទិននឹងការកាន់កាប់ដីធ្លីនៅជនបទ ក៏មានផលប៉ះពាល់ដល់តំបន់ទីក្រុងដែរបើតាមមធ្យោបាយផ្សេងៗទៀត ។ ផលប៉ះពាល់ដែលលេចធ្លោជាងគេ គឺប្រជាជនដ៏ច្រើនៗដែលធ្វើចំណាកស្រុកទៅទីក្រុងដើម្បីរកការងារធ្វើ ។ ចំណាកស្រុកនេះ រួមទាំងកត្តាផ្សេងៗទៀត បានដាក់សំពាធយ៉ាងធ្ងន់ធ្ងរទៅលើទីផ្សារនៃលំនៅដ្ឋាន សេវាសាធារណៈ និងការផ្គត់ផ្គង់សាធារណៈ (ឧទាហរណ៍ ទឹក និងអនាម័យ) ហើយវាជាប្រភពធ្វើឱ្យអស្ថិរភាពសង្គមអាចកើតមានឡើងបាន ។ ទំនាស់ដីធ្លីទាក់ទិននឹងប្រជាជនអ្នកគ្មានដី ទៅរំលោភយកដីរដ្ឋ ឬដីឯកជនក៏កើនឡើងដែរ ។ ដោយមានបញ្ហាទាំងនេះ និងបញ្ហាដទៃទៀត កំណែទំរង់សិទ្ធិលើទ្រព្យសម្បត្តិ និងដីធ្លី ទាំងនៅជនបទ និងទីក្រុង មានអាទិភាពខ្ពស់នៅក្នុងរបៀបវារៈអភិវឌ្ឍន៍របស់រដ្ឋាភិបាល ដូចមានចែងក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី ២ (២០០១-២០០៥) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (២០០៣-២០០៥) ។

---

[១២] ឧទាហរណ៍ សូមអាន Van Acker, Frank (1999); Biddulph, Robin (Oxfam GB, 2000); So *et al*, (2001); Sophal *et al.* (2003) ។

[១៣] Kang Chandararot and Chan Sophal (CDRI, 2003) ។

### ២.៣.២.១ ផលិតកម្ម និងវិនិយោគកសិកម្ម

ផលិតភាពដី បើពិនិត្យតាមទិន្នផលនៅកម្ពុជា គឺស្ថិតនៅក្នុងចំណាត់ថ្នាក់ទាបៗជាងគេបំផុតនៅក្នុងតំបន់[១៤] ហើយចំណូលពីកសិកម្មក៏បានទាបណាស់ដែរ ។ កសិករភាគច្រើនខ្វះធនធានទុនដើម្បីវិនិយោគលើធាតុចូលផ្សេងៗ (ឧទាហរណ៍ គ្រាប់ពូជ និងជី) សំភារៈបរិក្ខា (ឧទាហរណ៍ ម៉ាស៊ីនបូមទឹក និងគោយន្ត) ឬលើការកែលំអដីធ្លី (ឧទាហរណ៍ ប្រព័ន្ធស្រោចស្រពតូចៗ) ។ បញ្ហាមួយទៀតទាក់ទិននឹងកង្វះលទ្ធភាពទទួលបានឥណទានពីស្ថាប័នផ្លូវការ ដោយសារទីតាំងកង្វះរបស់ដាក់បញ្ចាំ/ធានា ដើម្បីទទួលបានកំចីមានតំលៃទាប ឬការពុំមានព័ត៌មានគ្រប់គ្រាន់អំពីច្បាប់ និងបទដ្ឋានគ្រប់គ្រងឥណទាន (ឧទាហរណ៍ រយៈពេលសងប្រាក់ និងករណីមិនអាចសងបំណុល) ។ ជាលទ្ធផល កសិករខ្ចីបុលជារឿយៗពីវិស័យក្រៅផ្លូវការ ជួនកាលក្នុងអត្រាការប្រាក់ដ៏ខ្ពស់ ពីអ្នករកស៊ីចងការប្រាក់ ដើម្បីដោះស្រាយធុរៈបន្ទាន់ផ្សេងៗ (ឧទាហរណ៍ ការថែទាំសុខភាព និងកង្វះស្បៀងអាហារ) និងធាតុចូលកសិកម្មតាមរដូវកាល (ឧទាហរណ៍ ពូជ និងជី) ។ នៅពេលមានជំរើសឥណទានតែតិចតួច ការខ្ចីបុលសំរាប់ធុរៈបន្ទាន់ផ្សេងៗ វាច្រានចេញអស់នូវចំណាយវិនិយោគ ។

កសិករភាគច្រើន ក៏ខ្វះខាតកម្មសិទ្ធិដីមានសុវត្ថិភាពដែរ ដែលធ្វើឱ្យពួកគេងាយរងគ្រោះដោយសារ ការទន្ទ្រានយកដី ការរំលោភយកដី និងទំនាស់ប្រភេទផ្សេងៗទៀត ។ រឿងនេះបានកាត់បន្ថយទឹកចិត្តធ្វើវិនិយោគ ទោះបីនៅពេលគេមានធនធានទុនហើយក្តី ។ កសិករជាច្រើនក៏គ្មានលទ្ធភាព ឬមួយស្ទាក់ស្ទើរនឹងប្រថុយគ្រោះថ្នាក់ជាប់ទាក់ទិននឹងប្រែប្រួលចុះឡើងនៃដី និងអាកាសធាតុដែរ (ឧទាហរណ៍ ការរាំងស្ងួត និងទឹកជំនន់) ។ កសិករត្រូវប្រឈមនឹងការិតថ្លៃទាបសំរាប់ផលិតផលរបស់ខ្លួន បើធៀបនឹងចំណាយដ៏ខ្ពស់លើធាតុចូល ការលក់ដូរ និងការរកទីផ្សារ ។ ម្យ៉ាងទៀត កសិករជាច្រើនពុំមានលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយអំពីគ្រាប់ពូជ ការចិញ្ចឹមសត្វ ការនេសាទ ឬពត៌មានអំពីលក្ខខណ្ឌទីផ្សារ និងនិន្នាការកំនត់ថ្លៃទេ ។

---

[១៤] Sophal, Chan, Kim Seadara, and Sarthi Acharya (CDRI, 2003) ។

ចំពោះផលិតភាពវិញ Sophal and Acharya (2002b) បានសង្កេតឃើញថា ការលើកឡើងជាទូទៅទាក់ទិននឹងផលិតភាពខ្ពស់ជាងរបស់កសិដ្ឋានតូចៗនៅអាស៊ី ក៏ពិតផងដែរសំរាប់កម្ពុជា នៅពេលកសិករប្រើវិធីសាស្ត្របែបប្រពៃណីដើម្បីធ្វើស្រូវវស្សា ។ ប៉ុន្តែទំនាក់ទំនងនេះច្រើនតែខុសវិញ "នៅពេលមានការប្រើវិធីសាស្ត្រកសិកម្មទំនើប ដើម្បីដាំដុះនៅរដូវប្រាំង" ។ គេក៏សង្កេតឃើញដែរថា ផលិតកម្មសរុបច្រើនតែទទួលបានតិចជាងក្នុងកសិដ្ឋានតូចៗ ដូច្នេះប្រសិទ្ធភាពខ្ពស់មិនមែនសុទ្ធតែមានន័យថា មានសំរាប់សន្តិសុខស្បៀងនោះទេ ។ រឿងនេះបំផុសសំនួរដ៏សំខាន់អំពីទំហំកសិដ្ឋានដែលប្រសើរបំផុតនៅកម្ពុជា (សូមអានផ្នែក ២.៧.៣) ។

## *២.៣.២.២ វិសមភាពដីធ្លី*

យោងតាម អង្កេតសង្គមកិច្ច-សេដ្ឋកិច្ច (SES) ឆ្នាំ១៩៩៩ នៅកម្ពុជាមានដីកសិកម្មប្រហែល ២,៨៨លានឡូត៍ គឺថា ជាមធ្យមមួយគ្រួសារមានដី ១,៣៧ឡូត៍ ហើយមួយឡូត៍មានទំហំជាមធ្យម ០,៩០ហ.ត ។ ការសិក្សាថ្មីៗជាច្រើន[១៥] បានបង្ហាញពីកំណើនវិសមភាពដីធ្លីនៅកម្ពុជា ដោយបញ្ជាក់ថា Gini co-efficients មានទំហំពី ០,៥០-០,៦១ សំរាប់ដីកសិកម្ម ។ រីឯមូលហេតុគឺមានជាអាទិ៍ សំពាធប្រជាសាស្ត្រ ប្រជាជនដ៏ច្រើនៗមិនទាន់បានតាំងលំនៅ ទីផ្សារឥណទានទន់ខ្សោយ ការទិញដីទុកលក់យកចំណេញដោយពួកអ្នកមាននៅទីក្រុងដែលប្រហែលអស់ច្រកអ្វីផ្សេងហើយដើម្បីវិនិយោគទុន[១៦] ។

គួរចងចាំជាសំខាន់ថា ក្នុងរឿងសមភាពដីធ្លីរវាងគ្រួសារនានានេះ ការបែងចែកដីគឺមិនដែលមានសមភាពទេ តាំងពីការបែងចែកដីនៅឆ្នាំ១៩៨៩ មកម្លេះ ។ ដូចបានបង្ហាញពីខាងដើម ដីធ្លី ត្រូវបានបែងចែកទៅឱ្យគ្រួសារនានាដោយយោងតាមចំនួនសមាជិកគ្រួសារដែលធ្វើពលកម្ម ។ ជាលទ្ធផល គ្រួសារធំៗ គឺបានទទួលដី និងចំនួនដីឡូត៍ច្រើនជាងគ្រួសារតូចៗ ។

---

[១៥] រាជរដ្ឋាភិបាលកម្ពុជា (១៩៩៩) *របាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៩* (ភ្នំពេញ ក្រសួងផែនការ) ។

[១៦] សូមអានឯកសាររបស់ សូ សុវណ្ណារិទ្ធិ, ច័ន្ទ សុផល, និង Sarthi Acharya (CDRI, 2001)

គ្រួសារតូចៗ ដែលមានកំលាំងពលកម្មតិចនាក់ ជាពិសេសមេគ្រួសារស្រ្តីមេគ្រួសារ ត្រូវចាញ់ប្រៀបគេយ៉ាងច្រើនក្រោយមក ក្នុងការងារដាំដុះឱ្យមានផលិតភាពល្អ និងមានចីរភាព ។ ដោយហេតុនេះ ពួកគេងាយរងគ្រោះចំពោះហេតុការណ៍បន្ទាន់នានា និងការប៉ះទង្គិចផ្សេងៗមកលើគ្រួសារ ហើយច្រើនតែត្រូវបាត់បង់ដីក្នុងល្បឿនលឿនជាងគ្រួសារឯទៀតៗ ដោយសារការលក់ដីដើម្បីដោះទាល់ ។

### *២.៣.២.៣ ភាពអត់ដីធ្លី ឬភាពជិតអត់ដីធ្លី*

អ្នកស្រាវជ្រាវបានប៉ាន់ស្មានថា គ្រួសារជនបទ ១២-១៥% គ្មានដីកសិកម្មទេ[១៧] ហើយភាពគ្មានដីធ្លីទាំងស្រុង អាចកើនឡើងប្រហែល ២% ក្នុងមួយឆ្នាំ[១៨] ។ អត្រាអត់ដីធ្លី ក្នុងចំណោមគ្រួសារស្រ្តីមេគ្រួ ក៏ខ្ពស់ជាងអត្រាសំរាប់គ្រួសារបុរសមេគ្រួដែរ[១៩] ។ ឧទាហរណ៍ អង្កេតមួយរបស់ Oxfam GB លើ ៣0.000គ្រួសារ រកឃើញ អត្រាអត់ដីធ្លី ២១% ក្នុងចំណោមគ្រួសារស្រ្តីមេគ្រួ ធៀបនឹងអត្រា ១៣% សំរាប់គ្រួសារទាំងអស់ ។ ចំពោះ "ភាពជិតអត់ដីធ្លី" គេបានប៉ាន់ស្មានថា ប្រហែល ២៥% នៃគ្រួសារទាំងអស់ មានដីតិចជាង 0,៥ហ.ត គឺមិនគ្រប់គ្រាន់ទេសំរាប់ទ្រទ្រង់ជីវភាព ។ Acharya *et al.* (2001:2) ក៏សង្កេតឃើញដែរថា "ទំហំដីតូច គួបផ្សំនឹងការប្រើប្រាស់តិចនូវបច្ចេកវិទ្យាទំនើប គឺជាមូលហេតុចំបងនៃភាពក្រីក្រនៅជនបទ" ។

កំនើនភាពអត់ដីធ្លី និង "ភាពជិតអត់ដីធ្លី" ជាប់ទាក់ទិននឹងកត្តាដ៏ស្មុគស្មាញជាច្រើន ។ អ្នកអត់ដីជាច្រើននាក់ គឺមិនដែលមានដីទេ (ជាពិសេសតាំងពីដើមទសវត្សរ៍ ១៩៩0 មក) ។ ឧទាហរណ៍ អតីតជនភៀសខ្លួនជាច្រើននាក់ដែលធ្វើមាតុភូមិនិវត្តន៍ទៅកាន់តំបន់ជនបទនៅឆ្នាំ១៩៩២-៩៣ មិនដែលទទួលបានដីទេ ដោយសារដីមានគេកាន់កាប់ហើយ ឬក៏មានមីន ។ ហើយប្រជាជនមួយចំនួនដែលធ្លាប់មានដី ក៏បាត់បង់ដីទៅដោយសារមូលហេតុជាច្រើន ។

---

[១៧] Biddulph, Robin (Oxfam GB, 2000); So *et al.* (CDRI, 2001) ។

[១៨] Ibid. ។

[១៩] Ibid. ។

មូលហេតុមួយដែលមានលើកឡើងជារឿយៗគឺ កង្វះឥណទានមានតំលៃថោកគួរសមអាចខ្ចីប្រើបាន វាបានរុញច្រានប្រជាជនមួយចំនួនឱ្យលក់ដី នៅពេលមានវិបត្តិ ។ ឧទាហរណ៍ ក្នុងចំណោមគ្រួសារគ្មានដី នៅក្នុងការសិក្សារបស់ Oxfam GB មាន ៤៣,៦% ដែលកាលពីមុនធ្លាប់មានដី តែក្រោយមកក៏បាត់បង់ដីអស់ ក្នុងនេះមានជិត ៨៧% បានលក់ដីដើម្បីដោះទាល់ ហើយមានជិត ៥០% បានលក់ដីដើម្បីព្យាបាលជំងឺ[២០] ។

កត្តាផ្សេងទៀតរួមមាន មានផលិតភាពទាប និងចំណូលទាប ដែលបង្ខំឱ្យកសិករមួយចំនួនឈប់ធ្វើកសិកម្ម រួចធ្វើចំណាកស្រុកទៅកន្លែងផ្សេងដើម្បីលក់កំលាំងពលកម្ម។ ការទន្ទ្រានយកដី និងការទិញដីទុកលក់យកចំណេញ ក៏បង្កឱ្យមានភាពគ្មានដីមួយចំនួនដែរ ។ ឧទាហរណ៍ ក្នុងគំរូតាង Oxfam ១៣% នៃអ្នកអត់ដីបានរាយការណ៍ថា ត្រូវគេដកហូតយកដីពីពួកគេដោយគ្មានផ្តល់សំណងប៉ះប៉ូវ[២១] ។ សំពាធប្រជាសាស្ត្រ និងការពុះចែកដីឡូត៍ ក៏ជាកត្តារួមផ្សំដែរ ។ ឧទាហរណ៍ Biddulph (2004) បានសង្កេតឃើញថា ចំនួនគ្រួសារថ្មី បានកើនលឿនជាង ចំនួនប្រជាជនសរុប ដោយសារការប្រែប្រួលខុសលំនាំដើមក្នុងស្រទាប់ប្រជាជន ដែលបង្កឡើងដោយការប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៥-១៩៧៩ ។ រឿងនេះបង្ហាញថា គ្រួសារនានាត្រូវតែពុះចែកដីឡូត៍ក្នុងអត្រាមួយយ៉ាងលឿន ដើម្បីបំពេញតំរូវការផ្ទេរតកឱ្យកូនៗ ជាពិសេសអ្នកទើបរៀបការថ្មី ។

### *២.៣.២.៤ ការកាន់កាប់ដី*

យោងតាមនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្នុងចំណោមអ្នកដាក់ពាក្យសុំ ប្រហែល ៤,៥ លាននាក់ មានមិនលើសពី ១៤% ទេដែលបានទទួលប័ណ្ណសំគាល់សិទ្ធិជាផ្លូវការ តាំងពីដើមទសវត្សរ៍១៩៩០ មក ។ ប័ណ្ណសំគាល់សិទ្ធិច្រើនណាស់ (មិនសមាមាត្រទេ) បានផ្តល់ឱ្យនៅខេត្តកណ្តាល តាកែវ កំពត ព្រមទាំងនៅតាមខេត្តមានប្រជាជនច្រើនៗឯទៀតនៅភាគខាងត្បូង

---

[២០] Biddulp, Robin (2000) ។

[២១] Ibid. ។

និងនៅខេត្តសៀមរាប ។ ប័ណ្ណសំគាល់សិទ្ធិដែលចេញឱ្យពីឆ្នាំ១៩៨៩-១៩៩៥ គឺមានច្រើនជាងប័ណ្ណដែលចេញឱ្យពីឆ្នាំ១៩៩៥-២០០០ ដែលប្រហែលដោយសារករណីងាយៗ (ដូចជា ងាយទៅដល់, គ្មានទំនាស់) ត្រូវបានដោះស្រាយមុន (Sophal *et al*, 2001) ។ មានភស្តុតាងមួយចំនួនបង្ហាញថា ភាគរយគ្រួសារស្ត្រីមេគ្រួដែលបានទទួលប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដី គឺមានកំរិតទាបជាង តួលេខសំរាប់គ្រួសារបុរសមេគ្រួ (Boreak, 2000) ។ គេអាចពន្យល់បានថាគ្រួសារក្រីក្រក្នុងនេះគឺមានគ្រួសារស្ត្រីមេគ្រួជាច្រើន ពុំមានលទ្ធភាពរ៉ាប់រងចំណាយដ៏ខ្ពស់ដើម្បីទទួលបានប័ណ្ណសំគាល់សិទ្ធិនោះទេ (So *et al*, 2001) ។

តំរូវការនូវឯកសារដីជាផ្លូវការ ហាក់ដូចមានកំរិតខ្ពស់បំផុតនៅក្នុងតំបន់នានាដែលស្ថិតនៅតាមដងផ្លូវ និងនៅជិតតំបន់ផ្សារក្នុងទីប្រជុំជន ដែលគេអាចប្រើប័ណ្ណសំគាល់សិទ្ធិ ដើម្បី "សំរួលដល់ការលក់ដូរដីធ្លី បញ្ជាក់ព្រំដី និងចៀសវាងជំលោះជាមួយពួកអ្នកតវ៉ាទាមទារផ្សេងៗជាយថាហេតុ" ។ ប៉ុន្តែ ចំនាយដ៏ខ្ពស់ (ដូចជា ពេលវេលា កំរៃផ្លូវការ/ក្រៅផ្លូវការ) ដើម្បីទទួលបានប័ណ្ណសំគាល់សិទ្ធិ វាបានរារាំងប្រជាជនជាច្រើននាក់ក្នុងការស្វែងរកប័ណ្ណនេះ (So *et al*, 2000) ។ ដូច្នេះហើយ អ្នកមានទ្រព្យ និងមានឋានៈខ្ពស់ច្រើនប្រឹងប្រែងស្វែងរកប័ណ្ណសំគាល់សិទ្ធិដីធ្លី ខ្លាំងជាងពួកអ្នកមិនសូវមានធនធាន ។ម្យ៉ាងទៀត ប្រជាជនមួយចំនួនខ្វះទំនុកចិត្តលើសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលដើម្បីពង្រឹងការអនុវត្តន៍កម្មសិទ្ធិដី ជាពិសេសនៅពេលមានជាប់ពាក់ព័ន្ធនឹងអ្នកមានអំណាច ។

ជំនួសឱ្យប័ណ្ណសំគាល់សិទ្ធិ ប្រជាជនភាគច្រើនប្រើប្រាស់ឯកសារផ្សេងៗទៀត ដើម្បីបញ្ជាក់ពីកម្មសិទ្ធិ ដូចជា បង្កាន់ដៃទទួលពាក្យសុំកាន់កាប់ដី និង/ឬ កំណត់ហេតុអង្កេតដីជាដើម។ ជារឿយៗ គេបានផ្ទេរឯកសារទាំងនោះពីដៃមួយទៅដៃមួយ ដើម្បីសំរួលដល់ការលក់ដូរដី ។ ក្នុងការលក់ដូរដែលមានការប្រគល់ទាំង បង្កាន់ដៃទទួលពាក្យសុំកាន់កាប់ដី និងប័ណ្ណសំគាល់កម្មសិទ្ធិពិតៗ ប្រជាជនតាមធម្មតាគ្រាន់តែលុបឈ្មោះចាស់ចេញ និងសរសេរឈ្មោះថ្មីចូលប៉ុណ្ណោះ ។ ប្រព័ន្ធនេះហាក់ដូចប្រើការបាននៅក្នុងតំបន់ជាច្រើន ឱ្យតែភាគីជាប់ពាក់ព័ន្ធនឹងការលក់ដូរនោះ សុខចិត្តទទួលយកឯកសារប្រភេទនេះ ។ កន្លងមកវិធីនេះឃើញមានប្រើ

ច្រើនជាធម្មតាក្នុងការលក់ដូរនានាដែលធ្វើឡើងនៅកំរិតមូលដ្ឋាន រវាងប្រជាជនដែលស្គាល់គ្នាទៅវិញទៅមក ឬក៏មានចំណងទាក់ទងរួមគ្នាបែបណាមួយ ។ ប៉ុន្តែការយល់ច្រឡំ និងជំលោះច្រើនតែកើនឡើង នៅពេលការលក់ដូរវាទាក់ទងជាមួយពួកអ្នកមកពីខាងក្រៅសហគមន៍ ។

## ២.៤ កម្មសិទ្ធិអចលនវត្ថុ និងសុវត្ថិភាពនៃការកាន់កាប់ដី[២២]

ការសន្មត និងការទស្សន៍ទាយផ្សេងៗរបស់អ្នកធ្វើផែនការ ស្តីពីលទ្ធផលរំពឹងទុកនៃកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដី គឺដកស្រង់ចេញពីទ្រឹស្តីទូទៅលើកម្មសិទ្ធិអចលនវត្ថុ ។ កម្មសិទ្ធិអចលនវត្ថុ ជាទូទៅមាននិយមន័យថាជា "សិទ្ធិមួយសំណុំ" ដើម្បីប្រើប្រាស់ ទទួលបានចំណូល និង ចាត់ចែងបញ្ចេញទ្រព្យសកម្មនានា (Barzel, 1989) ។ តំលៃទ្រព្យសកម្មណាមួយ ត្រូវបានកំណត់ជា ១) ផលចំណេញអនាគតរំពឹងទុកនឹងយកបានពីទ្រព្យសកម្ម ២) សុវត្ថិភាពនៃការត្រួតត្រារបស់សាមីជនទៅលើ កម្មសិទ្ធិលើលំហូរផលចំណេញរំពឹងទុក (Alchian and Demsetz, 1973) ។ ប៉ុន្តែ ការប្រើប្រាស់ ការត្រួតត្រា និងកម្មសិទ្ធិលើទ្រព្យសកម្មរូបិយ ដូចជា ដីធ្លី ជាដើម មិនមែនសុទ្ធតែស៊ីសង្វាក់គ្នាទាំងអស់ទេ ។ ឧទាហរណ៍ យើងបានឃើញហើយថា កាលពីមុនឯកត្តជននៅកម្ពុជាមានសិទ្ធិប្រើប្រាស់ដី ដើម្បីធ្វើផលិតកម្ម តែពុំមានសិទ្ធិធ្វើម្ចាស់លើដីធ្លីក្នុងលក្ខណៈជាទំនិញសំរាប់លក់ដូរនោះទេ ។

អភិបាលកិច្ចដីសក្តិសិទ្ធិលើកម្មសិទ្ធិអចលនវត្ថុ តំរូវឱ្យមានប្រព័ន្ធច្បាប់មួយដើម្បីគ្រប់គ្រងលើការចរចា និងពង្រឹងការអនុវត្តន៍កម្មសិទ្ធិ ការប្រើប្រាស់ និងសិទ្ធិត្រួតត្រា ។ ដោយសារវាជាប្រភេទមួយនៃទំនាក់ទំនងមានកិច្ចសន្យា ការដោះដូរកម្មសិទ្ធិអចលនទ្រព្យត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ទាំងស្ថាប័នផ្លូវការ និងក្រៅផ្លូវការ ។ ស្ថាប័នក្រៅផ្លូវការ ដូចជា បែបបទក្នុងសង្គម និងអាកប្បកិរិយារំពឹងទុកដែលកំណត់ដោយក្បួនច្បាប់ខាងវប្បធម៌ (culturally defined codes of expected behaviour) គឺអាចជាមធ្យោបាយគ្រប់គ្រងដ៏សក្តិសិទ្ធិនៅពេលដែលការដោះស្រាយមានលក្ខណៈជាបុគ្គល ដូចនៅតាមភូមិបែបបុរាណៗតាមជនបទកម្ពុជាជាដើម ។

---

[២២] អំណះអំណាងចំពោះកម្មសិទ្ធិអចលនវត្ថុ និងអភិបាលកិច្ចបានដកស្រង់ចេញពី Ballard (2003) ។

ស្ថាប័នផ្លូវការដែលត្រូវមានយន្តការ និងវិធានចងក្រងជាច្បាប់តាមរយៈដំណើរការខាងនយោបាយមួយ វាមានប្រសិទ្ធភាពខ្ពស់ក្នុងពេលដែលការដោះដូរ មានលក្ខណៈស្មុគស្មាញ និងអបុគ្គល (North, 1990) ។ រឿងនេះអាចមើលឃើញតាមការផុសឡើងនៃទីផ្សារដីធ្លីនៅក្នុងតំបន់មានប្រជាជនច្រើន និងមានសន្ទុះសេដ្ឋកិច្ច នៅក្នុង និងជុំវិញទីប្រជុំជន និងទីក្រុងធំៗនៅកម្ពុជា ។

ស្ថាប័នខាងអភិបាលកិច្ច ទាំងផ្លូវការ និងក្រៅផ្លូវការ ក៏សុទ្ធតែស៊ីសង្វាក់គ្នាល្អទេ ដែលនាំឱ្យមានចំណាយខ្ពស់នៅក្នុងដំណើរការលក់ដូរ និងដែលជាប់ទាក់ទិននឹងភាពមិនច្បាស់លាស់ និងភាពតានតឹងរវាងស្ថាប័នមានសមត្ថកិច្ចផ្សេងៗ ក្នុងការកសាង និងការអនុវត្តន៍ច្បាប់កម្មសិទ្ធិអចលនវត្ថុ ។ ភាពមិនច្បាស់លាស់បានកើនឡើងក្នុងពេលធ្វើអន្តរកាលយ៉ាងលឿនក្នុងសេដ្ឋកិច្ច និងសង្គមកិច្ចដ៏លឿន ដែលពិនិត្យឃើញតាមការប្រែប្រួលក្នុងបច្ចេកវិទ្យា ឬក៏រិតថ្លៃនៅមូលដ្ឋាន ដែលប៉ះពាល់ដល់តំលៃរំពឹងទុកនៃទ្រព្យសកម្មសំរាប់បង្កើតទ្រព្យធន ដូចជា ដីធ្លី ជាដើម (Libecap, 1989; North, 1990) ។ ភាពតឹងតែងដែលផ្សារភ្ជាប់នឹងស្ថានភាពមិនច្បាស់លាស់បានបង្កើតតំរូវការ និងឱកាសសំរាប់កំណត់ និងបែងចែកឡើងវិញនូវកម្មសិទ្ធិអចលនទ្រព្យឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងចំណោមសមាជិកសហគមន៍ ក៏ដូចជាពួកអ្នកទាមទារដែលមកពីខាងក្រៅ និងដែលត្រូវបានទាក់ទាញដោយសារការបង្កើតទ្រព្យសកម្មថ្មីៗ ។ ឧទាហរណ៍ដ៏ល្អមួយក្នុងរឿងនេះនៅកម្ពុជា ជាប់ទាក់ទិននឹងប្រជាជនទីក្រុងដែលទិញដីនៅតំបន់ជនបទ ហើយចង់បានប័ណ្ណកម្មសិទ្ធិ ឬប្លង់ដី ជាជាងបង្ហាន់ដៃទទួលពាក្យសុំកាន់កាប់ដី ដើម្បីកសាងសំណុំឯកសារឱ្យបានសមស្រប (So *et al*., 2001) ។

នៅតំបន់ជនបទជាក់លាក់ណាមួយ វិធីផលិតកម្មកសិកម្មបែបយថាផល អាចសំគាល់បានតាមរយៈដង់ស៊ីតេប្រជាជនទាប និងការដាំដុះមានចំនួនតិចដង[២៣] ។ នៅពេលដីមានច្រើនធៀបនឹងចំនួនប្រជាជន កម្មសិទ្ធិអចលនទ្រព្យអាចគ្រប់គ្រងបានយ៉ាងសក្តិសិទ្ធិជាលក្ខណៈក្រៅផ្លូវការនៅកំរិតមូលដ្ឋាន ផ្អែកលើសីលធម៌ និងភាពសមហេតុផលទៅតាមប្រពៃណី និងទំនៀម

[២៣] Boserup (1965) ផ្តល់ការពិភាក្សាជាមុននូវប្រព័ន្ធកសិកម្មយថាផល និងកសិកម្មអតិផល ។

ទំលាប់ ។ វិធីផលិតកម្មកសិកម្មបែបអតិផល អាចសំគាល់បានតាម ដង់ស៊ីតេប្រជាជនខ្ពស់ និងការដាំដុះមានចំនួនច្រើនដង ។ នៅតំបន់ទាំងនេះ ភាពខ្សត់ដីបានបំផុសតំរូវការនូវស្ថាប័នអភិបាលកិច្ចផ្លូវការជាច្រើន ដើម្បីការពារ សិទ្ធិត្រួតត្រា និងសិទ្ធិប្រើប្រាស់ ព្រមទាំងផ្តល់នីតិវិធីអាចដឹងមុនបាន សំរាប់ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ (ដូចជា ការលក់ និងការបន្តមរតក) ។

ដោយសារក្នុងលក្ខណៈជាទ្រព្យមានផលិភាពដីធ្លីបានកើនតំលៃ ដូច្នេះតំរូវការសិទ្ធិកាន់កាប់ជាអចិន្ត្រៃយ៍ និងអាចផ្ទេរកើត បានបង្កើនថែមនូវតំរូវការរចនាសម្ព័ន្ធអភិបាលកិច្ចច្រើនបែបយ៉ាងដែលពឹងផ្អែកលើសិទ្ធិអំណាចរបស់រដ្ឋ ។ ដើម្បីបំរើការងារពិពណ៌នា និងវិភាគ វាមានប្រយោជន៍ច្រើនក្នុងការធ្វើវិភាគលើទីផ្សារដីធ្លីនៅជនបទកម្ពុជា ក្នុងបរិបទនៃការធ្វើអន្តរកាលពី ការធ្វើកសិកម្មបែបយថាផល ទៅកាន់លំនាំប្រើប្រាស់ដីជាលក្ខណៈអតិផលវិញ ។

ដូច្នេះ ហេតុផលដែលគាំទ្រដល់កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដី វាឈរលើទ្រឹស្តីដែលចងភ្ជាប់ការលើកទឹកចិត្តវិនិយោគទុន ទៅនឹងកម្មសិទ្ធិអចលនវត្ថុមានសុវត្ថិភាព ។ ការរីកញែកជាមូលដ្ឋានគឺ ប្រជាជនចូលចិត្តខ្លាំងជាងដើម្បីធ្វើវិនិយោគធនធានក្នុងសហគ្រាសផលិតកម្មផ្សេងៗ បើសិនរូបគាត់ ឬអ្នកស្នងមរតករបស់គាត់ នឹងទទួលបានផលចំណេញពីវិនិយោគទាំងនោះនៅថ្ងៃខាងមុខ ។ ក្នុងវិស័យកសិកម្ម កសិករអាចទទួលបានឥណទានសំរាប់វិនិយោគលើធាតុចូល សំភារៈ ម៉ាស៊ីន និងការកែលំអហេដ្ឋារចនាសម្ព័ន្ធ ។

វិនិយោគទាំងនេះ នាំឱ្យមានកំណើនតំរូវការឥណទាន ។ ក្នុងន័យនេះ គេរំពឹងថា ប័ណ្ណកម្មសិទ្ធិដីនឹងជួយបង្កើនលទ្ធភាពរបស់ប្រជាជនក្នុងការទៅទាក់ទងស្ថាប័នឥណទានផ្លូវការ ។ រឿងនេះមានសារៈសំខាន់ ជាពិសេសដល់ការកាត់បន្ថយភាពក្រីក្រ ពីព្រោះប័ណ្ណកម្មសិទ្ធិដីអាចជួយឱ្យសមាជិកក្រៗក្នុងសហគមន៍ អាចទទួលបានកំចីមានតំលៃទាប សំរាប់បំរើគោលដៅផលិតកម្ម ។ នៅពេលតំរូវការឥណទានកើនឡើង ការផ្គត់ផ្គង់ឥណទានក៏គួររីកធំដែរ ។ ក្នុងរឿងនេះ កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីក៏រំពឹងថាអាចជួយជំរុញឱ្យមានវិស័យសេវាកម្មហិរញ្ញវត្ថុមួយមានប្រសិទ្ធភាពខ្ពស់ ដែលជាកត្តាគន្លឹះសំរាប់កំណើនម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលវែង ។

សំរាប់កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដី ក៏ត្រូវមានកិច្ចប្រឹងប្រែងគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់លើទីផ្សារដីធ្លី ដើម្បីអាចបែងចែកធនធានដ៏កំរនានាទៅប្រើក្នុងវិស័យណាដែលមានផលិតភាពខ្ពស់បំផុត ។ ទីផ្សារដីធ្លីដែលក្នុងនេះមាន ការផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ និតិវិធីមិនអាចទស្សន៍ទាយបាន និងទំនាស់ផ្សេងៗ ដូចជានៅកម្ពុជា គឺពុំមានប្រសិទ្ធភាពខាងសេដ្ឋកិច្ចទេ ដោយសារមានចំណាយខ្ពស់លើការលក់ដូរ ដែលជាប់ទាក់ទិននឹងការចរចា/ការអនុវត្តន៍កម្មសិទ្ធិអចលនវត្ថុ និងការដោះដូរមានកិច្ចសន្យា ។ កម្មសិទ្ធិអចលនវត្ថុដែលមានសុវត្ថិភាពនិងអាចទស្សន៍ទាយបាន វាជួយកាត់បន្ថយភាពមិនច្បាស់លាស់ខាងនីតិវិធី និងជួយផ្តល់ព័ត៌មានកាន់តែច្បាស់ពីតំលៃដីជាក់ស្តែង ។

ទីផ្សារដីធ្លីដែលមានទំនាស់ច្រើន និងអភិបាលកិច្ចមិនសក្តិសិទ្ធិ ក៏ពុំមានប្រសិទ្ធិភាពល្អខាងសង្គមកិច្ចដែរ ។ រឿងនេះធ្ងន់ធ្ងរជាពិសេស ក្នុងករណីប្រជាជនត្រូវបាត់បង់ដី ដោយពុំមានសំណងប៉ះប៉ូវគ្រប់គ្រាន់និងមានយុត្តិធម៌ ហើយពួកគេត្រូវបង្ខំចិត្តធ្វើចំណាកស្រុកទៅកន្លែងផ្សេងដើម្បីស្វែងរកឱកាសធ្វើការយកចំណូល ។ ការខាតបង់ខាងសង្គមកិច្ចជាសក្តានុពលមួយចំនួនទៀត ជាប់ទាក់ទិននឹងការបែងចែកកម្មសិទ្ធិដី ដោយសារដល់យូរៗទៅ ទីផ្សារដីធ្លីដែលកាន់តែមានប្រសិទ្ធភាព អាចនាំឱ្យមានការប្រមូលផ្តុំដីធ្លី នៅក្នុងដៃគ្រួសារមួយចំនួនតូច ។ ការខាតបង់ខាងសង្គមកិច្ចជាប់ទាក់ទិននឹងការបែងចែកបែបនេះ ត្រូវតែប៉ះប៉ូវឡើងវិញតាមរយៈសំណងប៉ះប៉ូវដ៏គ្រប់គ្រាន់និងមានយុត្តិធម៌សំរាប់ដីធ្លី ដ៏ដូចជាឱកាសមានការងារធ្វើដែលអាចធានាជីវភាពបាន និងដែលផុសចេញពីវិនិយោគផ្សេងៗដែលមានផលិតភាពល្អ ។

## ២.៥ វិធីសាស្ត្រស្រាវជ្រាវ

ទំរង់រចនាតាក់តែង គំរោងអង្កេតជាមូលដ្ឋាន (BSP) យកចេញមួយភាគធំពីក្របខ័ណ្ឌស្រាវជ្រាវដែលបានប្រើប្រាស់ក្នុងការសិក្សាពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅថៃ (Onchan and Aungsumalin, 2002) ដោយបានកែសំរួលខ្លះ ដើម្បីបញ្ជាក់មើលលើសម្មតិកម្មជាក់លាក់មួយចំនួនដែលទាក់ទិននឹងកម្ពុជា ។ BSP បានប្រើការរចនាតាក់តែងតាមបែបបទសឹងដកពិសោធន៍ទាំងអស់ (quasi-experimental) ដើម្បីវាយតំលៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច និងសង្គមកិច្ច នៃ

ប័ណ្ណកម្មសិទ្ធិដី ទៅលើគ្រួសារនីមួយៗ ។ ការស្រាវជ្រាវបានរចនាឡើងតាមវិធីមួយ ដើម្បីផ្តល់ការវិភាគប្រៀបធៀប រវាងបំរែបំរួលនៅក្នុងក្រុមធ្វើពិសោធន៍ និងក្រុមត្រួតពិនិត្យ និងរវាងចំនុចពេលវេលាពីរ (ដូចជា មុនធ្វើគំរោង និងក្រោយធ្វើគំរោង):

OCt0 = តំលៃអាំងឌីកាទ័រ/ខ្នាតរង្វាស់ នៃក្រុមត្រួតពិនិត្យមុនពេលចេញប័ណ្ណកម្មសិទ្ធិដី

OCt3 = តំលៃអាំងឌីកាទ័រ/ខ្នាតរង្វាស់ នៃក្រុមត្រួតពិនិត្យក្រោយពេលចេញប័ណ្ណកម្មសិទ្ធិដី

OEt0 = តំលៃអាំងឌីកាទ័រ/ខ្នាតរង្វាស់ នៃក្រុមពិសោធន៍មុនពេលចេញប័ណ្ណកម្មសិទ្ធិដី

OEt3 = តំលៃអាំងឌីកាទ័រ/ខ្នាតរង្វាស់ នៃក្រុមពិសោធន៍ក្រោយពេលចេញប័ណ្ណកម្មសិទ្ធិដី

ដូចការសិក្សានៅថៃដែរ វិធីសាស្ត្រជាមូលដ្ឋានសំរាប់ធ្វើវិភាគ គឺ ប្រៀបធៀបបំរែបំរួលជាភាគរយ រវាងក្រុមពិសោធន៍ និងក្រុមត្រួតពិនិត្យ ដូចខាងក្រោម:

$$\frac{OEt3 - OEt0}{OEt0} \times 100 \quad \text{ធៀបនឹង} \quad \frac{OCt3 - OCt0}{OCt0} \times 100$$

ក្នុងករណីមួយចំនួន យើងក៏អាចចង់ធ្វើវិភាគទិន្នន័យដោយក្នុងនោះ:

$$\frac{OEt3}{OCt3} \quad \text{ខុសគ្នាយ៉ាងច្រើនពី} \quad \frac{OEt0}{OCt0}$$

ការសិក្សានៅថៃ បានធ្វើសម្មតិកម្មថា "បំរែបំរួលនៅក្នុងក្រុមពិសោធន៍ ដែលខុសគ្នាពីក្រុមពិនិត្យ ត្រូវបានចាត់ទុកថាជាផលប៉ះពាល់នៃគំរោង" ។ ប៉ុន្តែ វាមិនទំនងសោះដែលប័ណ្ណកម្មសិទ្ធិដីតែមួយមុខ អាចបង្កើតផលប៉ះពាល់គួរកត់សំគាល់នៅក្នុងចំណុចនានាដូចមានបញ្ជាក់នៅខាងលើ ។ ដូច្នេះ គេចាំបាច់ត្រូវពិនិត្យពីបែបបទដែលប័ណ្ណកម្មសិទ្ធិដីមានអន្តរកម្មជាមួយ

ឬទៅបំពេញឱ្យកត្តាផ្សេងៗទៀត ដើម្បីបង្កើតបាននូវការខុសប្លែកគ្នានានាដែលគេអាចសង្កេតឃើញ ។ ឧទាហរណ៍ ដើម្បីឱ្យប័ណ្ណកម្មសិទ្ធិដីអាចបង្កើនលទ្ធភាពរបស់ប្រជាជនក្នុងការទទួលបានឥណទានផ្លូវការ គឺស្ថាប័នឥណទានបែបនេះត្រូវតែអាចទៅទាក់ទងបានយ៉ាងជាក់ស្តែង ។ ផលប៉ះពាល់នៃវិនិយោគខាងកសិកម្ម ក៏ត្រូវបានពង្រឹងឡើងដោយសារការទទួលបានព័ត៌មានបច្ចេកវិទ្យា និងទីផ្សារកាន់តែប្រសើរដែរ ។ ក្នុងន័យនេះ ការមានសេវាផ្សព្វផ្សាយបច្ចេកទេសខាងគ្រាប់ពូជ សត្វ ការនេសាទ គឺជាអថេរមួយដ៏សំខាន់។ យោងតាមទស្សនៈនេះ ប័ណ្ណកម្មសិទ្ធិដី អាចដើរតួជាកាតាលីករ ធ្វើអោយមានបំរែបំរួលបាន បើសិនមានកត្តា និងកាលទេសៈអំណោយផលផ្សេងទៀតគួបផ្សំផង ។

គំរូជាមូលដ្ឋាននៅថៃ ក៏ត្រូវបានកែសំរួល ដើម្បីសំរបតាមកាលៈទេសៈខាងសេដ្ឋកិច្ច-សង្គមកិច្ចនៅជនបទកម្ពុជា និងគោលដៅអភិវឌ្ឍន៍ដែលកំពុងអនុវត្តទៅមុខ ដោយគួបផ្សំនឹងការកាត់បន្ថយភាពក្រីក្រ និងការបញ្ជ្រាបបញ្ហាយេនឌ័រ ។ ដោយសារកំណើនភាពខុសគ្នាក្នុងលទ្ធភាពបានប្រើប្រាស់ និងបានត្រួតត្រា លើធនធាននិងទ្រព្យសម្បត្តិក្នុងតំបន់ជនបទ ការវិភាគពីផលប៉ះពាល់នៃប័ណ្ណកម្មសិទ្ធិដីត្រូវតែយកចិត្តទុកដាក់ទៅលើការបែងចែកផលចំណេញ ។ ដូច្នេះ ដើម្បីបំរើការងារវិភាគ ទិន្នន័យគ្រួសារត្រូវបានបំបែកលំអិតទៅតាម ទំហំដីកាន់កាប់ និងយេនឌ័រមេគ្រួសារ ។

## *២.៥.១ ការជ្រើសរើសទីតាំង*

ការជ្រើសរើសខេត្ត LMAPទាំង ៤ យកមកសិក្សា គឺផ្អែកទៅលើកត្តាផ្សេងៗដូចជា ទីតាំងជាយុទ្ធសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ ផ្លូវ) ប្រព័ន្ធកសិកម្ម និងនិន្នាការអភិវឌ្ឍន៍ដែលអាច មានផលប៉ះពាល់លើទីផ្សារដីធ្លី និងលំនាំនៃការប្រើប្រាស់ដី ។

ក្រុងព្រះសីហនុត្រូវបានជ្រើសយក ដោយសារមានទីតាំងជាយុទ្ធសាស្ត្រនៅក្នុងតំបន់អភិវឌ្ឍន៍តាមដងផ្លូវជាតិលេខ ៤ និងដោយសារទេសចរណ៍ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ ការអភិវឌ្ឍន៍កំពង់ផែ) នឹងមានផលប៉ះពាល់ដ៏ជ្រាលជ្រៅទៅលើទីផ្សារដីធ្លីនៅតំបន់នោះ ។ ខេត្តតាកែវ ត្រូវបានជ្រើសយក ដោយសារមានការធ្វើស្រែតាមបែបប្រពៃណី

ដូចៗគ្នាគួរសម និងនៅតាមផ្លូវជាតិលេខ២ ជិតក្រុងភ្នំពេញ ដែលអាចជាប្រភពគំរូការដែលជួយជំរុញឡើងនូវប្រព័ន្ធកសិកម្មចំរុះមុខ និងមានផលច្រើននៅថ្ងៃអនាគត បើសិនកសិករទទួលបានគាំទ្រ និងសេវាផ្សព្វផ្សាយបច្ចេកទេសទាន់ពេល និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ ខេត្តកំពង់ចាម ត្រូវបានជ្រើសយកដោយសារមានទីតាំងជាយុទ្ធសាស្ត្រនៅតាមផ្លូវជាតិលេខ ៦ និងមានស្ពានមិត្តភាពកម្ពុជា-ជប៉ុន ឆ្លងកាត់ទន្លេមេគង្គ ដែលតភ្ជាប់តំបន់ពាយព្យកម្ពុជាទៅនឹងតំបន់ឯទៀតៗ ព្រមទាំងជាច្រកផ្លូវសំរាប់បញ្ជូនផលិតផលកម្ពុជាជាច្រើនទៅទីផ្សារ និងកំពង់ផែនៅវៀតណាម ។ ខេត្តកំពង់ធំត្រូវបានជ្រើសយក ដោយសារស្ថិតនៅឆ្ងាយពីភ្នំពេញ និងទីតាំងជាយុទ្ធសាស្ត្រនៅតាមផ្លូវជាតិលេខ ៦ ដែលភ្ជាប់ខេត្តសៀមរាប ទៅក្រុងភ្នំពេញ ។ ទេសចរណ៍ និងចរាចរពាណិជ្ជកម្មតាមផ្លូវជាតិ ប្រហែលនឹងកើនឡើងក្រោយពេលមានការកែលំអ[២៤] ។

ការជ្រើសយកទីតាំងឃុំ គឺយោងមួយភាគធំទៅតាមទីតាំង និងកម្មវិធីធ្វើការ នៃគំរោង LMAP ។ ជាទូទៅ ក្នុងមួយឃុំ មានជ្រើសយក ៤ភូមិ ដោយផ្អែកទៅតាមការពិភាក្សាជាមួយសមាជិកក្រុមប្រឹក្សាឃុំ និងមេភូមិ ។ លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសភូមិ រួមមាន ការអភិវឌ្ឍន៍ និងសកម្មភាពទីផ្សារដីធ្លី ការប្រើប្រាស់ដី និងប្រព័ន្ធកសិកម្ម (ឧទាហរណ៍ ការធ្វើស្រែប្រាំង/វស្សា ចំការ ដំណាំដើមឈើ) ហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ ផ្លូវ ប្រព័ន្ធធារាសាស្ត្រ) ដង់ស៊ីតេប្រជាជន ទីតាំងនៅជិត និងលទ្ធភាពចេញចូលទីផ្សារ និងទីតាំងរដ្ឋបាល និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត (ឧទាហរណ៍ មុខរបរ) ។

សរុបមក បានធ្វើសំភាសន៍ ៩៧០គ្រួសារ និងធ្វើអង្កេតលើ ៣២ភូមិ ក្នុង ៤ខេត្ត LMAP ដែលបានធ្វើអង្កេត ។ ក្នុងមួយភូមិៗ បានជ្រើសយកប្រហែល ៣០គ្រួសារអ្នកមានដីកសិកម្ម

---

[២៤] ខេត្តកំពង់ឆ្នាំង ត្រូវបានជ្រើសយកជាខេត្តសំរាប់បំរើការត្រួតពិនិត្យ ដោយសារជាសំខាន់ ទីតាំងជាយុទ្ធសាស្ត្រនៅតាមផ្លូវជាតិលេខ ៥ និងនៅជិតក្រុងភ្នំពេញ ។ សង្ខេបគំហើញពីខេត្តកំពង់ឆ្នាំងមានចុះនៅក្នុងរបាយការណ៍អង្កេតជាមូលដ្ឋាន ដែលនឹងចេញផ្សាយក្នុងពេលឆាប់ៗ ។

ប៉ុន្តែជួនកាលតួលេខនេះប្រែប្រួលខ្លះទៅតាមទំហំភូមិ ។ វិធីសាស្ត្រ ៤ ខុសៗគ្នា បានយកមកប្រើប្រាស់ក្នុងការជ្រើសរើសគ្រួសារតាមវិធីចៃដន្យ ដើម្បីឆ្លើយតបនឹងបរិមាណ និងគុណភាពព័ត៌មានខុសៗគ្នាដែលអាចប្រមូលបាននៅកំរិតភូមិ ។ វិធីសាស្ត្រទាំងនេះ គឺមាន ក) ការជ្រើសរើសគ្រួសារដោយផ្អែកលើទំហំផ្ទៃដីកាន់កាប់ ខ) ចំនួនដីឡូត៍ គ) ការចុចយកគ្រួសារ ក្នុងចន្លោះជាក់លាក់ណាមួយពីក្នុងបញ្ជីភូមិ និង ឃ) ការចុចយកផ្ទះនៅក្នុងភូមិ ក្នុងចន្លោះជាក់លាក់ណាមួយ ។

ថ្វីបើ BSP ផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើគ្រួសារដែលមានទាំងដីលំនៅដ្ឋាន និងកសិកម្មក្តី ក៏ BSP បានសំភាសគ្រួសារអ្នកគ្មានដីកសិកម្មឱ្យបានច្រើន (សរុប ៥៤គ្រួសារ) ក្នុងក្របខ័ណ្ឌពេលវេលាអាចធ្វើទៅបាន នៅក្នុងតារាងពេលការងារ ។ ដោយមានការយល់ឃើញជាទូទៅថា ស្ត្រីមេគ្រួសារ ស្ថិតក្នុងក្រុមអ្នកងាយរងគ្រោះជាងគេក្នុងសង្គមកម្ពុជា ដូច្នេះមានកិច្ចប្រឹងប្រែងពិសេសដើម្បីធានាថា ក្រុមនេះមានតំណាងយ៉ាងសមស្របនៅក្នុងគំរូតាងអង្កេតជនបទ ។ ផ្អែកលើចំនួនស្ត្រីមេគ្រួសារក្នុងភូមិនីមួយៗដែលបានរាយការណ៍ ចំនួនសមស្របមួយក៏ត្រូវបានជ្រើសយកមកធ្វើសំភាសន៍ ដោយបានសំភាសស្ត្រីមេគ្រួសារទាំងអស់ ២២៥នាក់ ក្នុងតំបន់ LMAP ដែលបានធ្វើអង្កេត ។

## ២.៦ ស្ថានភាពកាន់កាប់ដីបច្ចុប្បន្ន

ខាងក្រោមនេះ គឺជាការពិភាក្សាទិន្នន័យគ្រួសារ ដែលផ្តោតលើទំហំកាន់កាប់ដីកសិកម្ម ទំហំដីលំនៅដ្ឋាន និង ទ្រព្យសកម្មរបស់គ្រួសារ ទាំងសំរាប់គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។

### *២.៦.១ ការកាន់កាប់ដីលំនៅដ្ឋាន*

ក្នុងចំណោម ៩៧០គ្រួសារនៅក្នុងតំបន់សិក្សា LMAP មាន ៩១៧គ្រួសារ (ប្រហែល ៩៤,៥%) មានដីលំនៅដ្ឋានជាមធ្យម ១,១ឡូត៍ ក្នុងនេះគឺមាន ៤៩គ្រួសារស្ថិតក្នុងចំណោមប្រជាជន ៥៤គ្រួសារដែលគ្មានដីកសិកម្ម។ ក្នុងចំណោម ៥៣គ្រួសារដែលរាយការណ៍ថាគ្មានដីលំនៅដ្ឋាន គឺមាន ១៣គ្រួសារដែលគ្មានទាំងដីកសិកម្ម, ២១គ្រួសារមានដីកសិកម្មតិចជាង 0,៥ហ.ត និង ១១គ្រួសារមានដីកសិកម្មតិចជាងឬស្មើនឹង ១ហ.ត។ ក្នុងន័យនេះ ភាគរយគ្រួសារអ្នកមាន

ដីលំនៅដ្ឋាន បានកើនឡើងស្របគ្នានឹងទំហំដីកសិកម្មកាន់កាប់ ។ ភាគរយគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ដែលមានដីលំនៅដ្ឋាន មានកំរិតប្រហែល១គ្នាក្នុងគ្រប់ទំហំដីកាន់កាប់ ។

គ្រួសារប្រហែល ៣៩,៣% ទទួលបានដីលំនៅដ្ឋានរបស់ខ្លួនពីរដ្ឋ និង ៣៤,៨% ទទួលបានដីលំនៅដ្ឋានតាមការបន្តមរតក ។ ១៧,៦% ផ្សេងទៀតបានទិញដីលំនៅដ្ឋានរបស់ខ្លួន ហើយ ៦,៨% ទទួលបានដីលំនៅដ្ឋានដោយការរានដី ។ ភាគរយដីឡូត៍លំនៅដ្ឋានទទួលបានពីរដ្ឋ ជាទូទៅកើនឡើងស្របគ្នានឹងទំហំដីកាន់កាប់ ប៉ុន្តែភាគរយដីទទួលបានតាមការបន្តមរតក គឺថយចុះ។ ភាគរយដីទទួលបានតាមការទិញ ស្ទើរតែនៅថេរសំរាប់គ្រប់ទំហំដីកាន់កាប់ លើកលែងតែចំពោះគ្រួសារគ្មានដីកសិកម្ម ដែលបានទិញដីឡូត៍លំនៅដ្ឋានរបស់ខ្លួន ៤៦,២% ។ រឿងនេះបង្ហាញថា អ្នកអត់ដីជាច្រើន (គឺ គ្មានដីកសិកម្ម) នៅក្នុងក្រុមបានធ្វើអង្កេតរបស់ LMAP អាចមិនដែលទទួលបានដីលំនៅដ្ឋានពីរដ្ឋសោះ ឬក៏បានបាត់បង់ដីពីដំបូងរបស់ខ្លួន ហើយក្រោយមកក៏ទិញដីមួយឡូត៍ផ្សេងទៀត ។ ភាគរយដីឡូត៍លំនៅដ្ឋានដែលទទួលបានតាមការរានដី (១១,១%) មានកំរិតខ្ពស់បំផុត ក្នុងចំណោមគ្រួសារដែលកាន់កាប់ដីធំជាងគេ ។

បើគិតតាមយេនឌ័រមេគ្រួសារ គ្រួសារស្ត្រីមេគ្រួ និងគ្រួសារបុរសមេគ្រួ ប្រហែល ៥១,៦% និង ៣៥,៣% រៀងគ្នាទទួលបានដីលំនៅដ្ឋានរបស់ខ្លួនពីរដ្ឋ ។ ភាគរយគ្រួសារស្ត្រីមេគ្រួ គឺខ្ពស់ជាងគ្រួសារបុរសមេគ្រួ នៅក្នុងចន្លោះដីកាន់កាប់នីមួយៗ ។ ប៉ុន្តែចំពោះដីលំនៅដ្ឋានទទួលបានតាមការបន្តមរតកវិញ គឺមានលក្ខណៈផ្ទុយគ្នា។ មានគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ៣៧,៧% និង ២៥,៨% រៀងគ្នា ដែលទទួលបានដីលំនៅដ្ឋានតាមការបន្តមរតក ហើយរឿងនេះនៅតែដូច្នេះសំរាប់រាល់ចន្លោះដីកាន់កាប់នីមួយៗ ។ សំរាប់ដីលំនៅដ្ឋានទទួលបានតាមការទិញ ក៏មានលំនាំស្រដៀងគ្នាដែរ (លើកលែងតែសំរាប់ទំហំដីកាន់កាប់ធំៗបំផុត ដែលមានការប្រែប្រួលតិចតួច) ។ រឿងគួរចម្លែកគឺ គ្រួសារស្ត្រីមេគ្រួដែលរាយការណ៍ថាបានទទួលដីលំនៅដ្ឋានតាមការរានដី គឺមានភាគរយធំជាង គ្រួសារបុរសមេគ្រួដែលបានរាយការណ៍ដូចគ្នា ។ តាមការសមហេតុផល គេគួររំពឹងថា មានភាគរយខ្ពស់ជាងនៃគ្រួសារបុរសមេគ្រួដែល

ទទួលបានដីលំនៅដ្ឋានតាមការវានដី ដោយយោងតាមធនធានពលកម្មជាសក្តានុពលដែលសំបូរជាងរបស់ពួកគេ (សូមមើល តារាង២.៤) ។

## *២.៦.២ ការកាន់កាប់ដីកសិកម្ម និងទ្រព្យសកម្ម*

គំរូតាងអង្កេត LMAP បង្ហាញថា អ្នកកាន់កាប់ដីធំៗ មានចំណែកដីកសិកម្មច្រើនហួសពេក ។ ឧទាហរណ៍ គ្រួសារមានដីតិចជាង ០,៥ហ.ត តំណាងឱ្យ ២១,៩%នៃគំរូតាងអង្កេត ប៉ុន្តែមានត្រឹម ៣,៨%នៃផ្ទៃដីប៉ុណ្ណោះ ។ គ្រួសារមានដីតិចជាង ១ហ.ត តំណាងឱ្យ ៤៦,២%នៃគំរូតាងតែកាន់កាប់ដីត្រឹម ១៤,៥% ។ ផ្ទុយទៅវិញ គ្រួសារមានដី ៣ហ.ត ឬច្រើនជាង តំណាងឱ្យ ១៤,៤%នៃគ្រួសារទាំងអស់ ប៉ុន្តែកាន់កាប់ដីដល់ ៤៣,៤%។ គ្រួសារមានដី ២ហ.ត ឬច្រើនជាង តំណាងឱ្យ ២៧,៧%នៃគ្រួសារទាំងអស់ ប៉ុន្តែកាន់កាប់ដីកសិកម្មដល់ ៦៣,៥% ។

ចំណុចគួរចាប់អារម្មណ៍មួយទៀតក្នុងទិន្នន័យអង្កេត គឺគ្រួសារមានដីកាន់កាប់តិច គឺដីឡូតិ៍កសិកម្មតិចឡូតិ៍ជាង និងជាឡូតិ៍តូចៗជាង បើធៀបនឹងគ្រួសារមានដីកាន់កាប់ធំៗ ដែលមានច្រើនឡូតិ៍ជាង និងជាដីឡូតិ៍ធំៗជាង ។ តារាង ២.១ បង្ហាញថា ចំនួននិងទំហំដីឡូតិ៍ កើនឡើងយ៉ាងទៀងទាត់ ពីចន្លោះដីកាន់កាប់មួយ ទៅចន្លោះមួយទៀត។ លំនាំនេះមានលក្ខណៈស៊ីគ្នាល្អ ស្ទើរគ្រប់ភូមិ ហើយចំពោះភូមិក្រៅពីនេះក៏មានការប្រែប្រួលខុសគ្នាតិចតួចទេ ពីលំនាំជាទូទៅនេះ ។

**តារាង ២.១: សង្ខេបអំពីការកាន់កាប់ដីកសិកម្មតាមគ្រួសារ ជាហិកតា**

| ដីកាន់កាប់ | ចំនួន គ្រួ | ដីឡូតិ៍សរុប | ផ្ទៃដីសរុប | ផ្ទៃដី/គ្រួ | ដីឡូតិ៍/គ្រួ | ផ្ទៃដី/ឡូតិ៍ |
|---|---|---|---|---|---|---|
| | | | | | | |
| <0.5 (ha) | 201 | 465 | 55.37 | 0.27 | 2.31 | 0.11 |
| 0.5 – 0.9 | 223 | 843 | 156.11 | 0.70 | 3.78 | 0.18 |
| 1.0 – 1.9 | 229 | 1,092 | 322.66 | 1.41 | 4.76 | 0.29 |
| 2.0 – 2.9 | 122 | 653 | 294.25 | 2.41 | 5.35 | 0.45 |
| >3.0 (ha) | 132 | 826 | 634.50 | 4.80 | 6.25 | 0.76 |
| | | | | | | |
| គំរូតាងសរុប | 917 | 3,879 | 1,462.89 | 1.59 | 4.23 | 0.37 |

ការពន្យល់ដែលមានលើកឡើងជារឿយៗសំរាប់លំនាំនេះ គឺចាប់ផ្តើមពីការបែងចែកដីនៅឆ្នាំ១៩៨៩ ដែលមានការប្រឹងប្រែងបែងចែកឱ្យបានស្មើៗគ្នានូវដីមានគុណភាពល្អ (កំណត់តាមផលិតភាព និងទីតាំង) ទៅតាមចំនួនសមាជិកគ្រួសារដែលគ្រប់អាយុធ្វើការ ។ យោងតាមរូបមន្តនេះ គ្រួសារដែលមានសមាជិកធ្វើការច្រើនគឺទទួលបានដីឡូត៍បន្ថែមទៀតក្នុងនេះឡូត៍ខ្លះអាចមានគុណភាពអន់ជាង ប៉ុន្តែមានទំហំធំជាង ។ ជាលទ្ធផល មានការខុសគ្នាជារចនាសម្ព័ន្ធរួចទៅហើយក្នុងពេលបែងចែកដីនៅឆ្នាំ១៩៨៩ បើសិនពិនិត្យពីទំហំដីកាន់កាប់តាមគ្រួសារ[២៥] ។

កេរ្តិ៍ដំណែលនៃការបែងចែកដីនៅឆ្នាំ១៩៨៩ បានឆ្លុះបញ្ចាំងពីការពិតដែលគ្រួសារជាង ៥៥% បានទទួលដីកសិកម្មរបស់ខ្លួនពីរដ្ឋ ។ ប៉ុន្តែ ទិន្នន័យស្តីពីបែបបទទទួលបានដី ក៏បង្ហាញផងដែរថា តើគ្រួសារដែលមានដីកាន់កាប់ពីដំបូងធំៗរួចទៅហើយ ធ្វើយ៉ាងណាតាំងពីនោះមកដើម្បីទទួលបានដីបន្ថែមទៀត ។ ឧទាហរណ៍ ទិន្នន័យបង្ហាញថា គ្រួសារធំៗមានកំលាំងពលកម្មក្នុងគ្រួសារច្រើន មានលទ្ធភាពច្រើនជាងក្នុងការពង្រីកដីកាន់កាប់ជាបណ្តើរៗ តាមការរានដីបន្ថែមទៀត (តារាង ២.២) ។ សេចក្តីនេះ ត្រូវបានគាំទ្រដោយទិន្នន័យក្នុងតារាង២.៣ ដែលបង្ហាញថា គ្រួសារអ្នកមានដីកាន់កាប់ច្រើន គឺមានពលកម្មជាសក្តានុពល និងទ្រព្យសកម្មច្រើនច្រើនជាង សំរាប់ធ្វើការរានដីបន្ថែម ។

**តារាង ២.២: បែបបទទទួលបានដី (ភាគរយដីឡូត៍សរុប)**

| ទំហំដី | រដ្ឋ | បន្តមរតក | ទិញ | រានដី | សរុប |
|---|---|---|---|---|---|
| <0.5 | 52.9 | 33.6 | 11.6 | 1.9 | 467 |
| 0.5 – 0.99 | 57.2 | 23.5 | 15.9 | 3.2 | 844 |
| 1.0 – 1.9 | 62.5 | 18.6 | 13.6 | 5.3 | 1,095 |
| 2.0 – 2.9 | 55.2 | 17.5 | 16.4 | 10.8 | 659 |
| >3.0 | 46.6 | 20.8 | 17.5 | 15.2 | 824 |
| ចំនួនសរុប N | 2,162 | 845 | 589 | 290 | 3,886 * |
| %នៃចំនួនសរុប | 55.6 | 21.7 | 15.2 | 7.4 | |

** ដកចេញn = 3, មិត្តភ័ក្តិផ្តល់ឱ្យ ។*

[២៥] ការពន្យល់នេះផ្អែកទៅលើការពិភាក្សាតាមក្រុមស្នូល ជាមួយសមាជិកក្រុមប្រឹក្សាឃុំ និងមេភូមិ និងជាមួយមន្ត្រី LMAP ប្រចាំខេត្ត ។

តារាង២.៣ ក៏បង្ហាញដែរថា ជាមធ្យម គ្រួសារធំៗមានទ្រព្យជាមូលធន និងចំណូលច្រើនជាងថែមទៀត ក្រៅពីកំលាំងពលកម្មជាសក្តានុពលច្រើន ។ រឿងនេះបង្ហាញថា គ្រួសារមានធនធានច្រើន គឺមានលទ្ធភាពទិញដីបន្ថែម ច្រើនជាងអ្នកកាន់កាប់ដីតូចៗ ។ សេចក្តីនេះក៏ត្រូវបានគាំទ្រដែរដោយទិន្នន័យក្នុងតារាង២.២ ដែលបង្ហាញថា គ្រួសារធំៗ មានកំរិតភាគរយនៃការទទួលបានដីតាមរយៈការទិញខ្ពស់ជាង បើធៀបនឹងគ្រួសារតូចៗ ។ ក្នុងន័យនេះ ការលក់ដូរដីធ្លី ហាក់ដូចបានដើរតួនាទីសំខាន់ក្នុងការពង្រីកគំលាតពីដំបូងក្នុងទំហំដីកាន់កាប់ ក្នុងចំណោមគ្រួសារនៅជនបទ ។

ការពន្យល់ម្យ៉ាងទៀត សំរាប់លំនាំបែងចែកដីឡូត៍ដែលបានសង្កេតឃើញ គឺការពុះបំបែកដីតាមការលក់ និង/ឬការបន្តមរតក ដូចមានលើកឡើងក្នុងការសិក្សាឯទៀត (ឧទាហរណ៍ Biddulph, 2004) ។ នៅកំរិតការលក់ដូរក្នុងមូលដ្ឋាន គ្រួសារធំៗទិញដីឡូត៍បន្ថែមពីគ្រួសារតូចៗដែលលក់ដី ដើម្បីដោះស្រាយវិបត្តិគ្រួសារ ឬមូលហេតុផ្សេងទៀត ។ ក្នុងចំណោមគ្រួសារមានដីតូចៗ ទំហំនិងចំនួនដីឡូត៍ក៏ថយចុះដែរ ដោយសារការពុះបំបែកដីឡូត៍ដើម្បីចែកឱ្យកូន ។ ការអះអាងនេះក៏ត្រូវបានគាំទ្រដោយទិន្នន័យក្នុងតារាង២.២ ដែលបង្ហាញពីចំនួនដ៏ច្រើននៃការទទួលបានដីតាមរយៈការបន្តមរតក ក្នុងចំណោមគ្រួសារដែលមានដីកាន់កាប់តូចៗ ។

**តារាង ២.៣: ទ្រព្យសកម្ម* និងពលកម្ម ** ក្នុងគ្រួសារ**

| ការកាន់កាប់ដី | បសុសត្វ | ទ្រព្យជាប់លាប់ | ទ្រព្យមិនមែនកសិកម្ម | ទ្រព្យកសិកម្មមិនមែនម៉ាស៊ីន | ទ្រព្យកសិកម្មជាម៉ាស៊ីន | ពលកម្មគ្រួសារ |
|---|---|---|---|---|---|---|
| | | | | | | |
| <0.5 | 85.69 | 33.31 | 18.31 | 3.58 | 6.65 | 3.3 |
| 0.5 – 0.9 | 149.22 | 39.96 | 8.82 | 9.86 | 17.87 | 4.1 |
| 1.0 – 1.9 | 186.88 | 52.47 | 18.90 | 13.67 | 30.72 | 4.0 |
| 2.0 – 2.9 | 220.04 | 47.78 | 11.46 | 21.98 | 37.21 | 4.8 |
| >3.0 | 318.83 | 58.38 | 24.34 | 37.59 | 43.61 | 5.0 |
| | | | | | | |
| សរុប | 179.45 | 45.49 | 16.63 | 15.75 | 25.78 | 4.1 |

* *ម៉ឺនរៀល*

** *ពលកម្មគ្រួសារជាសក្តានុពលរួមទាំងស្ត្រី និងបុរស អាយុពី ១០-៦០ឆ្នាំ យោងតាម CSES of Cambodia ។*

យុទ្ធសាស្ត្រដែលប្រជាជនប្រើពេលទិញឬលក់ដី និងធ្វើសេចក្តីសំរេចចិត្តពីការបន្តមរតក ត្រូវមានការសិក្សាបន្ថែមទៀត ។ បើមើលតែមួយគ្រួស គេហាក់ឃើញថា គ្រួសារធំៗទិញដីពីគ្រួសារតូចៗ ដើម្បីពង្រីក និងប្រមូលផ្តុំដីកាន់កាប់ ហើយអ្នកមកពីក្រៅសហគមន៍គេទិញដីដោយផ្អែកលើទីតាំងដែលមានទីផ្សារ (ឧទាហរណ៍ មានផ្លូវទៅដល់) ។ ទន្ទឹមនោះ អ្នកកាន់កាប់ដីតូចៗលក់ដីដើម្បីយកប្រាក់បំរើតំរូវការ ។ ជារឿយៗ ដីកសិកម្មគឺជាទ្រព្យចុងក្រោយដែលត្រូវលក់ (លើកលែងតែដីលំនៅដ្ឋាន) ហើយសេចក្តីសំរេចអំពី ដីណាត្រូវលក់ ឬក៏ត្រូវកាត់លក់ គឺជាប់ទាក់ទងនឹងតំរូវការប្រាក់នៅពេលនិមួយៗ ។ ដោយអ្នកកាន់កាប់ដីតូចៗ លក់ដីម្តងមួយឡូត៍ៗ គេបានកាត់បន្ថយសមត្ថភាពផលិតកម្ម ដែលរុញច្រានខ្លួនគេយ៉ាងលឿនទៅរកភាពគ្មានដីធ្លី ។

## ២.៦.៣ យេនឌ័រមេគ្រួសារ

ទិន្នន័យគួរចាប់អារម្មណ៍ផ្សេងទៀត ទាក់ទិននឹងទំនាក់ទំនងរវាង ក) ទំហំកាន់កាប់ដី ការទទួលបានដី ចំនូលនិងទ្រព្យសកម្មគ្រួសារ និងធនធានពលកម្ម និង ខ) យេនឌ័រមេគ្រួសារ ។ ជាទូទៅ លំនាំដូចដែលសង្កេតឃើញនៅខាងលើ ទាក់ទិននឹងការបែងចែកដីឡូត៍ក្នុងតំបន់អង្កេតរបស់ LMAP គឺមានលក្ខណៈត្រឹមត្រូវទាំងសំរាប់គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។ ប៉ុន្តែ

គ្រួសារស្ត្រីមេគ្រួមានដីជាមធ្យមក្នុងមួយគ្រួសារត្រឹម ៣,៧៨ឡូតិ៍ ទំហំ ០,៣០ ហ.ត/ឡូតិ៍ រីឯគ្រួសារបុរសមេគ្រួមានដល់ ៤,៤៤ឡូតិ៍ ទំហំ ០,៣៩ហ.ត/ឡូតិ៍ (តារាង ២.៤) ។

ទិន្នន័យក៏បង្ហាញដែរថា គ្រួសារស្ត្រីមេគ្រួ ៣៨% កាន់កាប់ដីកសិកម្មតិចជាង ០,៥ហ.ត ហើយគ្រួសារបុរសមេគ្រួ ១៨% កាន់កាប់តិចជាង ០,៥ហ.ត ។ ម្យ៉ាងទៀត គ្រួសារស្ត្រីមេគ្រួ ៦០% កាន់កាប់ដីតិចជាង ១ហ.ត ហើយគ្រួសារបុរសមេគ្រួ ៤២% កាន់កាប់តិចជាង ១ហ.ត ។ ផ្ទុយទៅវិញ ១៧% នៃគ្រួសារស្ត្រីមេគ្រួកាន់កាប់ដីច្រើនជាង ២ហ.ត ហើយ ៣១% នៃគ្រួសារបុរសមេគ្រួ កាន់កាប់ដីច្រើនជាង ២ហ.ត ។

**តារាង ២.៤: សង្ខេបដីកសិកម្មតាមយេនឌ័រ**

| ទំហំដី | ចំនួនគ្រួសារ * | | ដីឡូតិ៍ * | | ផ្ទៃដី | | ផ្ទៃដី /គ្រួសារ | | ដីឡូតិ៍/គ្រួសារ | | ផ្ទៃដី/ឡូតិ៍ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| | | | | | | | | | | | | |
| <0.5 | 123 | 78 | 281 | 184 | 34.9 | 20.5 | 0.28 | 0.26 | 2.28 | 2.36 | 0.12 | 0.11 |
| 0.5–0.99 | 164 | 59 | 616 | 227 | 114.9 | 41.2 | 0.70 | 0.69 | 3.78 | 3.89 | 0.18 | 0.18 |
| 1.0–1.99 | 180 | 49 | 876 | 216 | 253.7 | 69.0 | 1.40 | 1.40 | 4.86 | 4.40 | 0.28 | 0.31 |
| 2.0–2.99 | 102 | 20 | 540 | 113 | 248.4 | 45.9 | 2.43 | 2.29 | 5.29 | 5.65 | 0.46 | 0.40 |
| >3.0 | 113 | 19 | 714 | 112 | 547.3 | 87.2 | 5.36 | 4.59 | 6.32 | 5.89 | 0.76 | 0.77 |
| | | | | | | | | | | | | |
| សរុប | 682 | 225 | 3,027 | 852 | 1,199 | 263.8 | 1.75 | 1.17 | 4.44 | 3.78 | 0.39 | 0.30 |

**ដកចេញ ៩ គ្រួសារ, ដកចេញ ១៣ ដីឡូតិ៍*

បែបបទទទួលបានដី ក៏បង្ហាញពីកត្តាសំខាន់ៗជាច្រើននៃទំនាក់ទំនងរវាង យេនឌ័រមេគ្រួសារ និងដីកាន់កាប់ ។ ឧទាហរណ៍ គ្រួសារស្ត្រីមេគ្រួ មានភាគរយ (៧០,៩%) នៃការទទួលបានដីពីអាជ្ញាធររដ្ឋ ខ្ពស់ជាង គ្រួសារបុរសមេគ្រួ (៥១,៣%) ។ ក្នុងពេលជាមួយគ្នា ភាគរយនៃការទទួលបានដីឡូតិ៍តាមការបន្តមរតក គឺទាបជាងខ្លាំងសំរាប់គ្រួសារស្ត្រីមេគ្រួ (១១,២%) បើធៀបនឹងគ្រួសារបុរសមេគ្រួ (២៤,៦%) ។ ប៉ុន្តែគំលាតនេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេនៅជនបទកម្ពុជា ដែលដីធ្លីច្រើនតែចែកទៅឱ្យកូនប្រុសៗ ។

តារាង២.៥ បង្ហាញថា ភាគរយនៃការទទួលបានដីឡូតិ៍តាមការទិញនិងការរានដីសំរាប់គ្រួសារស្ត្រីមេគ្រួ គឺទាបជាងគ្រួសារបុរសមេគ្រួ។ ពេលគួបចូលគ្នា ភាគរយទាបជាងនៃការបន្ត

មរតក ការទិញ និងការភានដី បង្ហាញថា គ្រួសារស្ត្រីមេគ្រួមានលទ្ធភាពទទួលបានដីឡូត៍បន្ថែម តិចជាង គ្រួសារបុរសមេគ្រួ ។ តារាង២.៦ ជួយពន្យល់ថាការសង្កេតឃើញនេះគឺអាចត្រឹមត្រូវ ដោយបង្ហាញថា ជាមធ្យម គ្រួសារស្ត្រីមេគ្រួនៅក្នុងចន្លោះទំហំដីកាន់កាប់នីមួយៗ មានទ្រព្យ និងចំនូលតិចជាងគ្រួសារបុរសមេគ្រួ ។ ទ្រព្យសកម្មតិច ជាពិសេសទ្រព្យសកម្មទាក់ទិននឹង កសិកម្ម បង្ហាញពីកំហិតលើបរិមាណដីធ្លីដែលអាចធ្វើកសិកម្ម ហើយចំណូលទាបបង្ហាញពីកំហិត លើការទិញដីថ្មី និងធ្វើវិនិយោគផ្សេងៗទៀត ។

### តារាង ២.៥: ការទទួលបានដីតាមយេនឌ័រ (ភាគរយគ្រួសារ)

| ទំហំដី/ហ.ត | រដ្ឋ | | បន្តមរតក | | ទិញ | | ភានដី | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| | | | | | | | | | | |
| <0.5 | 39.5 | 73.1 | 43.1 | 19.4 | 14.9 | 6.5 | 2.5 | 1.1 | 281 | 186 |
| 0.5 – 0.9 | 52.0 | 71.6 | 29.6 | 6.7 | 15.7 | 16.4 | 2.6 | 4.9 | 619 | 225 |
| 1.0 – 1.9 | 58.7 | 77.9 | 21.5 | 6.9 | 14.9 | 8.3 | 4.9 | 6.9 | 878 | 217 |
| 2.0 – 2.9 | 51.5 | 73.5 | 18.5 | 12.4 | 18.5 | 6.2 | 11.4 | 8.0 | 546 | 113 |
| >3.0 | 46.1 | 50.0 | 22.1 | 12.5 | 16.7 | 22.3 | 15.2 | 15.2 | 712 | 112 |
| | | | | | | | | | | |
| សរុប | 1557 | 605 | 751 | 94 | 490 | 99 | 236 | 54 | 3036 | 853 |
| សរុបជា% | 51.3 | 70.9 | 24.7 | 11.0 | 16.1 | 11.6 | 7.8 | 6.3 | 78.1 | 21.9 |

### តារាង ២.៦: ទ្រព្យធនរបស់គ្រួសារ* និងពលកម្ម **

| ទំហំដី (ហ.ត) | បសុសត្វ | | ទ្រព្យសកម្ម ជាប់លាប់ | | ទ្រព្យសកម្ម មិនមែនកសិកម្ម | | ទ្រព្យកសិកម្ម មិនមែនម៉ាស៊ីន | | ទ្រព្យកសិកម្ម ជាម៉ាស៊ីន | | ពលកម្ម គ្រួសារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| 0 | | | | | | | | | | | 4.1 | 4.6 |
| <0.5 | 110.9 | 74.3 | 36.4 | 28.1 | 29.9 | 2.4 | 3.7 | 3.4 | 9.2 | 2.0 | 3.6 | 2.9 |
| 0.5 – 0.99 | 158.4 | 134.6 | 40.7 | 37.8 | 10.4 | 3.3 | 11.2 | 5.8 | 22.1 | 3.4 | 4.2 | 3.8 |
| 1.0 – 1.99 | 204.9 | 117.5 | 62.4 | 14.1 | 23.9 | 0.8 | 14.8 | 9.5 | 36.7 | 5.2 | 4.5 | 2.2 |
| 2.0 – 2.99 | 240.2 | 127.6 | 51.7 | 27.8 | 12.8 | 5.3 | 23.5 | 13.2 | 41.5 | 11.6 | 4.9 | 4.4 |
| >3.0 | 30.9 | 273.8 | 60.6 | 43.5 | 24.6 | 22.3 | 40.2 | 20.2 | 45.9 | 29.6 | 5.1 | 4.4 |
| | | | | | | | | | | | | |
| សរុប | 198.2 | 121.9 | 50.7 | 28.8 | 20.4 | 4.1 | 18.2 | 7.8 | 31.4 | 6.7 | 4.4 | 3.4 |

* *ម៉ឺនរៀល*

** *ពលកម្មគ្រួសារជាសក្តានុពលគឺមាន ស្ត្រី និងបុរស អាយុពី ១០-៦០ឆ្នាំ យោងតាម SES Cambodia ។*

លំនាំទាំងនេះស្របគ្នានឹងការសិក្សាផ្សេងៗទៀត ដែលគូសរំលេចពីការចាញ់ប្រៀបនានាដែលគ្រួសារស្ត្រីមេគ្រួត្រូវប្រឈម ក្នុងរឿងសុវត្ថិភាពកាន់កាប់ដី និងការរក្សាជីវភាពរស់នៅឱ្យមានចីរភាព[២៦] ។ ប៉ុន្តែ ទិន្នន័យពុំមានគ្រប់គ្រាន់ទេសំរាប់បង្ហាញពីលំនាំបែបនេះក្នុងរយៈពេលវែង ។ ឧទាហរណ៍ តើនៅពេលណាដែលស្ត្រីក្លាយខ្លួនជាមេគ្រួសារតែឯង និង តើមានអ្វីកើតឡើងចំពោះដីកាន់កាប់របស់ពួកគេ? យើងអាចសន្មតថា គ្រួសារស្ត្រីមេគ្រួប្រហែលទទួលបានដីតិចកាលពីឆ្នាំ១៩៨៩ ផ្អែកលើទិន្នន័យអង្កេតពីចំនួនកំលាំងពលកម្មក្នុងគ្រួសារស្ត្រីមេគ្រួ និងគ្រួសារបុរសមេគ្រួ ។ ប៉ុន្តែតើមានអ្វីកើតឡើងចំពោះស្ត្រីដែលក្លាយជាម៉េម៉ាយ រឺត្រូវគេបោះបង់ចោលនៅក្រោយឆ្នាំ១៩៨៩?

### *២.៦.៤ សង្ខេប*

ទំហំដីកាន់កាប់ និងយេនឌ័ររបស់មេគ្រួសារ គឺជាកត្តាទស្សន៍ទាយដ៏ល្អនៃកំលាំងពលកម្ម ទ្រព្យសកម្ម និងចំណូលក្នុងគ្រួសារ ។ ដូច្នេះ ទំហំដីកាន់កាប់ក៏បង្ហាញបានយ៉ាងល្អពីសមត្ថភាពជាសក្តានុពលរបស់គ្រួសារ ដើម្បីទទួលបានផលចំណេញពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដី។ ក្នុងន័យនេះ គ្រួសារមានដីកាន់កាប់ធំ ជាទូទៅមានស្ថានភាពប្រសើរជាងគ្រួសារមានដីកាន់កាប់តូច ក្នុងការទទួលបានផលប្រយោជន៍ពីប័ណ្ណកម្មសិទ្ធិដី។ គ្រួសារមានដីកាន់កាប់ធំ មានទ្រព្យធននិងកំលាំងពលកម្មច្រើន និងមានចំណូលខ្ពស់ អាចចាត់ទុកជា គ្រួសារទទួលផលប៉ះពាល់ជាសក្តានុពលខ្ពស់ (HPIs) ។ ផ្ទុយទៅវិញ គ្រួសារទទួលផលប៉ះពាល់ជាសក្តានុពលទាប (LPIs) គឺមានផ្ទៃដីកសិកម្មតូច និងតិចឡូត៍ ព្រមទាំងមានចំណូលតិច កំលាំងពលកម្មតិច និងទ្រព្យសកម្មតិច ។ LPIs ក៏មានរួមបញ្ចូលទាំងគ្រួសារងាយរងគ្រោះ ដូចជា គ្រួសារស្ត្រីមេគ្រួ ជាដើម ។

## ២.៧ ការវិនិយោគផ្នែកកសិកម្ម ផលិតភាព និងការប្រើប្រាស់ដី

ទ្រឹស្តីខាងស្រាវជ្រាវបានទស្សន៍ទាយថា ការកាន់កាប់ដីមានសុវត្ថិភាព នឹងធ្វើឱ្យមានកំនើនផ្នែកចំណាយផលិតកម្ម និងវិនិយោគលើផលិតកម្មស្រូវ និង/ឬ ផលដំណាំផ្សេងៗទៀត ក្នុងតំបន់

[២៦] Recall Biddulph, Robin (2000) and So *et al*. (2001) ។

គំរោង LMAP ។ ទិន្នន័យបង្ហាញថា របាយនៃចំណាយផ្សេងៗ និងវិនិយោគ ព្រមទាំងផលិតភាព មានការរៀបចំស្របទៅតាមទំហំដីកាន់កាប់ ។ រឿងនេះបញ្ជាក់ថា ផលចំណេញទទួលបានពីប័ណ្ណកម្មសិទ្ធិដីនឹងបែងចែកក្នុងលំនាំប្រហាក់ប្រហែលគ្នា ពិសេសបើសិនគ្មានគោលនយោបាយអភិវឌ្ឍន៍ និងរបៀបរបបអនុវត្តន៍នានាដែលអំណោយផលដល់អ្នកក្រ ។

## ២.៧.១ ការចំណាយ

តារាង២.៧ ខាងក្រោមបង្ហាញថា ចំនាយលើផលិតកម្មស្រូវនៅរដូវវស្សាំដុះមុនពេលធ្វើអង្កេត ភាគច្រើនជាចំណាយលើកំលាំងពលកម្មសំរាប់ការរៀបចំដី ដកស្ទូង និងប្រមូលផល ព្រមទាំងលើជីគីមី ហើយបន្ទាប់មកគឺ ថ្លៃឈ្នួលបូមទឹក បោកស្រូវ និងជួលដី ។ ចំណាយជាមធ្យមក្នុងមួយគ្រួសារ តែងកើនឡើងស្របតាមទំហំដីកាន់កាប់ ។ ឧទាហរណ៍ សំរាប់ទំហំដីកាន់កាប់ពីរចន្លោះក្រោមបំផុត គឺមានចំណាយជាមធ្យម ១៣,០៣ និង ២១,៥៧ ម៉ឺនរៀល/គ្រួសារ, សំរាប់ពីរចន្លោះលើបំផុត គឺ ៣១,៦ និង ៥១,៩៨ ម៉ឺនរៀល/គ្រួសារ និងសំរាប់ចន្លោះកណ្តាល ៣១,៧៧ម៉ឺនរៀល/គ្រួសារ ។ គ្រួសារមានដីកាន់កាប់ធំ មិនគ្រាន់តែមានដីច្រើនជាងសំរាប់វិនិយោគទៅលើប៉ុណ្ណោះទេ តែពួកគេក៏មានធនធានច្រើនជាងសំរាប់ធ្វើវិនិយោគដែរ ។

ចំណាយក៏មានលំនាំច្បាស់លាស់ដែរ យោងតាមយេនឌ័រមេគ្រួសារ ។ ជាមធ្យម គ្រួសារបុរសមេគ្រួ ចំនាយប្រហែល ៥០% ច្រើនជាងគ្រួសារស្ត្រីមេគ្រួ សំរាប់ផលិតកម្មស្រូវ ។ ម្យ៉ាងទៀត គ្រួសារបុរសមេគ្រួ តែងចំណាយច្រើនជាងគ្រួសារស្ត្រីមេគ្រួ លើជិតគ្រប់ធាតុចូលនៅក្នុងចន្លោះនីមួយៗ ។ រឿងនេះអាចដោយសារ ១) ជាមធ្យម គ្រួសារស្ត្រីមេគ្រួតែងមានដីកាន់កាប់តូចជាង (តារាង២.៦) និង ២) គំលាតរវាងចំនួនធនធាន ក្នុងនេះមានទាំងកំលាំងពលកម្មដែលមាននៅក្នុងគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួផង (តារាង២.៦ ខាងលើ) ។ មានចំណុចខុសប្លែកតែមួយទេគឺ ក្នុងចន្លោះដីកាន់កាប់ធំជាងគេ គ្រួសារស្ត្រីមេគ្រួ ចំណាយច្រើនជាងគ្រួសារបុរសមេគ្រួ ដែលមួយចំណែកធំមកពីចំណាយលើជីគីមី និងពលកម្ម សំរាប់ការដកស្ទូង និងប្រមូលផល ។ ការបកស្រាយមួយគឺថា គ្រួសារស្ត្រីមេគ្រួធ្វើការវិនិយោគដូច្នេះ ដើម្បីប៉ះប៉ូវកង្វះខាតពលកម្មក្នុងគ្រួសារ ។

**តារាង ២.៧: ធាតុចូលផលិតស្រូវ ( *ម៉ឺនរៀល*/គ្រួសារ)**

| ធាតុចូល | < .5 | | 0.5 – 0.99 | | 1.0 – 1.99 | | 2.0 - 2.99 | | ≥ 3.0 | | មធ្យម សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | | |
| | | | | | | | | | | | | |
| ជីគីមី | 5.8 | 5.7 | 10.6 | 8.7 | 12.0 | 8.3 | 13.6 | 8.9 | 17.6 | 32.7 | 11.21 | |
| ថ្នាំសំលាប់ | 1.4 | .8 | 2.1 | 1.2 | 2.0 | 1.1 | 1.5 | 1.5 | 3.1 | 3.1 | 2.06 | |
| បូមទឹក | 3.2 | 2.7 | 4.0 | 4.0 | 5.1 | 4.1 | 7.5 | 3.0 | 11.5 | 15.0 | 5.59 | |
| ព.ក រៀបចំដី | 4.6 | 3.1 | 6.7 | 5.2 | 11.6 | 7.1 | 10.6 | 5.5 | 18.4 | 17.3 | 9.01 | |
| ព.ក ដឹកជញ្ជូន | 6.8 | 5.7 | 9.2 | 8.3 | 11.8 | 8.8 | 14.5 | 11.1 | 22.5 | 33.5 | 12.2 | |
| ព.ក ប្រមូលផល | 5.3 | 3.4 | 6.2 | 4.0 | 8.3 | 5.4 | 12.1 | 9.9 | 13.5 | 18.3 | 8.46 | |
| បោកបែន | 2.7 | 2.3 | 2.8 | 2.3 | 3.9 | 3.2 | 5.8 | 3.6 | 6.7 | 9.3 | 4.2 | |
| ជួសជុល | 1.5 | 1.1 | 2.2 | 1.6 | 2.3 | 2.4 | 1.7 | .95 | 1.9 | 15.0 | 2.07 | |
| ដឹកជញ្ជូន | 1.8 | 2.0 | 2.7 | 2.6 | 3.2 | 2.6 | 3.5 | 1.9 | 6.6 | 3.9 | 3.23 | |
| ជួលដី | 7.5 | | 6.1 | 1.7 | 10.8 | | 6.0 | | 10.9 | | 7.7 | |
| ជួលសត្វ | .2 | 5.0 | 4.9 | | 3.2 | 5.0 | | 6.0 | 10.0 | 1.5 | 4.48 | |
| ផ្សេងៗ | 4.6 | .97 | 4.4 | 5.5 | 10.6 | 20.0 | 3.1 | 10.0 | 7.4 | 6.3 | 7.2 | |
| | | | | | | | | | | | | |
| សរុប | 14.4 | 10.8 | 23.1 | 17.0 | 34.4 | 20.0 | 32.8 | 25.0 | 50.7 | 60.2 | 30.7 | 19.8 |
| | | | | | | | | | | | | |
| សរុប | 13.03 | | 21.57 | | 31.77 | | 31.6 | | 51.98 | | 28.2 | |

## *២.៧.២ ប្រភពហិរញ្ញវត្ថុសំរាប់ចំណាយ*

តារាង២.៨ ខាងក្រោមបង្ហាញថា ជិត ៩០% នៃចំណាយខាងកសិកម្មសំរាប់ផលិតកម្មស្រូវ គឺប្រើហិរញ្ញវត្ថុ "ប្រភពផ្ទាល់" បន្ទាប់មកគឺ កំចីពីសាច់ញាតិនិងមិត្តភក្តិ (៨.៣%) និង ឥណទានពី "កម្មវិធី" ដែលក្នុងនេះមានទាំង សញ្ញ័យពាក់កណ្តាលផ្លូវការ ក្រុមកំចី MFIs និងធនាគារពាណិជ្ជកម្ម (២.៣%) ផង ។ ករណីខុសប្លែកគួរកត់សំគាល់បំផុតអំពីនិន្នាការទូទៅ ទាក់ទិននឹងជីគីមី ដែលផ្តល់ហិរញ្ញប្បទានដោយ "ប្រភពផ្ទាល់" ៧៩% និង ២១%ទៀតដោយកំចីពីគ្រួសារ

មិត្តភក្តិ និងកម្មវិធីឥណទាន[២៧] ។ ចំណាយលើពលកម្ម ប្រហែល ៩២-៩៦% សំរាប់ការរៀបចំដី ដកស្ទូង និងប្រមូលផល គឺផ្តល់ហិរញ្ញប្បទានពី "ប្រភពផ្ទាល់" ។

**តារាង ២.៨: ប្រភពចំណាយសំរាប់ធាតុចូលកសិកម្មជ្រើសរើស**

| ធាតុចូល | ប្រភពផ្ទាល់ | | សាច់ញាតិ/មិត្តភក្តិ | | កម្មវិធីឥណទាន | | សរុប |
|---|---|---|---|---|---|---|---|
| | N | % | N | % | N | % | N |
| | | | | | | | |
| ជីគីមី | 473 | 79.0 | 106 | 17.7 | 20 | 3.3 | 599 |
| ថ្នាំសំលាប់សត្វល្អិត | 195 | 96.1 | 4 | 2.0 | 4 | 2.0 | 203 |
| បូមទឹក | 250 | 89.6 | 24 | 8.6 | 5 | 1.8 | 279 |
| រៀបចំដី | 355 | 92.4 | 19 | 4.9 | 10 | 2.6 | 384 |
| ការដាំដុះ | 387 | 92.6 | 23 | 5.5 | 8 | 1.9 | 418 |
| ការប្រមូលផល | 357 | 95.5 | 12 | 3.2 | 5 | 1.3 | 374 |
| | | | | | | | |
| សរុប | 2,017 | 89.4 | 188 | 8.3 | 52 | 2.3 | 2,257 |

ប៉ុន្តែវាមានការប្រែប្រួលខ្លះ បើគិតពីរបាយប្រភពហិរញ្ញប្បទានសំរាប់ធាតុចូលផ្សេងៗទៅតាមទំហំដីកាន់កាប់ ។ ឧទាហរណ៍ដើម្បីផ្តល់ហិរញ្ញប្បទានសំរាប់ធាតុចូលពលកម្ម ២គ្រួសារដែលកាន់កាប់ដីធំជាងគេ បានខ្ចីប្រាក់ពីគ្រួសារមិត្តភក្តិនិងកម្មវិធីឥណទាន ច្រើនជាង គ្រួសារដែលកាន់កាប់ដីតូច ។ ការសង្កេតនេះបានបង្ហាញថា ការផ្លាស់ប្តូរពី "ប្រភពផ្ទាល់" ឆ្ពោះទៅកាន់ឥណទាន ដំបូងចាប់ផ្តើមពីការខ្ចីពីគ្រួសារ/មិត្តភក្តិ បន្ទាប់មកទើបទៅរកខ្ចីពីស្ថាប័នឥណទានផ្លូវការ ។ វាបង្ហាញដែរថា ទិន្នាការនេះអាចចាប់ផ្តើមឡើងពីគ្រួសារមានដីកាន់កាប់ធំៗ ។

តារាង២.៩ បង្ហាញថា ទាំងគ្រួសារក្នុងចន្លោះដីកាន់កាប់តូចបំផុត និងធំបំផុត គឺត្រូវពឹងផ្អែកលើសាច់ញាតិ និងមិត្តភក្តិដើម្បីដោះស្រាយជាង ២០%នៃហិរញ្ញប្បទានសំរាប់ធាតុចូលជា

[២៧] ទិន្នន័យអង្កេតជាមូលដ្ឋាននេះ មិនបានបញ្ជាក់ចំៗពីពាណិជ្ជករទេ ហើយរឿងនេះមួយចំណែកគឺប្រហែលដោយសារទិន្នន័យសំដៅដល់សាច់ប្រាក់ ជាជាងកំចីជាវត្ថុ ។

ដីគីមី ហើយគ្រួសារក្នុងចន្លោះខ្ពស់បំផុតលំដាប់ទី ២ ប្រើប្រាស់កម្មវិធីឥណទានសំរាប់ ៧,៧% នៃហិរញ្ញប្បទាន ។ រឿងនេះអាចពន្យល់បានមួយចំណែកថា ចំណាយលើធាតុចូលជាដីគីមីវាមានកំរិតខ្ពស់ គឺជាមធ្យមប្រហែល ១១,២១ម៉ឺនរៀល/គ្រួសារ (ប្រហែល ៥,៨ម៉ឺនរៀល សំរាប់អ្នកកាន់កាប់ដីតូចៗ) ។ គ្រួសារកាន់កាប់ដីតូចៗ តែងមានធនធានតិចជាងសំរាប់ធ្វើហិរញ្ញប្បទានពីប្រភពផ្ទាល់ ដូច្នេះមានគ្រួសារច្រើនជាងដែលតែងពឹងលើហិរញ្ញប្បទានពីសាច់ញាតិ និងមិត្តភក្តិ ។ ថ្វីបើគ្រួសារកាន់កាប់ដីធំៗអាចមានធនធានច្រើនជាងក្តី ប៉ុន្តែក៏មានដីច្រើនជាងដែរ ដូច្នេះអាចត្រូវការកំចីពីប្រភពផ្សេងៗទៀតដើម្បីទិញបានដីគីមីច្រើន ។

**តារាង ២.៩: ប្រភពហិរញ្ញប្បទានសំរាប់ធាតុចូលជាដីគីមី**

| ធាតុចូល | ប្រភពផ្ទាល់ | | សាច់ញាតិ/មិត្តភក្តិ | | កម្មវិធីឥណទាន | | សរុប |
|---|---|---|---|---|---|---|---|
| | N | % | N | % | N | % | N |
| <0.5 | 99 | 75.0 | 30 | 22.7 | 3 | 2.3 | 132 |
| 0.5 – 0.99 | 131 | 82.4 | 23 | 14.5 | 5 | 3.1 | 159 |
| 1.0 – 1.99 | 112 | 78.9 | 26 | 18.3 | 4 | 2.8 | 142 |
| 2.0 – 2.99 | 64 | 82.1 | 8 | 10.3 | 6 | 7.7 | 78 |
| >3.0 | 67 | 76.1 | 19 | 21.6 | 2 | 2.3 | 88 |
| | | | | | | | |
| សរុប | 473 | 79.0 | 106 | 17.7 | 20 | 3.3 | 599 |

### *២.៧.៣ ផលិតភាព*

ទិន្នន័យក្នុងតារាង២.១០ បញ្ជាក់ទំនាក់ទំនងរវាងផលិតភាព-ទំហំកសិដ្ឋាន ដែលសង្កេតឃើញនៅកន្លែងផ្សេងទៀតនៅអាស៊ី និងកម្ពុជា (Sophal and Acharya, 2002) គឺថា កសិដ្ឋានតូចៗច្រើនតែមានផលិតភាពខ្ពស់ បើគិតតាមទិន្នផល (ស្រូវ) ជាងកសិដ្ឋានធំៗ ដោយគ្មានទាក់ទិននឹងយេនឌ័រមេគ្រួសារទេ ។ ហេតុផលមួយដែលគេយកមកពន្យល់លំនាំនេះ គឺដីឡូត៍តូចៗតាមធម្មតាគឺកើតចេញពីការពុះចែកដីដែលមានដីជាតិល្អ ។ ចំណុចនេះហាក់ដូចស៊ីគ្នានឹងលំនាំទូទៅនៃការបែងចែកដីឆ្នាំ១៩៨៩ នៅកម្ពុជា ដូចបានពិភាក្សាពីខាងដើម ។ ហេតុផលមួយទៀត គឺប្រហែលម្ចាស់កសិដ្ឋានតូចៗតែងប្រើបច្ចេកវិទ្យាល្អជាង និងធ្វើការគ្រប់គ្រងបានល្អជាងបើសិន

គ្មានវិធីធ្វើកសិកម្មតាមបែបទំនើបទេ ។ ម្ចាស់កសិដ្ឋានតូចៗ ក៏អាចប្រើកំលាំងពលកម្មគ្រួសារ និងធាតុចូលផ្ទាល់ផ្សេងៗ ក្នុងបរិមាណច្រើនជាងដែរ ។

**តារាង ២.១០: ទិន្នផលស្រូវជាមធ្យមនៃផ្ទៃដីបានប្រមូលផលសរុប (គ.ក/ហ.ត)**

| ដីកាន់កាប់ | បុរស | | ស្ត្រី | | សរុប | |
|---|---|---|---|---|---|---|
| | គ្រួសារ | ទិន្នផល | គ្រួសារ | ទិន្នផល | គ្រួសារ | ទិន្នផល |
| | | | | | | |
| < 0.5 | 107 | 2,138 | 70 | 1,918 | 177 | 2,051 |
| 0.5 – 0.99 | 156 | 1,660 | 51 | 1,724 | 207 | 1,676 |
| 1.0 – 1.99 | 169 | 1,516 | 41 | 1,247 | 210 | 1,464 |
| 2.0 – 2.99 | 98 | 1,189 | 19 | 920 | 117 | 1,145 |
| ≥ 3.0 | 110 | 1,013 | 17 | 1,041 | 127 | 1,016 |
| | | | | | | |
| សរុប | 640 | 1,519 | 198 | 1,558 | 838 | 1,528 |

**តារាង ២.១១: ធាតុចូលសំរាប់ផលិតកម្មស្រូវ (ម៉ឺនរៀលក្នុងមួយហិកតា)**

| ធាតុចូល | < .5 | | 0.5 – 0.99 | | 1.0 – 1.99 | | 2.0 - 2.99 | | ≥ 3.0 | | មធ្យមសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនដង | ទឹកប្រាក់ | ចំនួនដង | ទឹកប្រាក់ | ចំនួនដង | ទឹកប្រាក់ | ចំនួនដង | ទឹកប្រាក់ | ចំនួនដង | ទឹកប្រាក់ | ចំនួនដង | ទឹកប្រាក់ |
| | | | | | | | | | | | | |
| ជីគីមី | 131 | 23.0 | 159 | 15.7 | 139 | 10.7 | 77 | 8.5 | 87 | 8.4 | 593 | 14.1 |
| ថ្នាំសំលាប់សត្វល្អិត | 23 | 3.1 | 45 | 4.4 | 53 | 1.6 | 35 | 0.9 | 46 | 1.4 | 202 | 2.23 |
| ម៉ាស៊ីនបូមទឹក | 54 | 17.2 | 74 | 5.6 | 74 | 4.6 | 29 | 4.5 | 45 | 5.1 | 276 | 7.4 |
| ពលកម្មរៀបចំ | 91 | 14.8 | 90 | 9.9 | 88 | 9.7 | 55 | 5.1 | 54 | 6.1 | 378 | 9.8 |
| ពលកម្មដឹកជញ្ជូន | 51 | 27.8 | 83 | 12.2 | 99 | 11.0 | 35 | 7.4 | 51 | 8.7 | 319 | 13.2 |
| | | | | | | | | | | | | |
| ធាតុចូលសរុប | 169 | 51.3 | 202 | 32.4 | 185 | 29.4 | 104 | 18.5 | 121 | 19.5 | 78 1 | 31.9 |

ម្ចាស់កសិដ្ឋានតូចៗនៅកម្ពុជា ក៏ហាក់មានប្រើធាតុចូលទិញគេ លើដីមួយហិកតាៗ ក្នុងចំនួនច្រើនជាងកសិដ្ឋានធំៗដែរ ។ តារាង២.១១ ផ្ដល់ពតិមានសង្ខេបពីចំណាយកសិកម្ម/ហ.ត នូវធាតុចូលជ្រើសរើសមួយចំនួន ។ ជាទូទៅ គ្រួសារកាន់កាប់ដីតូចៗជាងគេពីរក្រុមខាងក្រោម បានចំនាយសំរាប់ធាតុចូលនីមួយៗក្នុងដីមួយហិចតា ច្រើនជាងគ្រួសារពីរក្រុមខាងលើដែលមាន

ដីកាន់កាប់ធំៗ ។ បើគិតលើធាតុចូលទាំងអស់ គ្រួសារពីរក្រុមដែលមានដីកាន់កាប់តូចជាងគេ ចំណាយ ៥១,៣ និង ៣២,៤ ម៉ឺនរៀល ក្នុងមួយហិកតារៀងគ្នា ហើយគ្រួសារពីរក្រុមដែលមានដីកាន់កាប់ធំជាងគេ ចំណាយ ១៨,៥ និង១៩,៥ម៉ឺនរៀល ក្នុងមួយហិកតារៀងគ្នា ។

ថ្វីបើកសិដ្ឋានតូចៗអាចមានផលិតភាពច្រើន បើគិតពីដី (គ.ក/ហ.ត) ជាងកសិដ្ឋានធំៗក្តី ប៉ុន្តែពុំមានផលិតភាពល្អទេបើគិតពីវិនិយោគ (គ.ក/ម៉ឺនរៀល) ។ តារាង២.១២ បង្ហាញថា កសិដ្ឋានមានដីតូចជាង ០,៥ហ.ត ទទួលបានស្រូវ ៣៩,៩៨ គ.ក សំរាប់ការចំនាយ *១ម៉ឺនរៀលៗ* ហើយកសិដ្ឋានមានដី ២-២,៩៩ហ.ត និងលើសពី ៣ហ.ត ទទួលបានស្រូវ ៦១,៨៩គ.ក និង ៥២,១គ.ក រៀងគ្នា សំរាប់ការចំណាយ *មួយម៉ឺនរៀលៗ* ។ ដើម្បីជួយគ្រួសារតូចៗឱ្យកែលំអជីវភាព និងចេញផុតពីភាពក្រីក្រ រឿងនេះបង្ហាញថា ប្រសិទ្ធភាពនៃការវិនិយោគទុន វាសំខាន់ស្មើគ្នានឹងកំរិតនៃការវិនិយោគ រឺក៏សំខាន់ជាងថែមទៀត។ ចំពោះផលប៉ះពាល់នៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីវិញ លទ្ធភាពទទួលបានឥណទានដែលអាចប្រើសំរាប់ធ្វើវិនិយោគ ត្រូវតែមានការបំពេញបន្ថែមដោយសេវាផ្សព្វផ្សាយបច្ចេកទេសដែលអាចជួយកែលំអផលិតភាពទុន ។

ផលិតភាពដីខ្ពស់ជាងនៃកសិដ្ឋានតូចៗ ក៏មិនសុទ្ធតែនាំឱ្យមាន ផលិតកម្មគ្រួសារជាមធ្យមកំរិតខ្ពស់ជាងនោះទេ ។ ទោះជាកសិដ្ឋានតូចៗមានទិន្នផលក្នុងមួយហិកតាដី ខ្ពស់ជាងកសិដ្ឋានធំៗក្តី ក៏ពួកគេមានដីតិចជាងឆ្ងាយដែរ ។ តារាង២.១៣ បង្ហាញថា គ្រួសារមានដីតិចជាង ០,៥ហ.ត អាចផលិតបានស្រូវតែ ៦៤០,៣គ.ក ទោះបីមានផលិតភាពខ្ពស់ជាងក្តី ។ ម្យ៉ាងទៀត កសិដ្ឋានធំៗជាងគេ ផលិតស្រូវបានសរុប ៣,២៧តោន/គ្រួសារ ទោះបីមានផលិតភាពបានត្រឹមតែពាក់កណ្តាលនៃផលិតភាពរបស់កសិដ្ឋានតូចៗជាងគេក្តី ។

ផលិតភាពដីខ្ពស់ជាងនៃកសិដ្ឋានតូចៗ ក៏មិននាំឱ្យមានផលិតកម្មជាមធ្យមកំរិតខ្ពស់ជាងនៃពលកម្មមនុស្សធ្វើការជាសក្តានុពលម្នាក់ដែរ ។ នៅពេលយើងពិនិត្យ ពីផលិតភាពដែលវាស់វែងតាមផលិតកម្មគ្រួសារក្នុងពលកម្មសមាជិកគ្រួសារសកម្មជាសក្តានុពលម្នាក់ យើងឃើញថា ធាតុចេញមធ្យមនៃពលកម្មសមាជិកគ្រួសារសកម្មជាសក្តានុពលម្នាក់នៅក្នុងគ្រួសារមានដីកាន់កាប់តូច គឺមានកំរិតតិចជាងខ្លាំងណាស់ បើធៀបនឹងគ្រួសារមានដីកាន់កាប់ធំ ។

ឧទាហរណ៍ គ្រួសារមានដីតិចជាង ០.៥ហ.ត ផលិតបាន ១៩៤គ.ក ក្នុងសមាជិកគ្រួសារសកម្មជាសក្តានុពលម្នាក់ ឯសំរាប់គ្រួសារមានដីច្រើនជាង ៣ហ.ត គឺផលិតបានដល់ ៦៥៤គ.ក ។

## តារាង ២.១២: ផលិតភាព និងចំណាយ*

| ដីកាន់កាប់ (ហ.ត) | ទិន្នផល (គ.ក/ហ.ត) | ចំណាយ (ម៉ឺនរៀល/ហ.ត) | ចំនាយ (គ.ក/ម៉ឺនរៀល) | ចំនាយ[២៨] (ម៉ឺនរៀល/ហ.ត) |
|---|---|---|---|---|
| | | | | |
| < 0.5 | 2,051 | 51.3 | 39.98 | 16.01 |
| 0.5 – 0.99 | 1,676 | 32.4 | 51.72 | 22.81 |
| 1.0 – 1.99 | 1,464 | 29.4 | 49.80 | 34.31 |
| 2.0 – 2.99 | 1,145 | 18.5 | 61.89 | 33.37 |
| ≥ 3.0 | 1,016 | 19.5 | 52.10 | 62.81 |

**រដូវដាំដុះចុងក្រោយ (២០០៣) មុនពេលធ្វើអង្កេតនៅខែមករា/កុម្ភៈ ២០០៤ ។*

## តារាង ២.១៣: សង្ខេបផលិតកម្មគ្រួសារ

| ដីកាន់កាប់ (ហ.ត) | ពលកម្មគ្រួសារ | ទិន្នផល (គ.ក/ហ.ត) | ផ្ទៃដី (ហ.ត/គ្រួសារ) | | ផលិតកម្មសរុប (គ.ក/គ្រួ) និង គ.ក/ពលកម្ម | |
|---|---|---|---|---|---|---|
| | | | កាន់កាប់ | ប្រមូលផល | ទិន្នផល x ផ្ទៃដីប្រមូលផល | គ.ក/គ្រួ/ពលកម្ម/គ្រួ |
| | | | | | | |
| < 0.5 | 3.3 | 2,051 | 0.27 | .3122 | 640.3 | 194.0 |
| 0.5 – 0.99 | 4.1 | 1,676 | 0.70 | .704 | 1,180.0 | 287.8 |
| 1.0 – 1.99 | 4.0 | 1,464 | 1.41 | 1.167 | 1,708.5 | 427.1 |
| 2.0 – 2.99 | 4.8 | 1,145 | 2.41 | 1.8037 | 2,065.2 | 430.0 |
| ≥ 3.0 | 5.0 | 1,016 | 4.80 | 3.2208 | 3,272.3 | 654.4 |

---

[២៨] តួលេខនេះផ្ទុយនឹងតួលេខសំរាប់ចំណាយ *ម៉ឺនរៀល*/ហ.ត បង្ហាញក្នុងតារាង ២.៧ ខាងលើ ។ តួលេខក្នុងតារាង ២.៧ ដកស្រង់ដោយផ្ទាល់ពីចំលើយសំភាសន៍អំពីចំណាយ ហើយតួលេខក្នុងតារាង ២.១២ គណនាដោយផ្អែកលើចំលើយសំភាសន៍អំពីផ្ទៃដី និងផលិតកម្មសរុប ។ តួលេខទាំងពីរ អាចខិតជិតតួលេខមួយផ្សេងទៀត ផ្តល់នូវការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យផ្ទៃក្នុងទៅលើភាពត្រឹមត្រូវ ។ បើមិនដូច្នោះទេ ការខុសប្លែកគ្នាអាចអះអាងថា អ្នកឆ្លើយហាក់ប្រាប់បន្ទាប ឬពន្លើសខ្ទង់ចំណាយ ។ រឿងនេះ គឺជារឿងធម្មតាទេនៅកម្ពុជា ។

រឿងនេះបង្ហាញថា កសិដ្ឋានតូចៗ មានការចាញ់ប្រៀបយ៉ាងខ្លាំងក្នុងរយៈពេលវែង ដោយគេត្រូវបន្តប្រើធនធានដ៏កំររបស់គ្រួសារ ដើម្បីបំពេញកង្វះខាតស្បៀងអាហារ ជាជាងធ្វើវិនិយោគថែមក្នុងផលិតកម្ម ឬសកម្មភាពសំខាន់ៗផ្សេងទៀត ដូចជា ការអប់រំរបស់កូនៗជាដើម (សូមអានឧបសម្ព័ន្ធ ក) និងបានគូសបញ្ជាក់ពីបញ្ហានានាជាប់ទាក់ទិននឹងចំណាយគ្មានប្រសិទ្ធភាពដូចបានបង្ហាញពីខាងដើមហើយ ។ បើសិនកសិករខ្ចីប្រាក់ទៅវិនិយោគក្នុងផលិតកម្ម ដែលហុចផលមិនគ្រប់គ្រាន់ដើម្បីបំពេញតំរូវការគ្រួសារ (មិនទាន់គិតដល់ការសល់ទុកលក់ផង) ដល់យូរៗទៅពួកគេអាចលិចលង់កាន់តែជ្រៅទៅក្នុងការជំពាក់បំណុលគេ ។ ចំណុចនេះគូសរំលេចម្តងទៀត ពីតំរូវការបំពេញបន្ថែមដោយសេវាកម្មផ្សព្វផ្សាយបច្ចេកទេស និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីអាចទាញយកផលឱ្យបានប្រសើរបំផុតពីការផ្តល់ប័ណ្ណកម្មសិទ្ធិដី នៅតាមតំបន់ជាក់លាក់នានា ។

### *២.៧.៤ ការប្រើប្រាស់ដី*

ដូចនៅតំបន់ផ្សេងទៀតដែរ ដីក្នុងតំបន់អង្កេត LMAP ជាទូទៅចែកចេញជា ១)ដីលំនៅដ្ឋាន, ២)ដីអាចដាំដុះធ្វើកសិកម្ម, ៣)ដីរួម និង/ឬ ដីរដ្ឋ រួមមាន ដីព្រៃ ដីលិចទឹក ដែលមានការធ្វើនេសាទ និងដាំដំណាំ ។ បញ្ហាប្រឈមសំខាន់មួយនៃការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គឺកសាងវិធីមានចីរភាពផ្សេងៗ ដើម្បីបែងចែកដីសំរាប់ការប្រើប្រាស់មានប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែខ្ពស់។ ចំរុះកម្មនៃការប្រើប្រាស់ដីអាចជាអាំងឌីកាទ័រមួយនៃប្រសិទ្ធភាពនេះ ទាំងសំរាប់ដីលំនៅដ្ឋាន និងដីកសិកម្ម ។ តាមទ្រឹស្តីស្រាវជ្រាវ ប័ណ្ណកម្មសិទ្ធិដីអាចជួយជំរុញចំរុះកម្មការប្រើប្រាស់ដី ពីព្រោះម្ចាស់ដីនឹងតំរង់ធនធានទៅខាងការប្រើប្រាស់នានាដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ។

#### *២.៧.៤.១ ដីលំនៅដ្ឋាន*

ការប្រើប្រាស់មានផលិតភាពល្អនៃដីលំនៅដ្ឋាន នឹងលើកមកពិនិត្យពិភាក្សាតាមរយៈ ផលប៉ះពាល់នៃការផ្តល់ប័ណ្ណកម្មសិទ្ធិដី និងការចុះបញ្ជីដីធ្លី ពីព្រោះក្នុងសង្គមធ្វើកសិកម្មនៅកម្ពុជា ដីលំនៅដ្ឋានមិនមែនប្រើសំរាប់តែការស្នាក់នៅទេ ប៉ុន្តែក៏សំរាប់ការដាំដើមឈើ និងប្រកបរបរតូច

តាច រួមទាំងការចិញ្ចឹមសត្វ និងច្បារដំណាំតាមផ្ទះផង ដើម្បីបំពេញបន្ថែមលើចំនូលគ្រួសារ ។ តារាង២.១៤ សង្ខេបការប្រើប្រាស់ផ្សេងៗនៃដីលំនៅដ្ឋាន នៅក្នុងតំបន់អង្កេត LMAP ។ ប្រហែល ៩២% នៃក្រុមមុខសញ្ញាអង្កេត LMAP រស់នៅលើដីលំនៅដ្ឋានជារបស់ខ្លួនឯងផ្ទាល់ ។ គ្រសារប្រហែល ២៤,៩% ប្រើដីលំនៅដ្ឋានរបស់ខ្លួនសំរាប់តែការរស់នៅ ហើយ ៦៤,២% ប្រើដីនោះសំរាប់ទាំងការរស់នៅ និងសកម្មភាពផ្សេងៗ រួមមាន ដំណាំ (៥០%), របរផ្សេងៗ (៩,៨%) និង ជំនួញទាក់ទិននឹងកសិកម្មតូចៗ (៤,៤%) ។ គ្រួសារប្រហែល ៣,៨% បានទុកដីលំនៅដ្ឋានរបស់ខ្លួនអោយនៅទំនេរចោល ។

**តារាង ២.១៤: ការប្រើប្រាស់ដីលំនៅដ្ឋានតាមទំហំដីកាន់កាប់(ហ.ត)**

| សកម្មភាពប្រើប្រាស់ដី | 0 | < 0.5 | 0.5-0.99 | 1-1.99 | 2-2.99 | > 3.0 | សរុប |
|---|---|---|---|---|---|---|---|
| | | | | | | | |
| ទុកដីឱ្យនៅទំនេរ | 6% | 2% | 4% | 3% | 5% | 7% | 4% |
| ជួលដី រឺជួលផ្ទះ | 0% | 0% | 1% | 0% | 0% | 0% | 0% |
| ឱ្យសាច់ញាតិរស់នៅបណ្តោះអាសន្ន ដោយមិនគិតឈ្នួល | 2% | 1% | 0% | 2% | 3% | 2% | 2% |
| រស់នៅ និងដំណាំដើមឈើ | 37% | 44% | 50% | 54% | 53% | 53% | 50% |
| ដំណាំដើមឈើ/បន្លែ (គ្មានផ្ទះ) | 4% | 3% | 3% | 6% | 7% | 6% | 5% |
| រស់នៅនិងរបរជំនួញ | 8% | 13% | 16% | 15% | 14% | 14% | 14% |
| សំរាប់តែរបរជំនួញ | 0% | 0% | 0% | 0% | 1% | 0% | 0% |
| សំរាប់តែរស់នៅ | 43% | 37% | 26% | 20% | 17% | 18% | 25% |
| ផ្សេងទៀត | 0% | 1% | 0% | 0% | 0% | 0% | 0% |
| សរុប | 51 | 187 | 227 | 256 | 139 | 153 | 1,013 |

ចំរុះកម្មការប្រើប្រាស់ដីកសិកម្ម ហាក់កើនឡើងស្របតាមទំហំដីកាន់កាប់ ដោយក្រុមកាន់កាប់ដីធំៗ ហាក់ដូចជាបានប្រើភាគរយមួយដីកសិកម្មដ៏តូចរបស់ខ្លួនសំរាប់តែការរស់នៅ ។ ឧទាហរណ៏ សំរាប់ក្រុមកាន់កាប់ដីក្នុងពីរចន្លោះទំហំដីធំជាងគេ គឺមាន ១៧% និង ១៨% ដែលប្រើប្រាស់ដីលំនៅដ្ឋានខ្លួនសំរាប់ការរស់នៅសុទ្ធ ហើយសំរាប់ក្រុមកាន់កាប់ដីនៅក្នុងពីរចន្លោះ

ទំហំដីតូចជាងគេ គឺមាន ៣៧% និង ២៦% ដែលប្រើប្រាស់ដីលំនៅដ្ឋានរបស់ខ្លួនសំរាប់តែការរស់នៅសុទ្ធ ។

*២.៧.៤.២ ដីកសិកម្ម*

ទិន្នន័យអង្កេតបង្ហាញថា លំនាំប្រើប្រាស់ដីកាន់តែមានលក្ខណៈចំរុះ នៅពេលទំហំដីកាន់កាប់កើនឡើង។ ឧទាហរណ៍ ភាគរយដីឡូត៍បែងចែកសំរាប់ផលិតកម្មស្រូវវស្សា ធ្លាក់ចុះពី ៨៩.១% សំរាប់គ្រួសារមានដីតិចជាង ០,៥ហ.ត មកត្រឹម ៧០%សំរាប់គ្រួសារមានដីច្រើនជាង ៣ហ.ត។ ម្យ៉ាងទៀត ភាគរយដីឡូត៍បែងចែកសំរាប់ផលិតកម្មស្រូវប្រាំង កើនឡើងស្របតាមទំហំដី ពី ២,៨%សំរាប់គ្រួសារមានដីតិចជាង ០,៥ហ.ត ដល់ ១២,៧%សំរាប់គ្រួសារដែលមានដីធំជាង ៣ហ.ត ។ ភាគរយដីឡូត៍បែងចែកសំរាប់ធ្វើ*ចំការ* (សរុប ៦,៧%) សឹងតែនៅថេរសំរាប់រាល់ទំហំដីកាន់កាប់ ហើយភាគរយដីឡូត៍បែងចែកសំរាប់ដំណាំជាដើមឈើ និងដំណាំចំរុះ គឺមានកំរិតទាបដូចគ្នាសំរាប់រាល់ទំហំដីកាន់កាប់ ហើយមានអត្រាមធ្យមសរុប ០,១% ។ ដូច្នេះ ហាក់ដូចមានលទ្ធភាពច្រើនណាស់សំរាប់ការធ្វើចំរុះកម្មដំណាំទៅថ្ងៃមុខ ក្នុងតំបន់អង្កេត LMAP ជាច្រើន។

បើគិតពីការប្រើប្រាស់ដីឡូត៍ជាក់ស្តែង ប្រហែល ៩០%នៃដីឡូត៍ទាំងអស់ត្រូវបានដាំដុះ ថ្វីបើភាគរយនេះហាក់ដូចជាថយចុះនៅពេលទំហំដីកើនឡើង ។ ភាគរយដីឡូត៍ដាំដុះសំរាប់គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ គឺស្រដៀងគ្នា សំរាប់រាល់ទំហំដីកាន់កាប់ ។ ភាគរយដីឡូត៍ជួលឱ្យគេ (១,៦%) ក៏ថេរគួរសមសំរាប់រាល់ទំហំដីកាន់កាប់ ។ គ្មានអ្វីគួរភ្ញាក់ផ្អើលទេ ដែលភាគរយនៃដីឡូត៍ទុកទំនេរចោល (សរុប ៧,៦%) កើនឡើងស្របតាមទំហំដីពី ៣,២% សំរាប់គ្រួសារមានដីតិចជាង ០,៥ហ.ត ដល់ ១១,៥%សំរាប់គ្រួសារមានដីកាន់កាប់ច្រើនជាង ៣ហ.ត។ គ្រួសារស្ត្រីមេគ្រួ មានភាគរយដីឡូត៍ទុកទំនេរចោលខ្ពស់ជាងបន្តិចបន្តួច ហើយក៏មានភាគរយដីជួលអោយគេខ្ពស់ជាងគ្រួសារបុរសមេគ្រួដែរ ។

ក្នុងចំនួនដីអាចដាំដុះបាន ៣.៨៩១ឡូត៍ មាន ២៩៥ឡូត៍ (ប្រហែល ៧,៦%) ត្រូវបាន ១៧៥គ្រួសារ ទុកទំនេរចោល ក្នុងអំឡុងរដូវដាំដុះចុងក្រោយ ។ ហេតុផលសំខាន់បីដែលបាន

លើកឡើងគឺ ខ្វះកំលាំងពលកម្ម(៣៤%) គ្មានចំណេញ(១៦%) និងខ្វះទុនវិនិយោគ(៩%) ។ អ្នកឆ្លើយដែលនៅសល់ ៤២% បានផ្តល់ហេតុផលបន្ថែមផ្សេងៗច្រើនទៀត ។ ភាគរយគ្រួសារស្ត្រីមេគ្រួដែលលើកពីកង្វះកំលាំងពលកម្ម (៣៨%) គឺមានច្រើនជាងគ្រួសារបុរសមេគ្រួ (៣៣%) ។ មួយវិញទៀត ភាគរយគ្រួសារបុរសមេគ្រួដែលលើកពីការគ្មានចំណេញ (១៨%) មានច្រើនជាងគ្រួសារស្ត្រីមេគ្រួ (៩%) ។ ចំណែកកំរិតភាគរយសំរាប់ការទុកដីឡូត៍ទំនេរចោលដោយសារខ្វះទុនវិនិយោគ គឺស្មើគ្នាសំរាប់គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។

ចំលើយគ្រួសារទាំងនេះ ហាក់ស្របនឹងហេតុផលលើកដោយអ្នកផ្តល់ព័ត៌មានគន្លឹះនានាក្នុងពេលពិភាក្សាជាក្រុម ដែលបានរកឃើញផងដែរថាការខូចផលដំណាំដោយសារអាកាសធាតុគឺជាហេតុផលចំបងមួយដែលគេទុកដីឱ្យនៅទំនេរចោល ។ ដីទំនេរ ក៏អាចពន្យល់មួយចំណែកថា ដោយសារថ្លៃឡើងចុះ និងការប្រែប្រួលខុសលំនាំដើមផ្សេងៗនៃទីផ្សារ ដូចជា ការជួញដីជាពិសេសក្នុងករណីដែលដីទំនេរមានម្ចាស់ជាអ្នកមកពីក្រៅភូមិ ។ ហេតុផលផ្សេងទៀត អាចមានទិន្នផលទាប ដោយសារដីគ្មានជីជាតិ និងវិនិយោគទាបលើធាតុចូលកសិកម្មទំនើបៗ ជាពិសេសជីគីមី (Chan and Acharya, 2002) ។

ចំពោះការដាំដុះជាក់ស្តែង ដីឡូត៍ប្រហែល ៧៩% ប្រើសំរាប់ផលិតកម្មស្រូវវស្សាមួយដងក្នុងមួយឆ្នាំ និង ៧,៣% ប្រើសំរាប់ផលិតកម្មស្រូវប្រាំងដែលធ្វើមួយដងក្នុងមួយឆ្នាំ ។ គ្មានអ្វីគួរភ្ញាក់ផ្អើលទេដែលលំនាំដាំដុះនេះ វាស៊ីគ្នាគួរសមនឹងលំនាំបែងចែកការប្រើប្រាស់ដីដែលពិពណ៌នាពីខាងដើម គឺបានន័យថា ភាគរយដីឡូត៍ប្រើប្រាស់សំរាប់ដំណាំស្រូវវស្សាថយចុះ នៅពេលទំហំដីកាន់កាប់កើនឡើង រីឯភាគរយដីប្រើប្រាស់សំរាប់ដំណាំស្រូវប្រាំងកើនឡើងទៅតាមទំហំដីកាន់កាប់ ។ ដីឡូត៍ប្រហែល ៤% ប្រើសំរាប់ធ្វើស្រូវវស្សា ២ដង និង ៣,៨% ប្រើសំរាប់ដាំដើមឈើយកផ្លែ និងដើមឈើផ្សេងៗទៀត ។

ការកាន់កាប់ដីមានសុវត្ថិភាព រំពឹងថានឹងជួយពង្រីកវិនិយោគរបស់កសិករនៅពេលខាងមុខ។ ភស្តុតាងនៅថៃ (Onchan and Aungsumalin, 2002) បង្ហាញថា ការផ្តល់ប័ណ្ណកម្មសិទ្ធិដី អាចជួយជំរុញការផ្លាស់ប្តូរមួយចំនួនក្នុងការប្រើប្រាស់ដី ដោយការដាំដុះងាកចេញ

ពីមុខដំណាំ អស់ចំណាយតិច/ផ្តល់ចំណូលតិច (ដូចជា ផលិតកម្មស្រូវ សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ) ហើយបែរទៅខាង ដំណាំពាណិជ្ជកម្ម និង/ឬ ដើមឈើយកផ្លែ ឬដំណាំដើមឈើផ្សេងទៀតដែលទាមទារវិនិយោគ ច្រើនតែផ្តល់ផលចំណេញជាសក្តានុពលខ្ពស់នៅពេលបន្ទាប់ ។ ទោះបីនៅកម្ពុជាមានលក្ខខណ្ឌទីផ្សារ និងកសិកម្ម ខុសគ្នាក្តី ប៉ុន្តែកសិករមួយចំនួន ជាពិសេសអ្នកមានដីកាន់កាប់ធំៗ គឺអាចរំពឹងថានឹងចាប់ផ្តើមធ្វើចំរុះកម្មការប្រើប្រាស់ដី (ដូចជា ចំការនិងដំណាំដើមឈើ) ។ វិសាលភាព និងទំហំនៃចំរុះកម្មនេះ ក៏រំពឹងថានឹងកើនឡើងកាន់តែលឿនស្របតាមទំហំដីកាន់កាប់ ។ អត្រាប្រើប្រាស់ដីក៏អាចកើនឡើងដែរ នៅពេលកសិករចាប់ផ្តើមធ្វើវិនិយោគកាន់តែច្រើនទៅលើផលិតកម្មកសិកម្ម ថ្វីបើអាចយឺតៗដោយសារកង្វះវិធានការខាងគោលនយោបាយដែលជំរុញឱ្យមានអត្រាប្រើប្រាស់ដីកាន់តែខ្ពស់ (ដូចជា ពន្ធលើដីឡូត៍ទំនេរធំៗ) ។ ក្នុងរឿងនេះ ផលប៉ះពាល់នៃប័ណ្ណកម្មសិទ្ធិដី អាចប្រែប្រួលទៅតាមកត្តាទីតាំងនិងកាលៈទេសៈ ដូចជា ការរកបានឥណទាន និងសេវាផ្សព្វផ្សាយបច្ចេកទេស លទ្ធភាពទាក់ទងទីផ្សារ (ដូចជា ចំណាយដឹកជញ្ជូន និងលក់ដូរ, របាំងផ្សេងទៀត) និងថ្លៃផលិតផល[២៩] ។ ប៉ុន្តែផលប៉ះពាល់ពេញលេញនៃប័ណ្ណកម្មសិទ្ធិដីក្នុងរឿងនេះ អាចទាមទារការសង្កេតតាមដានលើសពីបីឆ្នាំ ។

## ២.៨ សកម្មភាពឥណទាននៅក៏រិតគ្រួសារ

កំណើនវិនិយោគ និងចំណាយសំរាប់ផលិតកម្មកសិកម្ម និងសកម្មភាពផលិតកម្មផ្សេងៗទៀត (ឧទាហរណ៍ សហគ្រាសធុនតូច និងមធ្យម) រំពឹងថានឹងជំរុញកំណើនតំរូវការធនធានទុន ។ បន្ទាប់មក ប័ណ្ណកម្មសិទ្ធិដីក្នុងលក្ខណៈរបស់បញ្ចាំ រំពឹងថានឹងបង្កើនលទ្ធភាពរបស់ប្រជាជនក្នុងការទទួលបានឥណទានពីស្ថាប័នឥណទានផ្លូវការ ។ ចំណុចនេះអាចមានសារៈសំខាន់ ជាពិសេស

---

[២៩] សូមអាន Chandararot, Kang and Chan Sophal (2003) សំរាប់ការពិភាក្សាមួយដែលទាក់ទិននឹងចំណាយលើការលក់ដូរក្នុងវិស័យកសិកម្ម ។

ក្នុងការកាត់បន្ថយភាពក្រីក្រ ពីព្រោះប័ណ្ណកម្មសិទ្ធិដីអាចជួយឱ្យសមាជិកក្រីក្រក្នុងសហគមន៍ទទួលបានឥណទានមានតំលៃថោកសំរាប់បំរើផលិតកម្ម ។

**តារាង ២.១៥: ប្រភពឥណទាន (ជាភាគរយនៃកំចីសរុប)**

| ដីកាន់កាប់ (ហ.ត) | សាច់ញាតិ/ មិត្តភក្តិ | | អ្នកចងការប្រាក់ | | NGOs | | អេស៊ីលីដា | | MFIs | | ចំនួនកំចីសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| 0 | 13.3 | 25.0 | 26.7 | 33.3 | 10.0 | 0 | 10.0 | 25.0 | 4 0.0 | 16.7 | 30 | 12 |
| <0.5 | 43.5 | 41.5 | 20.2 | 13.2 | 4.8 | 15.1 | 4.0 | 1.9 | 29.4 | 28.3 | 124 | 53 |
| 0.5 – 0.99 | 53.7 | 38.9 | 13.6 | 11.1 | 8.6 | 25.0 | 8.6 | 2.8 | 5.4 | 22.2 | 162 | 36 |
| 1.0 – 1.99 | 48.1 | 46.9 | 15.3 | 15.6 | 5.3 | 3.1 | 3.8 | 0 | 27.4 | 34.4 | 131 | 32 |
| 2.0 – 2.99 | 36.0 | 30.0 | 12.5 | 40.0 | 15.6 | 10.0 | 9.4 | 0 | 27.6 | 20.0 | 64 | 10 |
| >3.0 | 43.2 | 28.6 | 10.8 | 28.6 | 12.2 | 7.1 | 8.1 | 7.1 | 25.8 | 28.5 | 74 | 14 |
| | | | | | | | | | | | | |
| សរុបជា % | 45.0 | 38.9 | 15.6 | 17.8 | 8.4 | 12.7 | 6.7 | 3.8 | 24.5 | 26.7 | 585 | 157 |
| សរុបកំចី | 263 | 61 | 91 | 28 | 49 | 20 | 39 | 6 | 143 | 42 | 585 | 157 |
| | | | | | | | | | | | | |
| សរុប | 324 | | 119 | | 69 | | 45 | | 185 | | 742 * | |
| សរុប ជា % នៃកំចី | 43.7 | | 16.0 | | 9.3 | | 6.1 | | 24.9 | | | |

*⋆ ដកចេញ ១*

ប៉ុន្តែដូចចំណាយ និងវិនិយោគទុនក្នុងផលិតកម្មកសិកម្មដែរ គេរំពឹងថាមានការប្រែប្រួលខ្លះក្នុងសកម្មភាពឥណទាន ទាក់ទិននឹងភាពញឹកញាប់ ទំហំកំចី និងការប្រើប្រាស់កំចីយោងតាមទំហំដីកាន់កាប់ និងយេនឌ័រមេគ្រួសារ។ ឧទាហរណ៍ ការបែងចែកឥណទានអាចប្រែប្រួលទៅតាមសមត្ថភាពគ្រួសារក្នុងការគ្រប់គ្រងនិងសងការប្រាក់កំចីក្នុងទំហំខុសៗគ្នា ។ គ្រួសារក្រីក្រដែលអាចគ្រប់គ្រងត្រឹមតែកំចីតូចៗ ដោយសារលទ្ធភាពខាងរបស់បញ្ចាំ (ដូចជាទំហំដីឡូត៍) និងសមត្ថភាពសងតាមកាលកំណត់ជាក់លាក់ គឺអាចបន្តប្រើប្រភពឥណទានក្រៅផ្លូវការផ្សេងទៀត (ឧទាហរណ៍ គ្រួសារ និងអ្នករកស៊ីចងការប្រាក់) សំរាប់គោលដៅផ្សេងៗ ។ ទន្ទឹមនេះគ្រួសារមានដីកាន់កាប់ច្រើន ទ្រព្យជាមូលធន និងប្រាក់ចំណូល គឺអាចប្រើប័ណ្ណកម្មសិទ្ធិដី ដើម្បីទទួលបានកំចីច្រើនៗពីប្រភពផ្លូវការ ដើម្បីពង្រីក ឬធ្វើចំរុះកម្មសកម្មភាពកសិកម្ម និង/ឬ ជំនួញរបស់ខ្លួន ។

ក្នុងតំបន់អង្កេត LMAP មាន ៩៣១គ្រួសារ (ប្រហែល ៥៤,៧%នៃគ្រួសារសរុប) រាយការណ៍ថា មានសរុប ៧៤៣កំចី ក្នុងរយៈ៦ខែមុនពេលធ្វើអង្កេត រឺ ប្រហែល ១,៤០កំចី ក្នុងមួយគ្រួសារដែលខ្ចី ។ គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ មាន ៧៩% និង ២១% នៃកំចីរៀងៗគ្នា ។ តារាង២.១៥ បង្ហាញថា កំចីប្រហែល ៦០% ទទួលបានពីវិស័យក្រៅផ្លូវការ រួមមាន សាច់ញាតិនិងមិត្តភក្តិ(៤៣,៧%) និងអ្នករកស៊ីចងការប្រាក់(១៦%) ។ កំចី ៣១% ទទួលបានពីវិស័យផ្លូវការ គឺមាន អេស៊ីលីដា(៦,១%) និង MFIs (២៤,៩%) ។ កំចីប្រហែល ៩% ទទួលបានពីវិស័យ "ពាក់កណ្តាលផ្លូវការ" របស់ NGO ។

តារាង ២.១៦ ខាងក្រោមបង្ហាញថា កំចីសំរាប់វិនិយោគមានផលិតភាព តំណាងឱ្យ ៣៦% នៃសកម្មភាពឥណទានទាំងអស់នៅក្នុងក្រុមអង្កេត LMAPក្នុងនេះមាន សកម្មភាពទាក់ទិននឹងជំនួញតូចតាច (១២%) ផលិតកម្មកសិកម្ម (១៤,៤%) និងការចិញ្ចឹមសត្វ (៩,៦%) ។ គ្រួសារបុរសមេគ្រួបានខ្ចីច្រើនជាងសំរាប់កសិកម្មនិងជំនួញ ហើយគ្រួសារស្ត្រីមេគ្រួបានខ្ចីច្រើនជាងសំរាប់ការចិញ្ចឹមសត្វ ។

ការថែទាំសុខភាព (២១,៧%) និងកង្វះស្បៀងអាហារ (១៧,៩%) តំណាងឱ្យជិត ៤០%នៃសកម្មភាពឥណទានទាំងអស់ក្នុងក្រុមអង្កេត។ គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ មានភាគរយប្រហែលគ្នាក្នុងការខ្ចីសំរាប់ចំណាយលើការថែទាំសុខភាព ហើយគ្រួសារស្ត្រីមេគ្រួ ដែលខ្ចីប្រាក់មកបំពេញកង្វះស្បៀងអាហារក្នុងគ្រួសារ គឺមានភាគរយខ្ពស់ជាងគ្រួសារបុរសមេគ្រួ។ រឿងនេះបង្ហាញថា គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ រងឥទ្ធិពលប្រហាក់ប្រហែលគ្នាពីជំងឺ ហើយគ្រួសារស្ត្រីមេគ្រួមានសមត្ថភាពតិចជាងក្នុងការផលិតស្បៀងឱ្យបានគ្រប់គ្រាន់។ កំចីនៅសល់ ២៤,៥% គឺសំរាប់សកម្មភាពផ្សេងៗ ដែលរួមមាន បុណ្យទាន សាងសង់ផ្ទះ និងដឹកជញ្ជូន ។

ជាទូទៅ សំរាប់ទំហំដីកាន់កាប់ពីរចន្លោះខាងលើ មិនសូវមានខ្ចីញឹកញាប់ដូចគ្រួសារឯទៀតទេ ដែលប្រហែលមកពីគេអាចប្រើធនធានផ្ទាល់របស់ខ្លួន សំរាប់ធ្វើវិនិយោគជាមូលធន។ សំរាប់ទំហំដីកាន់កាប់បីចន្លោះខាងលើ តែងមានខ្ចីសំរាប់បំរើផលិតកម្ម ច្រើនជាង ក្រុមមានដី

កាន់កាប់តិច ។ កំរិតនៃការខ្ចីសំរាប់កង្វះស្បៀងអាហារ ហាក់ដូចប្រហាក់ប្រហែលគ្នាសំរាប់គ្រួសារទាំងអស់ ប៉ុន្តែគ្រួសារកាន់កាប់ដីតូចៗ ហាក់ដូចមានខ្ចីសំរាប់ចំណាយថែទាំសុខភាពច្រើនជាងគ្រួសារកាន់កាប់ដីធំៗ ។

### តារាង ២.១៦: ការប្រើប្រាស់កំចីតាមទំហំដីកាន់កាប់

| ទំហំដី | កសិកម្ម | | ជំនួញ | | កង្វះស្បៀង | | សុខភាព | | បសុសត្វ | | ផ្សេងៗ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| | | | | | | | | | | | | | | |
| 0 | 3.3 | 0 | 33.3 | 33.3 | 20.0 | 8.3 | 10.0 | 33.3 | 10.0 | 8.3 | 23.3 | 16.8 | 30 | 12 |
| <0.5 | 9.5 | 3.8 | 8.7 | 9.6 | 15.9 | 25.0 | 31.7 | 19.2 | 7.9 | 15.4 | 26.3 | 27.0 | 126 | 52 |
| 0.5 – 0.99 | 12.3 | 19.4 | 13.0 | 2.8 | 15.4 | 30.6 | 18.5 | 11.1 | 9.3 | 16.7 | 31.5 | 19.4 | 162 | 36 |
| 1.0 – 1.99 | 15.8 | 0 | 10.5 | 0 | 21.8 | 28.1 | 27.1 | 31.3 | 5.3 | 21.9 | 19.5 | 18.7 | 133 | 32 |
| 2.0 – 2.99 | 28.1 | 20.0 | 10.9 | 0 | 20.3 | 10.0 | 15.6 | 10.0 | 4.7 | 20.0 | 20.4 | 40.0 | 64 | 10 |
| >3.0 | 25.0 | 42.9 | 20.8 | 7.1 | 6.9 | 0 | 15.3 | 14.3 | 12.5 | 0 | 19.5 | 35.7 | 72 | 14 |
| | | | | | | | | | | | | | | |
| សរុបជា % | 15.3 | 10.9 | 13.3 | 7.1 | 16.7 | 22.4 | 22.1 | 19.9 | 8.0 | 15.4 | 24.6 | 24.3 | | |
| សរុបកំចី | 90 | 17 | 78 | 11 | 98 | 35 | 130 | 31 | 47 | 24 | 144 | 38 | 587 | 156 |
| | | | | | | | | | | | | | | |
| សរុប | 107 | | 89 | | 133 | | 161 | | 71 | | 182 | | 743 | |
| សរុបជា % | 14.4 | | 12.0 | | 17.9 | | 21.7 | | 9.6 | | 24.5 | | | |

តារាង២.១៧ បង្ហាញថា ទំហំកំចីជាមធ្យមពីអេស៊ីលីដា គឺប្រហែល ៨៩ម៉ឺនរៀល ដែលគេគិតថា ខ្ពស់យ៉ាងខ្លាំងជាងប្រភពផ្សេងៗទៀត ។ រឿងគួរឱ្យភ្ញាក់ផ្អើលគឺ ទំហំកំចីជាមធ្យមពី MFIs ប្រហែលតែ ២៨,១៣ម៉ឺនរៀលប៉ុណ្ណោះដែលទាបបន្តិចផង ជាងទំហំកំចីជាមធ្យមពីសាច់ញាតិនិងមិត្តភក្តិ (២៩,៥ម៉ឺនរៀល) ។ ទំហំកំចីជាមធ្យមពីអ្នកចងការប្រាក់ និង NGOs គឺស្រដៀងគ្នាត្រឹម ២៣,៧៧ម៉ឺនរៀល និង ២៥,១៩ម៉ឺនរៀល រៀងគ្នា ។ ជាទូទៅ ទំហំកំចីជាមធ្យមសំរាប់សកម្មភាពផលិតកម្ម (ដូចជា ជំនួញ កសិកម្ម ចិញ្ចឹមសត្វ) គឺធំជាង ទំហំកំចីជាមធ្យមសំរាប់កង្វះស្បៀង និងការថែទាំសុខភាព ។ ប៉ុន្តែ ទំហំជាមធ្យមនៃ "កំចីផ្សេងៗ" (៤២,៧២ម៉ឺនរៀល) គឺតូចជាង តែកំចីសំរាប់សកម្មភាពជំនួញប៉ុណ្ណោះ (៥៣,២៦ម៉ឺនរៀល) ។

## តារាង ២.១៧: ប្រភពឥណទានលំអិតតាមការប្រើប្រាស់កំចី

| គោលដៅ | ញាតិ/មិត្តភក្តិ | | អ្នកចងការប្រាក់ | | NGOs | | អេស៊ីលីដា | | MFIs | | កំចីសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ទឹកប្រាក់ | ចំនួន | ទ.ប្រាក់ | ចំនួន | ទ.ប្រាក់ | ចំនួន | ទ.ប្រាក់ | ចំនួន | ទ.ប្រាក់ | ចំនួន | ទ.ប្រាក់ |
| កសិកម្ម | 36 | 21.97 | 22 | 22.39 | 14 | 20.71 | 6 | 59.2 | 28 | 33.07 | 106 | 26.9 |
| ជំនួញ | 18 | 72.57 | 14 | 24.46 | 14 | 20.79 | 14 | 137.9 | 28 | 29.14 | 88 | 53.26 |
| កង្វះស្បៀង | 70 | 13.61 | 25 | 19.98 | 3 | 10.67 | 10 | 27.7 | 26 | 12.36 | 134 | 15.55 |
| សុខភាព | 82 | 24.88 | 22 | 21.05 | 7 | 24.00 | 7 | 45.0 | 42 | 15.16 | 160 | 22.65 |
| បសុសត្វ | 15 | 36.53 | 5 | 14.8 | 17 | 19.82 | 4 | 140.0 | 34 | 28.59 | 75 | 33.23 |
| ផ្សេងៗ | 103 | 38.07 | 31 | 30.87 | 14 | 44.22 | 6 | 124.2 | 30 | 53.93 | 184 | |
| | | | | | | | | | | | | |
| សរុប | 324 | 29.5 | 119 | 23.77 | 69 | 25.19 | 47 | 89.00 | 188 | 28.13 | 747 | 31.60 |
| | | | | | | | | | | | | |
| % នៃសរុប | 43.40 | | 15.9 | | 9.2 | | 6.3 | | 25.2 | | | |

ជាការមានប្រយោជន៍បើប្រៀបធៀបទិន្នន័យនេះជាមួយនឹងការសិក្សាផ្សេងៗទៀត ។ ឧទាហរណ៍ Sophal and Acharya (2002) រកឃើញថា ប្រភពឥណទានធំបំផុតគឺ សាច់ញាតិនិងមិត្តភក្តិ(៤៤,៥%) បន្ទាប់មកគឺ អ្នកចងការប្រាក់(៣៣,១%) ប្រភពស្ថាប័ន(១៥,៧%) និងប្រភពផ្សេងទៀត ។ ទោះបីភាគរយកំចីបានពីសាច់ញាតិនិងមិត្តភក្តិ វាស្រដៀងគ្នាខ្លាំងក្តី ប៉ុន្តែភាគរយកំចីបានពីអ្នករកស៊ីចងការប្រាក់ (១៦%) និងស្ថាប័នផ្លូវការ (៣១%) គឺផ្ទុយគ្នាស្រឡះពីគំរូតាងអង្កេតជាមូលដ្ឋាន ។ រឿងនេះអាចពន្យល់ម្យ៉ាងបានថា ប្រហែលមកពីនៅតាមកន្លែងជាច្រើននៃតំបន់អង្កេត BSP មានស្ថាប័នឥណទានផ្លូវការច្រើនជាង បើធៀបនឹងតំបន់ដែលសិក្សាដោយ Sophal and Acharya ។ ក្នុងន័យនេះ ទិន្នន័យអង្កេតមូលដ្ឋាន អាចឆ្លុះបញ្ចាំងពីការរីកដុះដាល MFIs នៅក្នុងតំបន់ផ្សេងៗនៅកម្ពុជាតាំងពីឆ្នាំ២០០១ មក។ ចំនុចនេះបង្ហាញថា ក្នុងតំបន់ដែលការផ្គត់ផ្គង់ឥណទានផ្លូវការកើនឡើង ប្រជាជនចូលចិត្តស្ថាប័នផ្លូវការជាងអ្នកចងការប្រាក់ *បើសិនគេអាចរ៉ាប់រងអត្រាការប្រាក់ និងបំពេញបានតាមការតំរូវជាផ្លូវការផ្សេងៗទាក់ទិននឹងរបស់បញ្ចាំ*[៣០] ។

---

[៣០] សូមអាន Kang (2002) and Ballard (2004) ទាក់ទិននឹងការលួតលាស់ៗក្នុងទីផ្សារឥណទានជនបទ។

ចំពោះទំហំកំចីជាមធ្យម ទិន្នន័យអង្កេតមូលដ្ឋាន ស៊ីគ្នាជាខ្លាំងជាមួយនឹងទិន្នន័យជីវភាពជនបទ ។ ក្នុងការសិក្សាទាំងពីរ ទំហំកំចីជាមធ្យមដែលធំជាងគេគឺជារបស់ អេស៊ីលីដា ដែលជា MFI ដ៏ល្បីនៅកម្ពុជា នៅពេលធ្វើការសិក្សាពីជីវភាពនៅជនបទ (Sophal and Acharya, 2002) បន្ទាប់មកគឺ អ្នកចងការប្រាក់ រួចហើយគឺ សាច់ញាតិនិងមិត្តភក្តិ ។ ការខុសគ្នាដ៏ចំបងទាក់ទិននឹងចំណុចដែល MFIs គ្មានលើកឡើងទេនៅក្នុងការសិក្សាពីជីវភាពនៅជនបទ។ ទោះជាយើងរំពឹងថា ទំហំជាមធ្យមនៃកំចីទាំងនេះអាចស្ថិតក្នុងចន្លោះរវាង អេស៊ីលីដា និងអ្នកចងការប្រាក់ក្តី ក៏អង្កេតជាមូលដ្ឋានរកឃើញថា ទំហំកំចីជាមធ្យមពី MFIs តាមពិតគឺតូចជាងទំហំកំចីពីសាច់ញាតិនិងមិត្តភ័ក្តិ ។ ការពន្យល់មួយចំពោះរឿងនេះគឺ MFIs បានកើតចេញពីសមាគមឥណទានតូចៗគាំទ្រដោយ NGO ហើយជារឿយៗតែងរក្សាទុកលក្ខណៈខ្លះនៃរចនាសម្ព័ន្ធដើម (ឧទាហរណ៍ ក្រុមតូចៗ) និងគោលដៅ (ឧទាហរណ៍ កំចីខ្នាតតូចសំរាប់អ្នកក្រ) របស់ខ្លួន ។

តាមពិត ប្រជាជននៅគ្រប់កំរិតចំណូលទាំងអស់ និង/ឬ ចន្លោះទំហំដីកាន់កាប់ជាប្រពៃណីតែងខ្ចីពីប្រភពជាច្រើន យោងតាមភាពចាំបាច់ និងកាលៈទេសៈ (ឧទាហរណ៍ ភាពបន្ទាន់, រដូវកាល) ។ ជាលទ្ធផល ការសំរេចចិត្តពីប្រភព និងការប្រើប្រាស់កំចី គឺមានលក្ខណៈជាយុទ្ធសាស្ត្រ (ឧទាហរណ៍ វិនិយោគ) និងយុទ្ធវិធី (ឧទាហរណ៍ តំរូវការសាច់ប្រាក់ក្នុងគ្រួសារ) ។ ឧទាហរណ៍ ទោះជាប្រជាជនអាចចូលចិត្តខ្ចីពី NGOs និង MFIs ក្តី ក៏ភាពបន្ទាន់ខាងសុខភាព ឬការមិនអាចរករបស់បញ្ចាំបានសំរាប់ធាតុចូលកសិកម្ម អាចជំរុញឱ្យពួកគេបន្តខ្ចីពីអ្នកចងការប្រាក់ រឹឈ្នួញ ។ ជាលទ្ធផល ទីផ្សារហិរញ្ញវត្ថុជនបទ នៅតែដាច់គ្នាជាបំណែកៗយ៉ាងច្រើន ដូច្នេះការផ្លាស់ប្តូរ ក្នុងរយៈពេលវែងពីការខ្ចីពីប្រភពក្រៅផ្លូវការ ទៅប្រភពផ្លូវការ មិនមែនសុទ្ធតែរីកលូតលាស់ ទៅមុខយ៉ាងទៀងទាត់នោះទេ (linear progression) ។

ទ្រឹស្តីស្រាវជ្រាវទស្សន៍ទាយថា ចំនួន និងទឹកប្រាក់ជាមធ្យមនៃកំចីសំរាប់វិនិយោគក្នុងផលិតកម្មកសិកម្ម និងសកម្មភាពបង្កើតចំណូលផ្សេងទៀត (ឧទាហរណ៍ ការចិញ្ចឹមសត្វ, ជំនួញតូចៗ) នឹងកើនឡើង បើធៀបនឹងកំចីសំរាប់ការប្រើប្រាស់ និងសកម្មភាពផ្សេងៗទៀត ។

ទ្រឹស្តីស្រាវជ្រាវក៏ទស្សន៍ទាយដែរថា នៅពេលចំនួន និងទឹកប្រាក់កំចីកើនឡើង ប្រភពកំចីនឹងប្តូរច្រើនពីវិស័យក្រៅផ្លូវការ ទៅវិស័យផ្លូវការ ។ ប៉ុន្តែក្នុងនេះមានការសន្មតថា តំរូវការកំចីសំរាប់ការថែទាំសុខភាព និងស្បៀងបំពេញបន្ថែម នឹងថយចុះ បើធៀបនឹងកំចីផលិតកម្ម ។ ឧទាហរណ៍ អ្នកស្រាវជ្រាវបានអង្កេតឃើញថា ការខ្ចីដោះទាល់ក្នុងរយៈពេលខ្លី បានដាក់បន្ទុកយ៉ាងធ្ងន់ទៅលើអ្នកក្រ ហើយអាចច្រានចេញអស់នូវការវិនិយោគមានផលិតភាពជាសក្តានុពលផ្សេងៗ (Murshid, 1998; Chan and Acharya, 2002) ។ អ្នកស្រាវជ្រាវក៏បានតភ្ជាប់ចំណាយថែទាំសុខភាព ទៅនឹងការលក់ទ្រព្យសកម្មផ្សេងៗ មានទាំងដីផង (Biddulph, 2004) ។ ហេតុនេះ ការថែទាំសុខភាព និងសន្តិសុខស្បៀង គឺជាចំណុចពីរដែលត្រូវយកចិត្តទុកដាក់ បើសិនចង់ឱ្យគោលនយោបាយដែលតាក់តែងឡើង ដើម្បីតំរង់ទិសធនធានហិរញ្ញវត្ថុទៅរកការប្រើប្រាស់មានផលិតភាពខ្ពស់បំផុត អាចទទួលបានជោគជ័យ ។

សម្មតិកម្មនេះបានសន្មតដែរថា ទីផ្សារឥណទានមានដំណើរការល្អគួរសមនៅក្នុងតំបន់ជាក់លាក់ណាមួយ (ឧទាហរណ៍ ឥណទានអាចរកបាន ចំណាយប្រតិបត្តិការមានកំរិតទាប) ហើយ ប្រជាជនមានទំនោរចិត្ត និងមានសមត្ថភាពខ្ចី ។ គេសន្មតទៀតថា អត្រាការប្រាក់របស់ស្ថាប័នផ្លូវការ វាអំណោយផលជាង អត្រារបស់អ្នកចងការប្រាក់នៅមូលដ្ឋាន ។ បើសិនកត្តាផ្សេងទៀតល្អស្មើគ្នាទាំងអស់ យើងអាចរំពឹងថា សកម្មភាពឥណទាននឹងមានច្រើននៅក្នុងតំបន់នានាដែលកសិករក្នុងមូលដ្ឋានអាចទៅទាក់ទងស្ថាប័នឥណទានផ្លូវការបានងាយស្រួល ។ ដូច្នេះកសិករដែលនៅជិតទីរួមស្រុក និង/ឬ ទីផ្សារតាមដងផ្លូវ ប្រហែលទទួលបានឥណទានផ្លូវការ ច្រើនជាងអ្នកដែលនៅឆ្ងាយ ឬនៅតំបន់ដាច់ស្រយាល ។

មានភស្តុតាងមួយចំនួនដែលបញ្ជាក់គាំទ្រដល់សម្មតិកម្មទាំងនេះ ។ ឧទាហរណ៍ Chan and Acharya (2002) បានសង្កេតឃើញថា ប្រជាជនតែងបានខ្ចីច្រើននៅតាមភូមិដែលបានធ្វើពាណិជ្ជភាវូបនីយកម្មលើសកម្មភាពនានា ដោយសារមានសមាហរណកម្មទីផ្សារកំរិតខ្ពស់ ។ ប្រជាជនក្នុងភូមិមួយចំនួន ក៏ខ្ចីជាទឹកប្រាក់ច្រើនៗ ជាងកន្លែងឯទៀតដែរ ។ ពួកគេលើកមតិថា

ចំនួនដង ទំហំ និងការប្រើប្រាស់កំចី អាចជាប់ទាក់ទិននឹងកំរិតទំនើបកម្មកសិកម្ម និង/ឬ ភាពមមាញឹកនៃសកម្មភាពមិនមែនកសិកម្ម ។

តារាង ២.១៨ បង្ហាញពីបំរែបំរួលស្រដៀងគ្នានៅក្នុងតំបន់អង្កេត LMAP ។ ឧទាហរណ៍ ត្រពាំងសាប (តាកែវ) ស្រយូវ (កំពង់ធំ) និសំបូរ (កំពង់ចាម) គឺជាឃុំមានសកម្មភាពសេដ្ឋកិច្ច មមាញឹកជាងគេនៅក្នុងគំរូតាងអង្កេត ដោយសារទីតាំងនៅតាមដងផ្លូវធំៗ និងនៅជិតមជ្ឈមណ្ឌលពាណិជ្ជកម្ម ។ ឃុំទាំងនេះ ទទួលបានបីចំណាត់ថ្នាក់ខ្ពស់ជាងគេក្នុងចំនួនដងកំចី, បីចំណាត់ថ្នាក់ខ្ពស់ជាងគេក្នុងអត្រាកំចីខ្ពស់ (ចំនួនកំចីក្នុងមួយគ្រួសារអ្នកខ្ចី), ហើយក៏មានកំរិតភាគរយខ្ពស់ជាងគេនៃកំចីពីប្រភពផ្លូវការ (ក្នុងនេះមាន អេស៊ីលីដា និង MFIs) ។ ដោយសារទីតាំងរបស់ខ្លួន ឃុំទីពូ(កំពង់ធំ) មានសមាហរណកម្មទីផ្សារកំរិតទាបជាង និងមានសកម្មភាពសេដ្ឋកិច្ចតិចមុខជាង ។ ទីពូ ក៏មានចំនួនដងខ្ចីប្រាក់ទាបបំផុត និងមានកំរិតភាគរយ ទាបបំផុតនៃការខ្ចីពីប្រភពផ្លូវការដែរ ។

**តារាង ២.១៨: ការចែកចាយកំចីតាមឃុំ និងប្រភព**

| ឃុំ | ក្រៅផ្លូវការ | ពាក់កណ្តាលផ្លូវការ | ផ្លូវការ | កំចីសរុប | |
|---|---|---|---|---|---|
| | | | | ចំនួនកំចី | ចំនួនកំចី/គ្រួសារ |
| | | | | | |
| ត្រពាំងសាប | 44.3 | 8.4 | 33.6 | 131 | 1.03 |
| រវាង | 62.2 | 7.3 | 22.9 | 109 | 1.18 |
| ស្រយូវ | 58.1 | 11.8 | 30.1 | 93 | 1.50 |
| ទីពូ | 79.0 | 3.0 | 16.9 | 77 | .65 |
| សំបូរ | 70.2 | 0 | 29.8 | 114 | 1.16 |
| ស្រង៉ែ | 85.7 | 1.1 | 13.2 | 91 | 1.12 |

ការបែងចែកជាកំចីសំរាប់ផលិតកម្ម និងកំចីសំរាប់ការប្រើប្រាស់ ក៏ខុសគ្នាខ្លះដែរ យោងតាមឃុំ ។ ឧទាហរណ៍ នៅសំបូរ និងស្រយូវ សកម្មភាពផលិតកម្ម តំណាងឱ្យ ៥៦.១%

និង ៣៦,៦% នៃកំចី ។ ប៉ុន្តែនៅ ទីពូ មានតែ ១៤,៣% នៃកំចីប៉ុណ្ណោះដែលសំរាប់បំរើផលិតកម្ម រីឯ ៦៣,៦% ទៀតគឺសំរាប់ការប្រើប្រាស់ ។

## ២.៩ សន្និដ្ឋាន

ក៏រិតដែលសិទ្ធិកាន់កាប់ដីមានសុវត្ថិភាព អាចរួមចំណែកដល់ការអភិវឌ្ឍន៍សង្គម កំនើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ គឺផ្អែកមួយភាគធំទៅលើសមត្ថភាពរដ្ឋបាលសាធារណៈ ក្នុងការគ្រប់គ្រង និងពង្រឹងការអនុវត្តន៍កម្មសិទ្ធិអចលនវត្ថុឱ្យបានសក្តិសិទ្ធិ ។ ផលប៉ះពាល់នៃប័ណ្ណកម្មសិទ្ធិដី ទំនងជាបានច្រើនបំផុត នៅពេលប្រជាជនមានជំនឿលើសមត្ថភាព និងការប្តេជ្ញារបស់រដ្ឋាភិបាល ក្នុងការលើកស្ទួយ និងពង្រឹងការអនុវត្តន៍កម្មសិទ្ធិដី តាមបែបបទមានតម្លាភាព និងយុត្តិធម៌ ។ ក្នុងន័យនេះ ប្រជាជននៅក្នុងតំបន់អង្កេតមូលដ្ឋាន បានបង្ហាញនូវទំនុកចិត្តពីដំបូងយ៉ាងខ្ពស់ចំពោះប័ណ្ណកម្មសិទ្ធិដីដែល LMAP កំពុងតែចេញឱ្យ ។

ផលចំណេញបានពីប័ណ្ណកម្មសិទ្ធិដី ក៏ផ្អែកទៅលើកាលៈទេសៈនៅតាមមូលដ្ឋាន ដូចជា ក) កំរិតសកម្មភាពទីផ្សារដីធ្លី ខ) វត្តមានឥណទាន សេវាផ្សព្វផ្សាយបច្ចេកទេស ការថែទាំសុខភាព និងសេវាសង្គមផ្សេងទៀត គ) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង ឃ) ទីតាំងជាប់ទាក់ទិននឹងមធ្យោបាយដឹកជញ្ជូន និងទីផ្សារ ។ ផលចំណេញសំរាប់គ្រួសារនានា និងសង្គម ទំនងជាមានច្រើនបំផុតនៅតាមតំបន់ដែលមានទីផ្សារដីធ្លីសកម្ម និងងាយទទួលបានសេវាកម្មអភិវឌ្ឍន៍ ។ ការរួមចំណែករបស់ប័ណ្ណកម្មសិទ្ធិដី ដល់ការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ អាចបានប្រសើរបំផុត ដោយផ្តោតការប្រឹងប្រែងផ្តល់ប័ណ្ណកម្មសិទ្ធិដី ទៅលើតំបន់ទាំងឡាយណាដែលមានស្ថាប័នរដ្ឋាភិបាល, NGOs, អ្នកផ្តល់ជំនួយ, និងវិនិយោគិនឯកជន កំពុងធ្វើសកម្មភាព ។

ផលចំណេញបានពីប័ណ្ណកម្មសិទ្ធិដី ក៏ផ្អែកផងដែរទៅលើលក្ខណៈសម្បត្តិរបស់គ្រួសារ ។ ទំហំដីកាន់កាប់ និងយេនឌ័រមេគ្រួសារ តែងតែជាចំនុចដ៏ល្អសំរាប់ទស្សន៍ទាយពីកំលាំងពលកម្ម ទ្រព្យសកម្ម និងចំណូលរបស់គ្រួសារ ព្រមទាំងផ្តល់នូវអាំងឌីកាទ័រល្អមួយនៃសមត្ថភាពជាសក្តានុពលរបស់គ្រួសារដើម្បីទទួលបានផលប្រយោជន៍ពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដី ។ គ្រួសារ

មានដីកាន់កាប់ធំៗ មានស្ថានភាពល្អជាងក្នុងការទទួលបានផលប្រយោជន៍ពីប័ណ្ណកម្មសិទ្ធិដី បើធៀបនឹងគ្រួសារមានដីកាន់កាប់តូច ។ ម្យ៉ាងទៀត គ្រួសារបុរសមេគ្រួ ក៏ច្រើនមានស្ថានភាពល្អជាង ក្នុងការទទួលបានផលប្រយោជន៍ពីប័ណ្ណកម្មសិទ្ធិដី បើធៀបនឹងគ្រួសារស្ត្រីមេគ្រួ ។ ផលចំណេញចំពោះគ្រួសារងាយរងគ្រោះ និងការចាញ់ប្រៀប អាចបង្កើនបានដោយផ្តោតកិច្ចប្រឹងប្រែងផ្តល់ប័ណ្ណកម្មសិទ្ធិដី នៅតាមតំបន់នានាដែលមានសេវាកម្មសង្គម និងធនធានអភិវឌ្ឍន៍ផ្តោតទៅលើអ្នកក្រ ។ រឿងនេះមានសារៈសំខាន់ជាពិសេសចំពោះគ្រួសារនានាដែលខិតទៅដល់មាត់ជ្រោះនៃភាពអត់ដីធ្លីស្រាប់ហើយ ។

ការកែលំអសុវត្ថិភាពការកាន់កាប់ដី ក្នុងទំរង់ជាប័ណ្ណកម្មសិទ្ធិដី រំពឹងថានឹងជំរុញឱ្យមានវិនិយោគកសិកម្មច្រើនជាងមុន និងបែងចែកដីសំរាប់ការប្រើប្រាស់ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ។ ល្បឿនវិនិយោគកសិកម្ម ប្រហែលអាចប្រែប្រួលទៅតាមទំហំដីកាន់កាប់ ក្នុងនេះគ្រួសារកាន់កាប់ដីធំៗ នឹងធ្វើវិនិយោគច្រើនជាង គ្រួសារកាន់កាប់ដីតូចៗ ។ ល្បឿន និងប្រភេទវិនិយោគកសិកម្ម ក៏ពឹងផ្អែកផងដែរទៅលើកត្តាផ្សេងៗទៀត ដូចជា វត្តមាន ឥណទានស្ថាប័ន និងសេវាផ្សព្វផ្សាយបច្ចេកទេសនៅក្នុងតំបន់នីមួយៗ និងលក្ខខណ្ឌនៅមូលដ្ឋាន (ដូចជា អាកាសធាតុ គុណភាពដី) ។ ល្បឿនចំរុះកម្មការប្រើប្រាស់ដី ក៏ពឹងផ្អែកទៅលើកត្តាផ្សេងៗ ដូចជា ថ្លៃនៅទីផ្សារ និងពត៌មានទីផ្សារ ។ គេរំពឹងថា អ្នកកាន់កាប់ដីធំៗនឹងធ្វើចំរុះកម្មការប្រើប្រាស់ដីកាន់តែលឿននៅពេលខាងមុខ ប៉ុន្តែផលប៉ះពាល់ជាក់ស្តែងមិនអាចសង្កេតឃើញទេនៅមុនរយៈពេល ៣ឆ្នាំក្រោយ ។ អ្នកកាន់កាប់ដីធំៗ ក៏អាចបង្កើនអត្រាការប្រើប្រាស់ដីដែរ ។

គេរំពឹងដែរថា ប័ណ្ណកម្មសិទ្ធិដីធ្លីដែលអាចប្រើជារបស់ធានាបាន នឹងជួយបង្កើនលទ្ធភាពទទួលបានឥណទានស្ថាប័ន ។ ប៉ុន្តែ ផលប៉ះពាល់ជាក់ស្តែងនៃប័ណ្ណកម្មសិទ្ធិដី ទៅលើលទ្ធភាពទទួលបានឥណទាន គឺអាស្រ័យលើកត្តាជាច្រើនទៀត ដែលប៉ះពាល់ដល់អាកប្បកិរិយារបស់ប្រជាជនក្នុងការខ្ចីប្រាក់ ដូចជា លក្ខខណ្ឌឥណទានស្ថាប័ន ការប៉ះទង្គិចនិងតំរូវការបន្ទាន់របស់គ្រួសារ ការរំពឹងទុកពីថ្លៃផលិតកម្មនិងថ្លៃទីផ្សារ និងរបៀបរបបនៃជំរើសឥណទានផ្សេងទៀត ។ ជាទូទៅ គេរំពឹងថា នឹងមានសកម្មភាពឥណទានកាន់តែច្រើននៅតាមតំបន់ដែលងាយ

ទៅទាក់ទងស្ថាប័នឥណទានផ្លូវការ ។ កសិករដែលនៅជិត ទីរួមស្រុក និង/ឬ ទីផ្សារនៅតាមផ្លូវ ប្រហែលទទួលបានឥណទានផ្លូវការ ច្រើនជាង អ្នកនៅឆ្ងាយៗ ឬនៅតំបន់ដាច់ស្រយាល ។ ម្យ៉ាងទៀតអាចមានការប្រែប្រួលខុសគ្នាខ្លះៗក្នុង ចំនួនដង ទំហំ និងការប្រើប្រាស់កំចី យោងតាមទំហំដី និងយេនឌ័រមេគ្រួសារ ។ សំរាប់គោលដៅផលិតកម្ម គ្រួសារមានដីកាន់កាប់តូច និងធនធានតិច នឹងទទួលបានកំចីតូចនិងតិចដង រីឯគ្រួសារកាន់កាប់ដីធំ នឹងទទួលបានកំចីច្រើន និងញឹកញាប់ជាងទៀតផង ។

ផលចំណេញសំរាប់គ្រួសារទន់ខ្សោយចាញ់ប្រៀបគេ ក៏អាចបង្កើនឡើងបានតាមរយៈគោលនយោបាយនានាដែលផ្សារភ្ជាប់យ៉ាងជាក់លាក់នូវ កិច្ចប្រឹងប្រែងផ្តល់ប័ណ្ណកម្មសិទ្ធិដីទៅនឹងគោលដៅអភិវឌ្ឍន៍ផ្សេងៗដែលជួយដល់អ្នកក្រ ។ គោលនយោបាយពីរវិស័យដែលមានសក្តានុពលគឺមាន ឥណទាន និងហិរញ្ញវត្ថុសាធារណៈ ។ ឧទាហរណ៍ គោលនយោបាយនិងរបៀបរបបអនុវត្តន៍នានា ដែលរក្សាអត្រាការប្រាក់ឱ្យនៅខ្ពស់ នៅក្នុងវិស័យផ្លូវការ វាធ្វើឱ្យខូចខាតដល់ផលប្រយោជន៍ជាសក្តានុពលនៃប័ណ្ណកម្មសិទ្ធិដី ដោយបង្អាក់ទឹកចិត្តប្រជាជនក្នុងការទៅសុំខ្ចីឥណទាន ។ គោលនយោបាយនានាដែលសំដៅកាត់បន្ថយអត្រាការប្រាក់ អាចជួយកែលំអលទ្ធភាពទទួលបានឥណទានក្នុងចំណោមអ្នកកាន់កាប់ដីតូចៗ ។ ទន្ទឹមនឹងនេះ វត្តមានដីកាន់កាប់ធំៗទុកទំនេរចោល វាលើកទឹកចិត្តដល់សកម្មភាពជួញដី និងជំលោះដីធ្លី ព្រមទាំងបង្អាក់ដល់ចំរុះកម្មការប្រើប្រាស់ដី និងការប្រើប្រាស់ដីក្នុងអត្រាខ្ពស់ ។ ពន្ធលើដីធ្លីមិនប្រើប្រាស់ក្នុងទំហំណាមួយ អាចជួយកាត់បន្ថយការជួញដី បង្កើនអត្រាការប្រើប្រាស់ដី ព្រមទាំងផ្តល់ចំណូលឱ្យរដ្ឋទៀតផង ។

# ឯកសារយោង

Alchian, Armen and Harold Demsetz, 1973; “The Property Rights Paradigm,” *The Journal of Economic History,* 33(1): 27.

Asia Development Bank (2003): Cambodia Sectoral Policy Implementation Assessment.

Ballard, Brett (2003); *“Refugee Reintegration in Rural Areas: Land Distribution in Ban Pha Thao, Lao PDR,* “ Working Paper No. 18, The Inter-University Committee on International Migration: Cambridge, MA.

Ballard, Brett (2004); *Short-term Trend of Land-Term Shift?: Institutional Credit in Rural Cambodia,* in the Cambodia Development Review, Vol. 8(4), CDRI: phnom Penh.

Ballard, Brett and So Sovannarith (2004); *Can Land Titles Help Reduce Rural Poverty in Cambodia?,* in the Cambodia Development Review, Vol. 8(3), CDRI: Phnom Penh.

Ballard, Brett and So Sovannarith (forthcoming); *Cambodia Land Titling Program: Baseline Survey Project Final Report, Rural Phase 1,* CDRI and MLMUPC: Phnom Penh.

Barzel, Yoram (1989); *Economic Analysis of Property Rights,* Cambridge Press.

Biddulph, Robin (2000a); *Interim Report on Findings of Landlessness and Development Information Tool (LADIT),* Oxfam GB: Phnom Penh.

Biddulph, Robin (2000b); “Landlessness: A Growing Problem,” *Cambodia Development Review,* September 2000, CDRI: Phnom Penh.

Biddulph, Robin (2004); *Poverty and Social Impact Assessment of Social Land Concessions in Cambodia: Landlessness Assessment,* January, Oxfam GB: Phnom Penh.

Boreak, Sik (2000); *Land Ownership, Sales and Concentration in Cambodia,* Working Paper No. 16, Cambodia Development Resource Institute: Phnom Penh.

Boserup, Ester (1965); *The Conditions for Agricultural Growth,* Chicago: Aldine.

Brandao, A S P and Gershon Feder (1996); *"Regulatory Policies and Reform: The Case of Land Markets,"* PSD Occasional Paper No. 15, The World Bank, Washington, DC, January.

Kang Chandararot (2002); *The Development of Micro Finance in Cambodia*, in the Cambodia Development Review, Vol. 6(3): 1-4, Cambodia Development Resource Institute: Phnom Penh.

Kang Chandararot and Chan Sophal (2003); *Cambodia's Annual Economic Review*, Cambodia Development Resource Institute: Phnom Penh.

Libecap, Gary (1989); *Contracting for Property Rights*, New York: Cambridge University Press.

Munro-Faure, Paul (2003); *"Regularization of Property Rights and Rural Development: Challenges for Latin America,"* Faure.PDF.

North, Douglas (1990); *Institutions, Institutional Change, and Economic Performance*, Cambridge: Cambridge University Press.

Onchan, Tongroj and Saroj Aungsumalin (2002); Socio-Economic and Environmental Impact of the Land Titling Program; Kasetsart University: Thailand.

Payne, Geoffrey (2000), *"Urban Land Tenure Policy Options: Titles or Rights?"* Paper presented at the World Bank Urban Forum, Virginia.

RGC (1999), *Report of the Cambodia Socio-economic Survey 1999*, (Phnom Penh, Ministry of Planning).

Sedara, Kim, Chan Sophal, and Sarthi Acharya (2002); "*Land, Rural Livelihoods and Food Security in Cambodia: A Perspective from Field Reconnaissance*," Working Paper No. 24, Cambodia Development Resource Institute: Phnom Penh.

So Savannarith, Real Sopheap, Uch Utey, Sy Rathmony, Brett Ballard, and Sarthi Acharya (2001); "*Social Assessment of Land in Cambodia*,"Working Paper No. 20, Cambodia Development Resource Institute: Phnom Penh.

